សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royal de Droit des Sciences Economiques
Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់
# (ចាប់ពីឆ្នាំ២០១៤-២០១៨)

ស្រាវជ្រាវចាប់ពីថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២០ ដល់ថ្ងៃទី១៥ ខែឧសភា ឆ្នាំ២០២០


ស្រាវជ្រាវដោយនិស្សិត

**កញ្ញា យ៉ុង គឹមយី**

**កញ្ញា ជា លាងអេង**

សាស្ត្រាចារ្យណែនាំ

**បណ្ឌិត សឿន សោភ័ណ**


ថ្នាក់បរិញ្ញាបត្រ **រដ្ឋបាលសាធារណៈ** ឆ្នាំសិក្សា ២០១៦

ជំនាន់ទី១៣ ឆ្នាំសរសេរសារណា ២០២០

## **សេចក្តីថ្លែងអំណរគុណ**

នាងខ្ញុំ **ជា លាងអេង** និងកញ្ញា **យ៉ុង គឹមយី** ដែលជានិស្សិតថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ ក្រុមP4A1 ឆ្នាំសិក្សា២០១៩-២០២០ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**<u>សូមគោរពដឹងគុណ និងថ្លែងអំណរគុណជា អនេកប្បការជូនចំពោះ</u>**

- នាងខ្ញុំឈ្មោះ **យ៉ុង គឹមយី** សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះ លោកឪពុកឈ្មោះ **លី យ៉ុង** និង អ្នកម្តាយឈ្មោះ **គុលចន្ធូរ** ដែលបានចិញ្ចឹមបីបាច់ ថែរក្សាកូន ផ្តល់ដំបូន្មានប្រៀនប្រដៅ ទាំងកាយ ទាំងចិត្ត និងឧបត្ថម្ភទាំងសម្ភារៈ ក៏ដូចជាថវិកាឲ្យកូនបានសិក្សារហូតដល់សាកលវិទ្យាល័យ ដោយពុំខ្លាចនឿយហត់។
- នាងខ្ញុំឈ្មោះ **ជា លាងអេង** សូមសម្តែងនូវការគោរពដឹងគុណដ៏ជ្រាលជ្រៅជូនចំពោះ លោកឪពុកឈ្មោះ **ជា លឹមហ៊ន់** និង អ្នកម្តាយឈ្មោះ **ណែម ទូច** ដែលបានចិញ្ចឹមបីបាច់ថែរក្សាកូន និងផ្តល់ភាពកក់ក្តៅដល់កូនគ្រប់ពេលជាពិសេសលោកទាំងពីរបានបញ្ជូនកូនអោយចូលរៀនតាំងពីបឋមរហូតមកដល់សាកលវិទ្យាល័យដោយពុំខ្លាចនឿយហត់ឡើយ។
- ឯកឧត្តម **បណ្ឌិត លុយ ចណ្ណា** ដែលជាសាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងវិទ្យាសាស្ត្រសេដ្ឋកិច្ច
- លោកសាកលវិទ្យាធិការរង
- លោក លោកស្រីជាព្រឹទ្ធបុរស ព្រឹទ្ធបុរសរង
- លោក លោកស្រីជាប្រធាន អនុប្រធានការិយាល័យ
- លោកសាស្ត្រាចារ្យ **បណ្ឌិត សឿន សោភ័ណ** ជាសាកលវិទ្យាធិការរងនិងជាសាស្ត្រាចារ្យណែនាំ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការណែនាំ ផ្តល់ដំបូន្មានល្អៗ ត្រួតពិនិត្យ និងកែលម្អនូវចំណុចខ្វះខាតទៅលើសារណាបញ្ចប់ការសិក្សារបស់នាងខ្ញុំទាំងពីរនាក់យ៉ាងយកចិត្តទុកដាក់។
- លោក **ប៉ោ អៀត** និង **លោក ផៃ ច័ន្ទសុភី** ជាអភិបាលរងស្រុកមេមត់ ដែលបានចំណាយពេលវេលាហើយផ្តល់ឱកាសដល់នាងខ្ញុំទាំងពីរនាក់ក្នុងការចុះប្រមូលឯកសា ដែលពាក់ព័ន្ធនឹងការសរសេសារណាបញ្ចប់ការសិក្សារបស់យើងខ្ញុំទាំងពីរនាក់។
- លោក **អ៊ឹង សំអុល** ជានាយករដ្ឋបាលស្រុកមេមត់ដែលបានជួយសម្របសម្រួលក្នុងការចុះស្រាវជ្រាវឯកសារដល់នាងខ្ញុំទាំងពីរនាក់។
- លោក **ញឹម ចណ្ឌី** ជានាយករងរដ្ឋបាលនៃស្រុកមេមត់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការផ្តល់នូវឯកសារ និងទិន្នន័យសំខាន់ៗដល់នាងខ្ញុំទាំងពីរនាក់។
- មិត្តរួមថ្នាក់ និងមិត្តរួមជំនាន់ទាំងអស់ ដែលបានចែករំលែកចំណេះដឹង និងលើកទឹកចិត្ត ជាពិសេស លោក **ធី ធារុន** ដែលជាមិត្តសិក្សារួមជំនាន់ដែលបានផ្តល់នូវសម្ភារៈសិក្សាស្រាវជ្រាវសារណាក្នុងការបញ្ចប់ការ

សិក្សារបស់នាងខ្ញុំទាំងពីរនាក់។

ចុងក្រោយយើងខ្ញុំទាំងពីរនាក់ពិតជាមិនអាចបំភ្លេចនូវគុណូបការៈនេះបានឡើយហើយសូមប្រសិទ្ធិពរជ័យជូនលោកឪពុកអ្នកម្ដាយ ឯកឧត្តម លោក លោកស្រី អោយមានសុខភាពល្អជាពិសេសទទួលបាននូវជោគជ័យគ្រប់ភារកិច្ច ហើយសូមអោយជួបតែពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

ស្រុកមេមត់ជាស្រុកដែលស្ថិតក្នុងចំណោមក្រុង - ស្រុក ទាំង៧ នៃខេត្តត្បូងឃ្មុំ ដែលបានបំបែកចេញពីខេត្តកំពង់ចាម និងជារដ្ឋបាលថ្នាក់ក្រោមជាតិមួយមានរចនាសម្ព័ន្ធដឹកនាំជាក់លាក់ និងមានការគ្រប់គ្រងដោយអនុលោមទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។ ស្រុកមេមត់ជារដ្ឋបាលដែនដីថ្នាក់ក្រោមជាតិមួយដែលចំណុះអោយរាជរដ្ឋាភិបាលក្នុងការបម្រើប្រជាពលរដ្ឋ។ ដោយហេតុនេះក្រុមយើងខ្ញុំទាំងពីរនាក់បានលើកយកប្រធានបទ "**ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់**" យកមកសិក្សាស្រាវជ្រាវ និងចងក្រងជាសារណា ដើម្បីស្វែងយល់ពីដំណើរការនៃការគ្រប់គ្រងរបស់រដ្ឋបាលស្រុក និងចូលរួមចំណែកក្នុងការកែលម្អ និងបំពេញនូវចំណុចខ្វះខាត អោយទទួលបាននូវប្រសិទ្ធិភាព និងលើកកម្ពស់នូវលិទ្ធិប្រជាធិបតេយ្យដែលជាចំណែកនៃការអភិវឌ្ឍន៍ប្រទេសជាតិឱ្យមានភាពរីកចម្រើនលើគ្រប់វិស័យ។

នៅក្នុងការសិក្សាស្រាវជ្រាវប្រធានបទមួយនេះយើងទាំងពីរនាក់បានសិក្សានិងប្រមូលនូវកម្រងឯកសារដែលពាក់ព័ន្ធជាច្រើនដូចជា សៀវភៅច្បាប់នានា និងមានការពិគ្រោះយោបល់ជាមួយលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ រួមទាំងមានការចូលរួមពីសំណាក់លោកអភិបាលរងស្រុក លោកនាយករដ្ឋបាល នាយករដ្ឋបាលរង ដើម្បីស្រាវជ្រាវ ស្វែងរកទិន្នន័យបន្ថែម ដើម្បីបង្កើតជាសៀវភៅមួយក្បាលនេះឡើង។ សារណាមួយនេះ និងចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងការសិក្សាស្រាវជ្រាវ និងជាឯកសារជំនួយស្មារតីដល់អ្នកសិក្សាជំនាន់ក្រោយនៅក្នុងយកទៅសិក្សាបន្ត។

ជាការពិតណាស់កិច្ចការស្រាវជ្រាវមួយនេះប្រាកដជាមានចំណុចខ្វះខាតនិងមិនទាន់បានគ្រប់ជ្រុងជ្រោយប្រសើរនៅឡើយទេក្នុងការប្រើពាក្យពេចន៍ អក្ខរាវិរុទ្ធ ឃ្លាឃ្លោង ឬរចនាបថនៃប្រការណាមួយដោយអចេតនា។

ជាចុងក្រោយក្នុងនាមជាអ្នកស្រាវជ្រាវ សូមអធ្យាស្រ័យ និងអភ័យទោសនូវរាល់កំហុសដែលមាននៅក្នុងកិច្ចការស្រាវជ្រាវមួយនេះ ហើយក៏សូមស្វាគមន៍នូវរាល់មតិរិះគន់ទាំងឡាយពីសំណាក់សាស្ត្រាចារ្យ លោកគ្រូ អ្នកគ្រូ មិត្តៗនិស្សិតទាំងអស់ផងដែរ ដែលបានចូលរួមកែតម្រូវចំនុចខ្វះខាត និងញ៉ាំងឲ្យមានការសិក្សាស្រាវជ្រាវនេះមានអត្ថន័យនិងខ្លឹមសារត្រឹមត្រូវប្រសើរឡើង។

# មាតិកា

ទំព័រ

**បញ្ជីអក្សរកាត់**......vi

**បញ្ជីតារាង**......vii

**បញ្ជីប្រអប់**......viii

**សេចក្តីផ្តើម**......១

**១ លំនាំបញ្ហានៃការស្រាវជ្រាវ**......១

**២. ចំណោទបញ្ហានៃការស្រាវជ្រាវ**......២

**៣. គោលបំណងនៃការស្រាវជ្រាវ**......២

**៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ**......២

**៥. សារៈសំខាន់នៃការស្រាវជ្រាវ**......២

**៦. វិធីសាស្ត្រនៃការស្រាវជ្រាវ**......៣

**៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ**......៣

**ជំពូក ១**

**ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ**

**១.១ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល**......៤

១.១.១. ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ......៤

១.១.២.ប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ......៤

១.១.៣. ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ......៥

**១.២ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**......៦

១.២.១. ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ......៦

១.២.២. សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ......៦

១.២.៣. តួនាទី ភារកិច្ច សិទ្ធិអំណាចក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ......៧

**១.៣. គណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ**......៧

**១.៤. មុខងាររបស់រដ្ឋបាលស្រុក**......៨

**១.៥. ទំនាក់ទំនងរវាងក្រុមប្រឹក្សានិងគណៈអភិបាលស្រុក**......៩

**១.៦. ការបង្កើតការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ**......១០

១.៦.១. តួនាទី ភារកិច្ចរបស់ការិយាល័យរបស់ប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ.................................. ១០

១.៦.២. សិទ្ធិអំណាចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ........................................... ១០

១.៦.៣. លក្ខខណ្ឌនិងលក្ខណសម្បត្តិបេក្ខជនសម្រាប់ឈរឈ្មោះបោះឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ ................................................................................................ ១១

**១.៧. ទំនាក់ទំនងរវាងរដ្ឋបាលស្រុក ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព**......................១២

**១.៨. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្ត**................................................១៣

**១.៩. ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក** ........................... ១៤

**១.១០. របបហិរញ្ញវត្ថុរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ** ................................................ ១៤

១.១០.១. ប្រភពចំណូល............................................................................................. ១៥

## ជំពូក ២

## ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់

**២.១. ស្ថានភាពទីតាំងភូមិសាស្ត្រ និងប្រជាសាស្ត្រ**................................................ ១៦

២.១.១. ស្ថានភាពទីតាំងភូមិសាស្ត្រ................................................................................ ១៦

២.១.២. ស្ថានភាពប្រជាសាស្ត្រ....................................................................................... ១៦

**២.២. ស្ថានភាពសេដ្ឋកិច្ច** ......................................................................................... ១៦

២.២.១. វិស័យកសិកម្ម................................................................................................. ១៦

២.២.២. វិស័យឧស្សាហកម្ម និងសិប្បកម្ម ...................................................................... ១៦

**២.៣. ស្ថានភាពសង្គមកិច្ច**.........................................................................................១៧

២.៣.១. វិស័យអប់រំ.......................................................................................................១៧

២.៣.២. វិស័យសុខាភិបាល ............................................................................................១៧

២.៣.៣. ស្ថានភាពយេនឌ័រ ............................................................................................១៧

២.៣.៤. ស្ថានភាពនៃភាពក្រីក្រ........................................................................................ ១៨

២.៣.៥. ស្ថានភាពសាសនា .............................................................................................. ១៨

២.៣.៦. ការងាររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកមេមត់................................ ១៨

២.៣.៧. ការងាររ៉ែ និងថាមពលក្នុងស្រុកមេមត់ ................................................................... ១៩

២.៣.៨. ការងារមីក្រូហិរញ្ញវត្ថុក្នុងស្រុកមេមត់ ........ ១៩
**២.៤. តួនាទី ភារកិច្ច និងអង្គដឹកនាំរបស់សាលាស្រុក** ........ ២០
២.៤.១. អង្គដឹកនាំរបស់សាលាស្រុកមេមត់ ........ ២០
២.៤.២. តួនាទី ភារកិច្ច ........ ២១
**២.៥. ការិយាល័យចំណុះរដ្ឋបាលស្រុកមេមត់** ........ ២៧
**២.៦. ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលស្រុកមេមត់** ........ ៣០
**២.៧. ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល** ........ ៣១
២.៧.១. គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ........ ៣១
២.៧.២. តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាក្នុងការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ ........ ៣២
២.៧.៣. តួនាទីរបស់ក្រុមប្រឹក្សាស្រុកក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ........ ៣៣
២.៧.៤. ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់រដ្ឋបាលស្រុក ........ ៣៤
២.៧.៥. ដំណើរការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ........ ៣៥
**២.៨. ថវិការបស់រដ្ឋបាលស្រុក** ........ ៣៦

## ជំពូក ៣

## ការសិក្សាលើរបកគំហើញ

**៣.១. ការងាររដ្ឋបាល** ........ ៣៧
៣.១.១. ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ ........ ៣៧
៣.១.២. ការគ្រប់គ្រងប្រជាពលរដ្ឋ ........ ៣៧
៣.១.៣.ការងារអត្រានុកូលដ្ឋាន ........ ៣៨
៣.១.៤. ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តជាតិ ........ ៣៩
៣.១.៥. ការងារគណៈអភិបាល ........ ៣៩
៣.១.៦. ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា ........ ៤០
៣.១.៧. ការងាររៀបចំវេទិការ ........ ៤០
**៣.២. ការងារផែនការ និងការគាំទ្រឃុំ** ........ ៤១
៣.២.១. ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ ........ ៤១

៣.២.២. ការអនុវត្តគម្រោងវិនិយោគ ..................................................... ៤២

៣.២.៣. ការគាំទ្រឃុំ ..................................................... ៤៣

**៣.៣. ការងារហិរញ្ញវត្ថុ** ..................................................... ៤៣

៣.៣.១. ការអនុវត្តចំណូល និងចំណាយ ..................................................... ៤៣

៣.៣.២. ការគ្រប់គ្រងទ្រព្យសម្បត្តិ ..................................................... ៤៤

**៣.៤. ការងារលទ្ធផល** ..................................................... ៤៤

**៣.៥. ការងារអន្តរវិស័យ** ..................................................... ៤៥

៣.៥.១. ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់ ..................................................... ៤៥

៣.៥.២. កិច្ចការសេវាសង្គម និងការបង្កើតសិទ្ធិអំណាចស្ត្រី ..................................................... ៤៦

៣.៥.៣. ការងារគ្រប់គ្រងច្រកព្រំដែន ..................................................... ៤៦

**៣.៦. ការងាររបស់ការិយាល័យ អង្គភាពជំនាញ** ..................................................... ៤៦

៣.៦.១. សេដ្ឋកិច្ច ..................................................... ៤៦

៣.៦.២. ការអភិវឌ្ឍន៍ ..................................................... ៤៧

៣.៦.៣. ការងារសាធារណៈការស្រុក ..................................................... ៤៨

**៣.៧ សង្គមកិច្ច** ..................................................... ៤៩

៣.៧.១. ការងារអប់រំ ..................................................... ៤៩

៣.៧.២. ការងារសុខាភិបាល ..................................................... ៥០

៣.៧.៣. ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ..................................................... ៥១

៣.៧.៤. ការងារធម្មការ និងសាសនា ..................................................... ៥២

៣.៧.៥ ការងារកិច្ចការនារី ..................................................... ៥៣

៣.៧.៦. ការិយាល័យការងារ ..................................................... ៥៤

៣.៧.៧. ការិយាល័យឧស្សាហកម្ម និងសិប្បកម្ម ..................................................... ៥៤

**៣.៨ ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុនិងគ្រោះមហន្តរាយ** ..... ៥៥

៣.៨.១. ការងារភូមិបាល ..................................................... ៥៥

៣.៨.២. ការងារបរិស្ថាន ..................................................... ៥៥

**៣.៩. រដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ** ..................... ៥៦
៣.៩.១. សភាពការណ៍សន្តិសុខនយោបាយ ..................... ៥៦
៣.៩.២. អំពីការបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ ..................... ៥៦
៣.៩.៣. ការងារផែនការ ..................... ៥៦
**៣.១០. ការងារផ្នែករដ្ឋបាលឃុំ សង្កាត់** ..................... ៥៧
៣.១០.១. ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក ..................... ៥៧
៣.១០.២. ដីកា សេចក្តីសម្រេច និងលិខិត ..................... ៥៧
៣.១០.៣. កិច្ចប្រជុំក្រុមប្រឹក្សាឃុំ និង គ.ក.ន.ក ..................... ៥៨
៣.១០.៤. ចំនួនគម្រោង និងថវិកាវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ ..................... ៥៨
៣.១០.៥. ចំនួនគម្រោង និងតម្លៃគម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង ..................... ៥៩
៣.១០.៦. ការអនុវត្តថវិកាឃុំ ..................... ៦០
៣.១០.៧. ការគ្រប់គ្រងទ្រព្យសម្បត្តិ ..................... ៦០
៣.១០.៨. ការអភិវឌ្ឍសមត្ថភាព ..................... ៦១
៣.១០.៩. សកម្មភាពសេវាសង្គម ..................... ៦១
៣.១០.១០. ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់ ..................... ៦២
៣.១០.១១. ការងារអត្រានុកូលដ្ឋាន ..................... ៦៣
**៣.១១. បញ្ហាប្រឈម** ..................... ៦៣
**សេចក្តីសន្និដ្ឋាន** ..................... ៦៤
**អនុសាសន៍** ..................... ៦៥
**ឯកសារយោង**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- **គ.ក.ន.ក:** គណៈកម្មការទទួលបន្ទុកកិច្ចការនារី និងកុមារ
- **គ.ក.ស.ក:** គណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ
- **គ.ជ.អ.ប:** គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- **ស.អ.យ:** ក្រសួង សង្គមកិច្ច អតីតយុទ្ធជន យុវនីតិសម្បទា
- **អ.យ.ក:** ក្រសួងអប់រំយុវជន និងកីឡា

# បញ្ជីតារាង


ទំព័រ

1. តារាងលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ ៣៧
2. តារាងការគ្រប់គ្រងប្រជាពលរដ្ឋ ៣៨
3. តារាងការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន ៣៩
4. តារាងកិច្ចប្រជុំអភិបាល ៣៩
5. តារាងកិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា ៤០
6. តារាងការរៀបចំវេទិកា ៤០
7. តារាងចំនួនគម្រោង និងថវិកាដែលគ្រោងវិនិយោគ ៤១
8. តារាងចំនួនគម្រោងនិងថវិកាដែលបានអនុវត្តជាក់ស្តែង ៤២
9. តារាងចំណូល ចំណាយ ៤៣
10. តារាងការគ្រប់គ្រងទ្រព្យសម្បត្តិ ៤៤
11. តារាងការដោះស្រាយ និងការសម្រុះសម្រួលទំនាស់ ៤៥
12. តារាងការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក ៤៦
13. តារាងស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក ៥៧
14. តារាងដីកា សេចក្តីសម្រេច និងលិខិត ៥៧
15. តារាងកិច្ចប្រជុំក្រុមប្រឹក្សា និង គ.ក.ន.ក ៥៨
16. តារាងចំនួនគម្រោង និងថវិកាវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកា ៥៨
17. តារាងចំនួនគម្រោង និងតម្លៃវិនិយោគដែលបានអនុវត្តជាក់ស្តែង ៥៩
18. តារាងការអនុវត្តថវិកាឃុំ ៥៩
19. តារាងការគ្រប់គ្រងទ្រព្យសម្បត្តិ ៦០
20. តារាងការអភិវឌ្ឍសមត្ថភាព ៦០
21. តារាងសកម្មភាពសេវាសង្គម ៦០
22. តារាងការដោះស្រាយ និងការសម្រុះសម្រួលទំនាស់ ៦១
23. តារាងការងារអត្រានុកូលដ្ឋាន ៦១
24. តារាងការចុះបញ្ជី និងការពិនិត្យបញ្ជីឈ្មោះអ្នកបោះឆ្នោត ៦១

# បញ្ជីប្រអប់

ទំព័រ

1. បញ្ជីប្រអប់ អង្គដឹកនាំរបស់រដ្ឋបាលស្រុក ២១

# សេចក្តីផ្តើម

## ១ លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា គឺជារដ្ឋទោល និងជារដ្ឋដែលមិនអាចបំបែកបានដូចមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងឃុំ សង្កាត់។ ប្រទេសកម្ពុជាបានឆ្លងកាត់ការរៀបចំប្រព័ន្ធគ្រប់គ្រងរដ្ឋបាលជាច្រើន ទៅតាមសម័យកាលដែលជាប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការដោយអំណាចទាំងអស់ប្រមូលផ្តុំនៅរដ្ឋបាលថ្នាក់ជាតិ ឬរដ្ឋបាលថ្នាក់កណ្តាល។ នៅចុងទសវត្សទី៩០ រាជរដ្ឋាភិបាលបានគិតគូរផ្ទេរការទទួលខុសត្រូវឲ្យទៅរដ្ឋបាលមូលដ្ឋាន (ថ្នាក់ក្រោមជាតិ) ដើម្បីជួយដល់រាជរដ្ឋាភិបាលអភិវឌ្ឍមូលដ្ឋាន និងផ្តល់សេវាជូនប្រជាពលរដ្ឋទាន់ពេលវេលា។ រហូតដល់ឆ្នាំ២០០១ ទើបរាជរដ្ឋាភិបាលបានរៀបចំអោយមានច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ និងមានការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅឆ្នាំ២០០២។ ទន្ទឹមនឹងនោះនៅឆ្នាំ២០០៨ ក៏មានការលេចឡើងនូវច្បាប់មួយទៀតស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

តាមរយៈគោលនយោបាយវិមជ្ឈការ និង វិសហមជ្ឈការបានធ្វើអោយការគ្រប់គ្រងរដ្ឋបាលមានភាពជិតស្និតនៅជៀកប្រជាពលរដ្ឋដែលឆ្លើយតបទៅនឹងសេចក្តីត្រូវការបានទាន់ពេលវេលា។ ដោយរាជរដ្ឋាភិបាលមើលឃើញពីភាពចាំបាច់និងលទ្ធផលដែលទទួលបានកន្លងមករាជរដ្ឋាភិបាលបច្ចុប្បន្ន បានគិតគូរនៅពេលអនាគតរដ្ឋបាលថ្នាក់ក្រោមជាតិនិងទទួលបានអំណាចកាន់តែច្រើននៅក្នុងការគ្រប់គ្រងកិច្ចការមូលដ្ឋាន និងបុគ្គលិករបស់ខ្លួនផ្ទាល់។ ជាក់ស្តែងនៅ ខែមិថុនា ឆ្នាំ២០១៣ ជាមួយនឹងការធ្វើវិសោធនកម្មមាត្រា២៨នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃ គណៈរដ្ឋមន្ត្រីដែលមានបង្ហាញយ៉ាងច្បាស់ពីការធ្វើប្រតិភូកម្មអំណាចដល់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រង ការចាត់ចែង ការប្រើប្រាស់ ការតែងតាំង ការផ្លាស់ប្តូរ និងការបញ្ចប់ភារកិច្ច មន្ត្រីរាជការរបស់ក្រសួងស្ថាប័នដែលបំពេញការងារនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

ស្រុកមេមត់ គឺជាស្រុកមួយដែលស្ថិតក្នុងចំណោមក្រុង-ស្រុក ទាំង៧ នៃខេត្តត្បូងឃ្មុំដែលបានបំបែកចេញពីខេត្តកំពង់ចាម តាមព្រះរាជក្រឹត្យលេខ នស/រកត/១២០៣/១៤៤៥ ចុះថ្ងៃទី ៣១ ធ្នូ ២០១៣ និងសម្ពោធអោយប្រើប្រាស់នូវរដ្ឋបាលសាលាខេត្តត្បូងឃ្មុំ នៅថ្ងៃទី០២ មិថុនា ២០១៤។ ស្រុកមេមត់មានផ្ទៃដីសរុប១៦០,១៣០គីឡូម៉ែតការ៉េ ហើយក៏ជារដ្ឋបាលដែនដីមួយដែលប្រសូត្រចេញពីច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ មានតួនាទីភារកិច្ច មុខងារ និង កាតព្វកិច្ចជាច្រើនដែលត្រូវបំពេញឲ្យបាននៅក្នុងការកសាងអភិវឌ្ឍអោយបានសម្រេចចេញជាសមិទ្ធផលទៅតាមរយៈគោលនយោបាយជាយុទ្ធសាស្ត្រនានារបស់រាជរដ្ឋាភិបាល។ ដើម្បីអោយយល់ដឹងកាន់តែច្បាស់នូវដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់យើងខ្ញុំទាំងពីរនាក់បានលើកយកប្រធានបទមួយស្តីពី « **ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ ឆ្នាំ ២០១៤~២០១៨**» មកធ្វើការសិក្សា។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយផ្អែកតាមច្បាប់និងលិខិតបទដ្ឋានគតិយុតិផ្សេងៗដែលពាក់ព័ន្ធនឹង ការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិយើងឃើញថារដ្ឋបាលកណ្តាលបាននឹងកំពុងផ្តល់សិទ្ធិអំណាចដោយការប្រគល់ ផ្ទេរ និងធ្វើ ប្រតិភូកម្មនូវមុខងារមួយចំនួនទៅដល់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដើម្បីងាយស្រួលឆ្លើយតបទៅនឹងការបម្រើសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងការមើលឃើញពីសិទ្ធិអំណាចដែលរដ្ឋបាលថ្នាក់ក្រោមជាតិទទួលបានដោយរដ្ឋបាលកណ្តាលបានធ្វើអោយប្រធានបទ‹**ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ (ចាប់ពីឆ្នាំ២០១៤~២០១៨)**› ជាប្រធានបទមួយដែលផ្តល់ឱកាសដល់អ្នកសិក្សាស្រាវជ្រាវស្វែងយល់បន្ថែមពីការគ្រប់គ្រងរបស់រដ្ឋបាលស្រុក និងមានឱកាសផ្តល់ជាអនុសាសន៍ដើម្បីជាប្រយោជន៍ទៅដល់រដ្ឋបាលស្រុក។ ការសិក្សាស្រាវជ្រាវនេះបានលើកយកចំណោទបញ្ហាមួយចំនួនចងជាសំណួរដូចខាងក្រោមៈ

១ តើដំណើរការនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ប្រព្រឹត្តទៅយ៉ាងដូចម្តេចខ្លះ?

២ តើបញ្ហាប្រឈមអ្វីខ្លះដែលរារាំងដល់ការអភិវឌ្ឍន៍របស់រដ្ឋបាលស្រុក?

៣ តើរដ្ឋបាលស្រុក មានវិធានការ និងដំណោះស្រាយបែបណាក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនោះ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី **ការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ឆ្នាំ២០១៤~២០១៨** នេះមានគោលបំណងដូចជា៖

១ ស្វែងយល់ពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗដែលពាក់ព័ន្ធនឹងការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ ជាពិសេសស្វែងយល់ពីការផ្ទេរ និងការធ្វើប្រតិភូកម្មមុខងារមួយចំនួនទៅដល់រដ្ឋបាលស្រុក។

២ បង្ហាញពីដំណើរការគ្រប់គ្រងរបស់រដ្ឋបាលស្រុក លទ្ធផល បញ្ហាប្រឈមរបស់រដ្ឋបាលស្រុក និង ដំណោះស្រាយរបស់រដ្ឋបាលស្រុក

៣ បានចូលរួមចំណែកនៅក្នុងការចងក្រងជាឯកសារទុកសម្រាប់ អ្នកបន្តវេន និងសិស្សប្អូនជំនាន់ក្រោយ។

## ៤. ដែនកំណត់និងវិសាលភាពនៃការស្រាវជ្រាវ

ដែនកំណត់នៃប្រធានបទគឺស្រាវជ្រាវត្រឹមឆ្នាំ ២០១៤~២៩១៨ ។ វិសាលភាពនៃការសិក្សាស្រាវជ្រាវនេះគឺមានទីតាំងនៅស្រុកមេមត់ ខេត្តត្បូងឃ្មុំតែប៉ុណ្ណោះ។

## ៥. សារៈសំខាន់នៃការស្រាវជ្រាវ

សារៈសំខាន់នៃប្រធានបទខាងលើមានដូចជា៖

- សារៈសំខាន់ចំពោះរដ្ឋបាលស្រុកមេមត់ គឺផ្តល់នូវចំណុចខ្វះខាតដែលរដ្ឋបាលស្រុកគួរកែលម្អ និងបន្តនូវកិច្ចអភិវឌ្ឍស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល
- សារៈសំខាន់ចំពោះនាងខ្ញុំទាំងពីរនាក់ គឺបានបង្កើននូវចំណេះដឹងតាមរយៈការសិក្សាស្រាវជ្រាវ និងប្រមូល

ទិន្នន័យដែលពាក់ព័ន្ធនឹងប្រធានបទក្នុងការបញ្ចប់ថ្នាក់បរិញ្ញាបត្ររដ្ឋបាលសាធារណៈ លើសពីនេះបានផ្តល់ឱកាសដល់ការសរសេរសៀវភៅនេះឡើងក្នុងការផ្តល់នូវចំណេះដឹងអោយដល់អ្នកសិក្សាស្រាវជ្រាវជំនាន់ក្រោយបានស្វែងយល់។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

ការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវលើប្រធានបទនេះគឺធ្វើឡើងដោយប្រើទិន្នន័យពីរប្រភេទដូចខាងក្រោម៖

+ ទិន្នន័យបន្ទាប់បន្សំ ៖ ជាទិន្នន័យដែលមានស្រាប់ដូចជាច្បាប់ លិខិតបទដ្ឋានគតិយុត្ត ឯកសារផ្ទាល់ពីរដ្ឋបាលស្រុកមេមត់ ឯកសារជាសៀវភៅដែលមាននៅក្នុងបណ្ណាល័យ វេបសាយក្រសួងមហាផ្ទៃ អ៊ីធឺណេត Google ជាដើម។

+ ទិន្នន័យចម្បង ៖ ជាការចុះទៅផ្ទាល់ជួបសម្ភាសន៍ជាមួយលោកអភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល ប្រធានការិយាល័យ បុគ្គលិក មន្ត្រីរាជការដែលបម្រើការងារនៅស្រុកមេមត់ផ្ទាល់តែម្តង។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

នៅក្នុងរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ បានធ្វើការបែងចែកចេញជា ៣ជំពូកដែលមានដូចខាងក្រោម៖

- សេចក្តីផ្តើម
- ជំពូក ១ ៖ ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ
- ជំពូក ២ ៖ ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់
- ជំពូក ៣៖ ការសិក្សាលើរបកគំហើញ
- សេចក្តីសន្និដ្ឋាន
- អនុសាសន៍
- ឯកសារយោង
- ឧបសម្ព័ន្ធ។

# ជំពូក ១

# ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ

## ១.១ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាល

ដើម្បីអនុវត្តនូវសកម្មភាពរបស់ខ្លួនអាជ្ញាធរកណ្តាលអាចធ្វើការជ្រើសរើសរូបមន្តដូចជា៖ ប្រព័ន្ធគ្រប់គ្រងរដ្ឋបាលតាមបែបមជ្ឈការប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ និងប្រព័ន្ធគ្រប់គ្រងតាមបែបវិមជ្ឈការ។

### ១.១.១ ប្រព័ន្ធគ្រប់គ្រងបែបមជ្ឈការ

វាជាការគ្រប់គ្រងមួយប្រភេទដែលរដ្ឋបាលកណ្តាលដឹកនាំរដ្ឋបាលដោយផ្ទាល់(អំណាចប្រមូលផ្តុំ) លក្ខណៈនេះមិនអាចអនុវត្តបានទាំងស្រុងទេ យ៉ាងហោចណាស់ក៏រដ្ឋបានបង្កើតអាជ្ញាធរដែនដីត្រឹមថ្នាក់រាជធានី ខេត្តដែរ។ ប៉ុន្តែរាជធានីខេត្តគ្មានសិទ្ធិសម្រេចអ្វីទាំងអស់ ពីព្រោះអំណាចទាំងអស់បានត្រូវប្រមូលផ្តុំទៅលើ អាជ្ញាធររដ្ឋបាលកណ្តាល។ ប្រព័ន្ធគ្រប់គ្រងតាមបែបមជ្ឈការនេះនាំឱ្យមានទាំងគុណសម្បត្តិ និងគុណវិបត្តិ[1]ដូចតទៅ៖

**គុណសម្បត្តិរួមមាន៖**

- អាជ្ញាធររដ្ឋបាលកណ្តាលអាចជួយមូលដ្ឋានបាន
- អាជ្ញាធរតែងតាំងបុគ្គលអោយបម្រើការនៅមូលដ្ឋាន សុទ្ធតែជាមនុស្សមានសមត្ថភាព
- មានឯកភាពជាតិ ដោយសារស្ថិតក្រោមការត្រួតត្រាតែមួយ ហើយត្រូវអនុវត្តដូចគ្នាក្នុងដែនដីតែមួយ

**គុណវិបត្តិរួមមាន៖**

- យឺតយ៉ាងខាតសោហ៊ុយ ដោយសាររដ្ឋបាលកណ្តាលសម្រេចតែម្នាក់ឯងជាអន្តនោម័ត
- ខ្វះលទ្ធិប្រជាធិបតេយ្យ ដោយសារអាជ្ញាធរដែនដីកើតឡើងពីការតែងតាំងពីអាជ្ញាធរថ្នាក់កណ្តាល
- ការសម្រេចមិនយល់សភាពការណ៍។

### ១.១.២.ប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការ

ដើម្បីកាត់បន្ថយផលអាក្រក់នៃការប្រមូលផ្តុំអំណាចលើរដ្ឋបាលកណ្តាលរដ្ឋជាច្រើននៅលើពិភពលោក បានអនុវត្តរូបមន្តនៃការពង្រាងអំណាចរដ្ឋបាលពោលគឺវិសហមជ្ឈការ។ ក្នុងប្រព័ន្ធគ្រប់គ្រងតាមបែបវិសហមជ្ឈការគឺជាបច្ចេកទេសរដ្ឋបាលមួយប្រភេទដែលអាជ្ញាធររដ្ឋបាលកណ្តាលរំលែកអំណាច (បែងចែក) កិច្ចការមួយចំនួនទៅឲ្យរដ្ឋបាលមូលដ្ឋានធ្វើការសម្រេចចិត្តដោយខ្លួនឯងតាមរយៈការធ្វើប្រតិភូកម្ម។ ប៉ុន្តែការធ្វើប្រតិភូកម្មនេះមិនមែនមានន័យថាប្រគល់សិទ្ធិដោយស្វ័យភាពទេ។ ផ្ទុយទៅវិញ គឺជាប្រគល់សិទ្ធិឲ្យអោយសម្រេចក្នុងនាមរដ្ឋាភិបាលមានលក្ខណៈច្បាស់លាស់ជាលាយល័ក្ខណ៍អក្សរពីការកំណត់ព្រំដែននៃសិទ្ធិនោះ និងស្ថិតក្រោមការត្រួតពិនិត្យតាមឋានានុក្រមដ៏ហ្មត់ចត់ថែមទៀត។ ប្រតិភូកម្ម គឺជាវិធីសាស្ត្រមួយក្នុងការរំលែកឬប្រគល់អំណាចមួយចំនួនទៅអោយរដ្ឋបាលថ្នាក់ក្រោមជាតិ។ ប្រតិភូកម្មមានពីរ គឺ ប្រតិភូកម្មអំណាច និងប្រតិភូកម្មហត្ថលេខា។ ប្រតិភូកម្មអំណាចជាការរំលែក

[1] បណ្ឌិតសាយបូរី *នីតិរដ្ឋបាលទូទៅ* ២០០១,ទំព័រ ៣៩៤

សមត្ថកិច្ចមួយផ្នែកទៅអោយអាជ្ញាធររដ្ឋបាលទាំងឡាយក្នុងឋានានុក្រមរបស់ខ្លួន(ពីអង្គភាពមួយទៅអង្គភាពមួយ)។ ប្រតិភូកម្មហត្ថលេខា ជាវិធីសាស្ត្រមួយដែលអាជ្ញាធរនីមួយៗអាចប្រគល់ទៅអោយសហការីណាម្នាក់របស់ខ្លួននូវការចុះហត្ថលេខាជួសនូវសេចក្តីសម្រេចខ្លះៗ (ធ្វើពីបុគ្គលមួយទៅបុគ្គលមួយ ឬធ្វើពីអាជ្ញាធរមួយទៅសហការី)។

ប្រតិភូកម្មហត្ថលេខាជាភាពងាយស្រួលមួយផ្នែកតាមការងារគ្រប់គ្រងរដ្ឋបាលដោយពុំចាំបាច់ប្រតិភូកម្មបន្តទៀតទេ។ ការធ្វើប្រតិភូកម្មហត្ថលេខា គឺមានតែទៅលើការចុះហត្ថលេខាប៉ុណ្ណោះដោយគ្មានប៉ះពាល់ដល់ការបែងចែងអំណាចទេ។ ប្រតិភូកម្មនេះតាមផ្លូវច្បាប់សេចក្តីសម្រេចទាំងឡាយ គឺជាសេចក្តីសម្រេចរបស់អាជ្ញាធរផ្ទេរហត្ថលេខា។ ដូច្នេះអាជ្ញាធរនេះជាម្ចាស់នៃការទទួលខុសត្រូវ។

ការអនុវត្តប្រព័ន្ធនេះ នឹងបង្កឱ្យមានគុណសម្បត្តិនិងគុណវិបត្តិមួយចំនួនដូចខាងក្រោម៖

**គុណសម្បត្តិ**

- កាត់បន្ថយការប្រើប្រាស់អំណាចជ្រុលហួសហេតុរបស់អាជ្ញាធររដ្ឋបាលកណ្តាល
- ជួយសម្រួលដល់ជីវភាព និងកិច្ចការរបស់រាស្ត្រ
- ការងាររឆាប់រហ័ស ចំណេញពេលវេលា និងកាត់បន្ថយភាពក្រីក្រ

**គុណវិបត្តិ**

- ខ្វះលទ្ធិប្រជាធិបតេយ្យ
- គ្មានសមត្ថកិច្ចផ្ទាល់
- គ្មានបុគ្គលភាពគតិយុត្ត

### ១.១.៣ ប្រព័ន្ធគ្រប់គ្រងបែបវិមជ្ឈការ

ជាប្រព័ន្ធមួយដែលអាជ្ញាធររដ្ឋបាលកណ្តាលទទួលស្គាល់នូវសិទ្ធិអំណាចក្នុងការសម្រេចរបស់អាជ្ញាធរនៅមូលដ្ឋានដោយមានចែងនៅក្នុងច្បាប់ឬរដ្ឋធម្មនុញ្ញ(អំណាចផ្ទេរ)។ នៅក្នុងការទទួលស្គាល់នូវសិទ្ធិអំណាចរបស់អាជ្ញាធរមូលដ្ឋាននេះ គឺជាការផ្ទេរអំណាច និងផ្ទេរការទទួលខុសត្រូវលើកិច្ចការមួយចំនួនឲ្យទៅអាជ្ញាធរមូលដ្ឋានចាត់ចែងការងារដើម្បីបំរើផលប្រយោជន៍ផ្ទាល់របស់ខ្លួន។ ប្រព័ន្ធនេះអាជ្ញាធរកើតចេញពីការបោះឆ្នោតនិង មានគោលបំណងលើកកំពស់ការគ្រប់គ្រងតាមបែបប្រជាធិបតេយ្យ អភិបាលកិច្ចល្អ លើកកម្ពស់គុណភាពជីវភាពរស់នៅ និងជាការផ្តល់ជូនប្រជាពលរដ្ឋនូវឱកាសកាន់តែច្រើនដើម្បីសម្រេចលើជោគវាសនារបស់ខ្លួនឯង។

ដើម្បីធ្វើអោយមានវិមជ្ឈការពិតប្រាកដនោះចាំបាច់ត្រូវឲ្យមានស្វ័យភាពនៃអំណាចមូលដ្ឋានចំពោះអំណាចកណ្តាល។ ប៉ុន្តែក៏មិនត្រូវឲ្យមានស្វ័យភាពពេញលេញដែរ ព្រោះវាអោយធ្លាក់ចូលទៅក្នុងសម្ព័ន្ធភាពនិយម ពោលគឺការផ្តាច់ខ្លួនដើម្បីទាមទារឯករាជ្យក្នុងមណ្ឌលរបស់ខ្លួន។ ការធ្វើស្វ័យភាពពីអំណាចរដ្ឋបាលកណ្តាលនេះនៅតែអមទៅដោយការត្រួតពិនិត្យខ្លាំង ឬតិចពីរដ្ឋអំណាចកណ្តាលដែលការត្រួតពិនិត្យនេះគេឲ្យឈ្មោះថា **ការត្រួតពិនិត្យអាណាព្យាបាល** ដែលប្រែប្រួលទៅតាមស្ថានភាពនៃពេលវេលា។

គុណសម្បត្តិ

- ចំណេញពេលវេលា
- ស្វ័យភាពការងារ
- មានប្រជាធិបតេយ្យស៊ីជម្រៅ

គុណវិបត្តិ

- អាចបែកបាក់សាមគ្គីរវាងសមូហភាព
- អាចធ្វើអោយអាជ្ញាធររដ្ឋបាលកណ្តាលទុនខ្សោយ
- ការអភិវឌ្ឍន៍អាចតាមបែបអាណាធិបតេយ្យព្រោះមានការប្រកួតប្រជែងរវាងសមូហភាពរៀងៗខ្លួន។

## ១.២ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

### ១.២.១ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌត្រូវមានក្រុមប្រឹក្សារបស់ខ្លួនដែលត្រូវបានជ្រើសរើសឡើងតាមការបោះឆ្នោត។ ក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ[2]។ សមាជិករបស់ក្រុមប្រឹក្សាត្រូវបានជ្រើសរើសដោយការបោះឆ្នោតជាអសកល មិនចំពោះ ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់[3]។ ក្រុមប្រឹក្សាមានអាណត្តិប្រាំឆ្នាំ (០៥)ឆ្នាំ ហើយត្រូវផុតកំណត់នៅពេលក្រុមប្រឹក្សាថ្មីចូលកាន់ដំណែង។ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាត្រូវធ្វើតែមួយថ្ងៃ គឺនៅថ្ងៃអាទិត្យណាមួយ។ កាលបរិច្ឆេទជាក់ស្តែងនៃការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាកំណត់ដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[4]។

### ១.២.២ សមាសភាពក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ចំនួនសមាជិកក្រុមប្រឹក្សានីមួយៗត្រូវកំណត់ដោយផ្អែកលើកត្តាប្រជាសាស្ត្រ និង កត្តាភូមិសាស្ត្រដូចខាងក្រោមៈ

- ក្រុមប្រឹក្សារាជធានីភ្នំពេញ មានចំនួនសមាជិកមិនលើសពីម្ភៃប្រាំពីរ(២៧)រូប
- ក្រុមប្រឹក្សាខេត្ត មានចំនួនសមាជិកពីដប់ប្រាំ(១៥)រូប ដល់ម្ភៃប្រាំពីរ(២៧)រូប
- ក្រុមប្រឹក្សាក្រុង មានចំនួនសមាជិកពីដប់មួយ(១១)រូប ដល់ម្ភៃមួយ(២១)រូប
- ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ មានចំនួនសមាជិកពីដប់មួយ(១១)រូប ដល់ម្ភៃមួយ(២១)រូប[5]

[2] មាត្រា១ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ,២០០៨

[3] មាត្រា៤ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ,២០០៨

[4] មាត្រា៥ នៃច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ,២០០៨

[5] មាត្រា១៨ ថ្មី នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ,២០០៨

ចំនួនជាក់ស្តែងនៃសមាជិកនីមួយៗត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃក្នុងរយៈពេលយ៉ាងតិចមួយរយម្ភៃ(១២០)ថ្ងៃ មុនពេលផុតកំណត់អាណត្តិក្រុមប្រឹក្សា។

### ១.២.៣ តួនាទី ភារកិច្ច សិទ្ធិអំណាចក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការនានាដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញមុខងារភារកិច្ចដែលបានប្រគល់និងបានធ្វើប្រតិភូកម្មតាមច្បាប់នេះ ឬ ដែលស្របតាមច្បាប់នេះ[6]។

ក្រុមប្រឹក្សាមានសិទ្ធិអំណាចធ្វើសេចក្តីខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។ ក្រុមប្រឹក្សាមានសេចក្តីខាងបញ្ញត្តិរបស់ខ្លួនក្នុងការធ្វើដីការ ស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងច្បាប់។ ចំណែកឯសេចក្តីសម្រេចខាងប្រតិបត្តិក្រុមប្រឹក្សាប្រើប្រាស់នៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សា[7]។

ក្រុមប្រឹក្សាមានគណនេយ្យភាពផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសជាអាទិភាពដើម្បីធ្វើសេចក្តីសម្រេចធានាបានការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ តួនាទីរបស់ក្រុមប្រឹក្សាមានចែងនៅក្នុងមាត្រា ៣៦ មាត្រា៣៧ មាត្រា ៣៨ មាត្រា៣៩ មាត្រា៤០ មាត្រា៤១ មាត្រា៤២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

## ១.៣ គណៈអភិបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

រាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវរៀបចំអោយមានគណៈអភិបាលដែលរួមមាន ប្រធានមួយរូបហៅថាអភិបាល និងអភិបាលរងមួយរូប[8]។ សមាជិកគណៈអភិបាលកំណត់រួមមានដូចជា៖

- គណៈអភិបាលរាជធានីភ្នំពេញមានចំនួនយ៉ាងច្រើនប្រាំពីរ(០៧)រូប
- គណៈអភិបាលខេត្តមានចំនួនពីបី(០៣រូប ទៅប្រាំពីរ(០៧)រូប
- គណៈអភិបាលក្រុង ស្រុក ខណ្ឌ មានចំនួនពីបី(០៣)រូប ទៅប្រាំ(០៥)រូប[9]។

ចំនួនជាក់ស្តែងនៃគណៈអភិបាលខេត្ត ក្រុង ស្រុក ខណ្ឌត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើររបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលរាជធានី អភិបាលខេត្ត ត្រូវតែងតាំងដោយព្រះរាជក្រឹត្យតាមសំណើរបស់នាយករដ្ឋមន្ត្រីតាមសេចក្តីស្នើសុំពីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

អភិបាលរងរាជធានី អភិបាលរងខេត្ត អភិបាលក្រុង អភិបាលស្រុក អភិបាលខណ្ឌត្រូវតែងតាំងដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

---

[6] មាត្រា២៥ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , ២០០៨

[7] មាត្រា៣៣ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , ២០០៨

[8] មាត្រា១៣៩ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ , ២០០៨

[9] មាត្រា១៤០នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ,២០០៨

អភិបាលរងក្រុង អភិបាលរងស្រុក អភិបាលរងខណ្ឌ ត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ[10]។ អភិបាល អភិបាលរងមានអាណត្តិមិនលើសពីបួន(០៤)ឆ្នាំឡើយ តែអាចតែងតាំងបានចំនួនបួន(០៤)ឆ្នាំទៀតសម្រាប់អាណត្តិទី២របស់ខ្លួននៅក្នុងដែនសមត្ថកិច្ចដដែល[11]។ អភិបាល អភិបាលរងមិនមែនជាសមាជិករបស់ក្រុមប្រឹក្សាទេ។

## ១.៤. មុខងាររបស់រដ្ឋបាលស្រុក

សាលាស្រុក គឺជាការិយាល័យធ្វើការរបស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុក ដែលត្រូវបើកធ្វើការឲ្យបានទៀងទាត់តាមពេលម៉ោងធ្វើការរបស់រដ្ឋ[12]។ រដ្ឋបាលស្រុកនីមួយៗត្រូវធ្វើជាម្ចាស់ហើយ និងទទួលខុសត្រូវរាល់ការចាត់ចែងលើរាល់លិខិតស្នាម ឯកសារទាំងអស់ដែលបានទទួលត្រឹមត្រូវ ឲ្យបានស្របតាមច្បាប់ជាធរមាន។

រដ្ឋបាលស្រុកត្រូវបំពេញមុខងារតាមការកំណត់នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងមុខងារដែលបានផ្ទេរពីរាជរដ្ឋាភិបាល ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់[13]។

មុខងារពាក់ព័ន្ធនឹងការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍន៍មូលដ្ឋានក្នុងវិស័យនីមួយៗត្រូវបានប្រគល់ និងប្រតិភូកម្មទៅឲ្យរដ្ឋបាលស្រុកដូចមានកំណត់ក្នុងឧបសម្ព័ន្ធទី១នៃអនុក្រឹត្យលេខ១៨៤ អនក្រ.បកចុះថ្ងៃទី ០២ ធ្នូ ឆ្នាំ ២០១៩លើកលែងតែមុខងារក្នុងវិស័យអប់រំ យុវជន និងកីឡារបស់រដ្ឋបាលស្រុកនានាមានចែងក្នុងជំពូកទី៧នៃអនុក្រឹត្យនេះ។ មុខងារផ្តល់សេវាសាធារណៈ និងអភិវឌ្ឍមូលដ្ឋានរបស់រដ្ឋបាលស្រុករួមមានមុខងារជាកាតព្វកិច្ច និងមុខងារជាជម្រើស។រដ្ឋបាលស្រុកត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រង ការចាត់ចែង និងការអនុវត្ត មុខងារជាកាតព្វកិច្ចនានាដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ដោយផ្អែកតាមគោលការណ៍ នីតិវិធី ស្តង់ដាសេវា និងធនធានដែលបានផ្ទេរមានភ្ជាប់លក្ខខណ្ឌ ព្រមទាំងអាចប្រើប្រាស់ធនធានរបស់ខ្លួន ឬធនធានដែលកៀរគរបានពីប្រភពស្របច្បាប់ផ្សេងទៀតដើម្បីអនុវត្តមុខងារជាកាតព្វកិច្ចទាំងនោះឲ្យកាន់តែមានប្រសិទ្ធភាព។
គោលការណ៍ នីតិវិធី និងស្តង់ដាសេវាសម្រាប់គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចត្រូវរៀបចំ និងកំណត់ដោយក្រសួង ស្ថាប័ន នៃវិស័យនីមួយៗ។

រដ្ឋបាលស្រុកមានស្វ័យភាពក្នុងការសម្រេចជ្រើសរើស ឬមិនជ្រើសរើសយកមុខងារជាជម្រើសណាមួយមកអនុវត្តផ្អែកតាមតម្រូវការជាអាទិភាពរបស់ប្រជាពលរដ្ឋក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ រដ្ឋបាលស្រុកមានសិទ្ធិសម្រេចអំពីរបៀបគ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាជម្រើសដោយអនុលោមតាមបទដ្ឋាន និងនីតិវិធីដែលមានចែងក្នុងច្បាប់ ឬព្រះរាជក្រឹត្យ ឬប្រកាស ឬលិខិតបទដ្ឋានគតិយុត្តជាធរមាន។ ក្រសួង ស្ថាប័ន និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ត្រូវត្រួតពិនិត្យមើលឡើងវិញនូវមុខងារនានារបស់ខ្លួនដើម្បីបន្តផ្ទេរមុខងារសមស្របទៅឲ្យរដ្ឋបាលថ្នាក់ស្រុកស្របទៅ

---

[10] មាត្រា១៤១ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ , ២០០៨

[11] មាត្រា១៤៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ , ២០០៨

[12]សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ឆ្នាំ២០១០

[13] សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ឆ្នាំ២០១០

តាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការរបស់រាជរដ្ឋាភិបាល។

## ១.៥. ទំនាក់ទំនងរវាងក្រុមប្រឹក្សា និងគណៈអភិបាលស្រុក

ទំនាក់ទំនងរវាងក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកមានដូចខាងក្រោម៖

- អំណាចបញ្ញត្តិ និងអំណាចនីតិប្រតិបត្តិទាំងអស់ដែលក្រុមប្រឹក្សាស្រុកបានសម្រេចរួចហើយគណៈ-អភិបាលស្រុកត្រូវទទួលខុសត្រូវក្នុងការចាត់ចែងអនុវត្តក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។ដូច្នេះគណៈអភិបាលស្រុក គឺជាអ្នកអនុវត្តទាំងសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិរបស់ក្រុមប្រឹក្សាស្រុក។
- ក្រុមប្រឹក្សាស្រុក ត្រូវតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើកិច្ចការដែលអនុវត្តដោយគណៈអភិបាលស្រុកដើម្បីធានាថាគណៈអភិបាលស្រុកអនុវត្តកិច្ចការទាំងនោះបានត្រឹមត្រូវតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងការសម្រេចរបស់ក្រុមប្រឹក្សាស្រុក។
- គណៈអភិបាលស្រុកត្រូវធ្វើសេចក្តីរាយការណ៍ជូនក្រុមប្រឹក្សារបស់ខ្លួនរៀងរាល់កិច្ចប្រជុំសាមញ្ញ ឬវិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុក
- គណៈអភិបាលស្រុកត្រូវមានគណនេយ្យភាពចំពោះក្រុមប្រឹក្សាស្រុកអំពីការអនុវត្តសេចក្តីសម្រេចនានារបស់ក្រុមប្រឹក្សាស្រុក និងមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការអនុវត្តតាម រដ្ឋធម្មនុញ្ញ ច្បាប់ព្រះរាជក្រឹត្យ និងលិខិតបទដ្ឋានគតិយុត្តនានា។ អភិបាលស្រុកដោយមាននាយករដ្ឋបាលសាលាស្រុកជាជំនួយការត្រូវធ្វើសេចក្តីរាយការណ៍អំពីសកម្មភាពនិងលទ្ធភាពនៃការអនុវត្តតួនាទីជាតំណាងរាជរដ្ឋាភិបាលនិងតំណាងក្រសួង ស្ថាប័ននានាព្រមទាំងស្ថានភាពនៃការងារទាំងនោះក្នុងរបាយការណ៍ប្រចាំខែ ត្រីមាសឆមាសនិងឆ្នាំ ។
- ក្នុងករណីមានបញ្ហាណាមួយដែលពាក់ព័ន្ធដល់ការអនុវត្តតួនាទីរបស់អភិបាលស្រុកក្នុងនាមជាតំណាងរាជរដ្ឋាភិបាល និងតំណាងក្រសួង ស្ថាប័នរបស់រាជរដ្ឋាភិបាលហើយដែលមានការប៉ះពាល់ដល់ផលប្រយោជន៍ស្របច្បាប់របស់ប្រជាពលរដ្ឋ ឬមានការទាមទារតវ៉ាពីប្រជាពលរដ្ឋ ក្រុមប្រឹក្សាស្រុកអាចតម្រូវឲ្យអភិបាលស្រុកធ្វើសេចក្តីរាយការណ៍ ជាពិសេសជូនកិច្ចប្រជុំក្រុមប្រឹក្សាស្រុក។
- អភិបាលស្រុកត្រូវទទួលយកអនុសាសន៍ និងការណែនាំនានាពីក្រុមប្រឹក្សាស្រុករបស់ខ្លួនដើម្បីធ្វើការណែនាំសម្របសម្រួលនិងតម្រង់ទិសដល់ការិយាល័យ អង្គភាព និងទីភ្នាក់ងារនានារបស់ក្រសួងស្ថាប័នដែលប្រចាំនៅស្រុកក្នុងការឆ្លើយតបតម្រូវការទាំងនោះហើយត្រូវរាយការណ៍ជូនក្រុមប្រឹក្សាស្រុករបស់ខ្លួនវិញ[14]។

[14] សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ឆ្នាំ២០១០

## ១.៦. ការបង្កើតការិយាល័យប្រជាពលរដ្ឋរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ការិយាល័យប្រជាពលរដ្ឋត្រូវបានបង្កើតឡើងសម្រាប់ទទួលនឹងសម្រុះសម្រួលដោះស្រាយបណ្ដឹងនៅរដ្ឋបាលក្រុង ស្រុក ខណ្ឌនីមួយៗ[15]។ ការិយាល័យប្រជាពលរដ្ឋដឹកនាំដោយប្រធាន (០១) រូប និងមានបុគ្គលិកមួយចំនួនជាជំនួយការ។

### ១.៦.១. តួនាទី ភារកិច្ចរបស់ការិយាល័យរបស់ប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌមានភារកិច្ចដូចខាងក្រោម៖

- ប្រមូល និងទទួលពាក្យបណ្ដឹងនានានៅដែនសមត្ថកិច្ចរបស់ខ្លួន
- សម្រាំង និងវាយតម្លៃពាក្យបណ្ដឹងដែលទទួលបាន
- បញ្ជូនពាក្យបណ្ដឹងទាំងឡាយណាដែលមិនស្ថិតនៅដែនសមត្ថកិច្ចរបស់ខ្លួនទៅសមត្ថកិច្ចដែលពាក់ព័ន្ធ និងតាមដានដោះស្រាយដើម្បីបញ្ជូនព័ត៌មានទៅម្ចាស់ពាក្យបណ្ដឹង
- ចាត់វិធានការស៊ើបអង្កេតបណ្ដឹងរដ្ឋបាល លើកអនុសាសន៍អំពីវិធានការដោះស្រាយ តាមដានអនុវត្តវិធានការដោះស្រាយបណ្ដឹងដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ផ្ដល់ព័ត៌មានត្រឡប់ទៅដល់ប្រជាពលរដ្ឋអំពីលទ្ធផលនៃការដោះស្រាយពាក្យបណ្ដឹង
- ផ្សព្វផ្សាយអោយបានទូលំទូលាយអំពីយន្តការសម្រុះសម្រួលដោះស្រាយពាក្យបណ្ដឹងដែនសមត្ថកិច្ចរបស់ខ្លួន
- រៀបចំផែនការសកម្មភាព និងថវិកាប្រចាំឆ្នាំរបស់ខ្លួន
- រាយការណ៍ជាប្រចាំអំពីលទ្ធផលនឹងការដោះស្រាយពាក្យបណ្ដឹង[16]។

### ១.៦.២. សិទ្ធិអំណាចរបស់ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

ការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌមានសិទ្ធិអំណាចដូចខាងក្រោម៖

- ប្រើប្រាស់បុគ្គលិក ថវិកា សម្ភារៈ និងមធ្យោបាយនានារបស់អង្គភាពខ្លួនសម្រាប់អនុវត្តសកម្មភាពផ្អែកតាមផែនការសកម្មភាពរបស់ខ្លួនដែលទទួលការអនុម័តពីក្រុមប្រឹក្សា
- ស៊ើបអង្កេតបណ្ដឹងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់ខ្លួនតាមការចាំបាច់ព្រមទាំងលើកអនុសាសន៍អំពីវិធានការដោះស្រាយ ប៉ុន្តែពុំមានសិទ្ធិចេញសេចក្ដីសម្រេចដើម្បីចាត់វិធានការដោះស្រាយឬដាក់ទណ្ឌកម្មឡើយ
- ស្នើសុំកិច្ចសហការឬការចូលរួមពីបុគ្គលិកនៃអង្គភាពនានានៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ និងការិយាល័យអង្គភាពនានាតាមការចាំបាច់

[15] មាត្រា៣១ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

[16] មាត្រា ៣៣ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្ដីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

- កោះអញ្ជើញបុគ្គលឬប្រធានអង្គភាពនានាដែលពាក់ព័ន្ធពាក្យបណ្តឹងឱ្យចូលមកបំភ្លឺតាមការចាំបាច់
- ពិនិត្យមើលឯកសារ និងវត្ថុតាងផ្សេងៗដែលពាក់ព័ន្ធបណ្តឹងនៅតាមអង្គភាពនានាដោយពុំចាំបាច់ជូនដំណឹងជាមុន និងដកហូតឯកសារនិងវត្ថុតាងទាំងនោះមករក្សាទុកតាមការចាំបាច់
- រាយការណ៍ជូនអភិបាលក្រុង ស្រុក ខណ្ឌ ឬមេឃុំចៅសង្កាត់អំពីការមិនសហការក្នុងការស៊ើបអង្កេតរបស់ប្រធានអង្គភាព និងបុគ្គលដែលពាក់ព័ន្ធពាក្យបណ្តឹង និងការមិនចាត់វិធានការដោះស្រាយពាក្យបណ្តឹងនានាដែលពាក់ព័ន្ធអង្គភាពនោះ[17]។

### ១.៦.៣. លក្ខខណ្ឌ និងលក្ខណសម្បត្តិបេក្ខជនសម្រាប់ឈរឈ្មោះបោះឆ្នោតជាប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ

ប្រជាពលរដ្ឋដែលមានបំណងឈរឈ្មោះជាបេក្ខជនប្រធានការិយាល័យក្រុង ស្រុក ខណ្ឌ ត្រូវដាក់ពាក្យមកសុំគណៈកម្មាធិការបោះឆ្នោតជ្រើសរើសប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។

បេក្ខជនជាស្ត្រី ជនជាតិដើមភាគតិច ជនពិការ ត្រូវបានផ្តល់អាទិភាព និងលើកទឹកចិត្តនៅក្នុងការដាក់ពាក្យសុំឈរឈ្មោះជាបេក្ខជនប្រធានការិយាល័យប្រជាពលរដ្ឋក្រុង ស្រុក ខណ្ឌ។ ប្រជាពលរដ្ឋទាំងពីរភេទដែលមានបំណងឈរឈ្មោះជាបេក្ខជន ត្រូវបំពេញតាមលក្ខខណ្ឌ និងមានលក្ខណសម្បត្តិដូចខាងក្រោម៖

- មានសញ្ជាតិខ្មែរពីកំណើត
- មានអាយុចាប់ពី ៣៥ឆ្នាំ ទៅដល់ ៦៥ឆ្នាំ គិតដល់ថ្ងៃបោះឆ្នោត
- មានសញ្ញាបត្រចាប់ពីមធ្យមសិក្សាទុតិយភូមិ ឬសញ្ញាបត្រសមមូល
- មានបទពិសោធក្នុងការងារពាកព័ន្ធផ្នែកច្បាប់ ឬរដ្ឋបាល ឬការងារផ្សេងទៀតដែលពាក់ព័ន្ធនឹងការដោះស្រាយវិវាទយ៉ាងតិច ៣ឆ្នាំ
- ជាបុគ្គលស្អាតស្អំ មានកេរ្តិ៍ឈ្មោះល្អ មានការគោរពរាប់អានពីសហគមន៍របស់ខ្លួន
- មានទីលំនៅអចិន្ត្រៃយ៍នៅក្នុងក្រុង ស្រុក ខណ្ឌដែលមានសាមីជនចង់ចុះឈ្មោះ[18]។

អ្នកដែលគ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនប្រធានការិយាល័យក្រុង ស្រុក ខណ្ឌ៖

- មន្ត្រីរាជការ មន្ត្រីតុលាការ កងយោធពលខេមរភូមិន្ទ ឬនគរបាលជាតិ
- សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់
- ព្រះសង្ឃ ឬបុព្វជិតសាសនា
- ជនដែលត្រូវបានផ្តន្ទាទោសពីបទមជ្ឈឹម ឬឧក្រិដ្ឋ ហើយមិនមាននីតិសម្បទាឡើងវិញ

[17] មាត្រា ៣៥ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

[18] មាត្រា ៣៦ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– ជនដែលស្ថិតក្នុងរចនាសម្ព័ន្ធគណបក្សនយោបាយចាត់តាំងណាមួយ[19]។

## ១.៧. ទំនាក់ទំនងរវាងរដ្ឋបាលស្រុក ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព

ទំនាក់ទំនងរវាងរដ្ឋបាលស្រុក ជាមួយក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ស្ថាប័នរបស់រាជរដ្ឋាភិបាលរួមមាន៖

- ក្រុមប្រឹក្សាស្រុកត្រូវស្ថិតក្នុងក្របខ័ណ្ឌនៃអំណាចប្រតិបត្តិរបស់ជាតិ។ អំណាចប្រតិបត្តិរបស់រាជរដ្ឋាភិបាលមានសិទ្ធិណែនាំ និងត្រួតពិនិត្យនីត្យានុកូលភាពនៃការសម្រេច និងការធ្វើសកម្មភាពរបស់ក្រុមប្រឹក្សា ដើម្បីធានាឲ្យបានថាក្រុមប្រឹក្សាគោរពយ៉ាងត្រឹមត្រូវនូវធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ។
- ក្នុងការអនុវត្តការងារប្រចាំថ្ងៃ គណៈអភិបាលខេត្តគឺជាខ្សែរយៈទំនាក់ទំនងទៅវិញទៅមករវាងរាជរដ្ឋាភិបាលក្រសួងស្ថាប័ននានានៃរាជរដ្ឋាភិបាលជាមួយរដ្ឋបាលស្រុក ព្រមទាំងការគាំទ្រដល់រដ្ឋបាលស្រុកក្នុងខេត្ត។
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព អាចធ្វើទំនាក់ទំនង និងកិច្ចសហការដោយផ្ទាល់ជាមួយរដ្ឋបាលស្រុកតាមការចាំបាច់ប៉ុន្តែត្រូវជូនដំណឹងដល់រដ្ឋបាលខេត្ត
- ក្រសួងមហាផ្ទៃ ត្រូវធ្វើការសម្របសម្រួលដោះស្រាយស្របតាមច្បាប់ និងលិខិតបទដ្ឋានគតិយុតិនានា នៅពេលមានភាពមិនចុះសម្រុងគ្នារវាងរដ្ឋបាលខេត្តជាមួយរដ្ឋបាលស្រុក
- គ.ជ.អ.ប ត្រូវសម្របសម្រួលដោះស្រាយផ្អែកតាមច្បាប់ និងលិខិតបទដ្ឋានគតិយុត្តនានា នៅពេលមានភាពមិនចុះសម្រុងគ្នារវាងក្រសួងស្ថាប័ននានារបស់រាជរដ្ឋាភិបាលជាមួយក្រុមប្រឹក្សាស្រុកក្នុងខេត្ត
- ក្រុមប្រឹក្សាខេត្តត្រូវធានាឲ្យមានការពិគ្រោះយោបល់សមស្របជាមួយរដ្ឋបាលស្រុកក្នុងខេត្តសម្រាប់ជាមូលដ្ឋានក្នុងការពិគ្រោះពិភាក្សាជាមួយ គ.ជ.អ.ប និងក្រសួង ស្ថាប័ននានាអំពីការបែងចែកមុខងារ ធនធានទ្រព្យសម្បត្តិ ការគ្រប់គ្រង និងការកៀងគរចំណូល ព្រមទាំងការកែសម្រួលឡើងវិញនូវបុគ្គលិកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- ផ្អែកតាមការសម្រេចរបស់ គ.ជ.អ.ប ក្រុមប្រឹក្សាខេត្តត្រូវធានាធ្វើការសម្របសម្រួលជាមួយរដ្ឋបាលស្រុកដើម្បីបែងចែកមុខងារ ធនធាន ទ្រព្យសម្បត្តិ ការគ្រប់គ្រង និងការកៀងគរចំណូលព្រមទាំងបុគ្គលិកឲ្យបានសមស្របតាមស្ថានភាពជាក់ស្តែងនៃតំបន់នីមួយៗ រួមទាំងតំបន់ប្រជុំជន និងតំបន់ជនបទក្នុងខេត្ត
- ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព នានាត្រូវចូលរួម និងគាំទ្រយ៉ាងសកម្មចំពោះដំណើរការនៃការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យតាមរយៈនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៅថ្នាក់ស្រុក។
- ក្រសួង ស្ថាប័ននីមួយៗ ត្រូវធ្វើការប្រគល់ និងធ្វើប្រតិភូកម្មមុខងារ ភារកិច្ចសមស្រប ដោយភ្ជាប់ជាមួយនូវធនធានហិរញ្ញវត្ថុ បុគ្គលិក និងសមត្ថភាពទៅឲ្យក្រុមប្រឹក្សាស្រុក។
- ក្រសួង ស្ថាប័ន នានាត្រូវទទួលខុសត្រូវក្នុងការកំណត់គោលនយោបាយសម្រាប់វិស័យរបស់ខ្លួនទូទាំង

---

[19] មាត្រា ៣៧ នៃអនុក្រឹត្យលេខ១៩ អនក្រ.បក ស្តីពីការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

ប្រទេសការដាក់ចេញលិខិតបទដ្ឋានគតិយុត្ត ដើម្បីកំណត់អំពីបែបបទ នីតិវិធីសម្រាប់ក្រុមប្រឹក្សាស្រុក អនុវត្តមុខងារដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម[20]។

## ១.៨ ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលខេត្ត

ក្រៅពីទំនាក់ទំនងនានាដែលបានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាខេត្ត គណៈអភិបាលខេត្ត ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក រដ្ឋបាលខេត្ត រដ្ឋបាលស្រុកនៅមានទំនាក់ទំនងមួយចំនួនទៀតដូចជា៖

- ក្រុមប្រឹក្សាខេត្តត្រូវសហការជាមួយក្រុមប្រឹក្សាស្រុកក្នុងខេត្តរបស់ខ្លួនដើម្បីពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំក្នុងខេត្តរបស់ខ្លួនក្នុងគោលបំណងឆ្លើយតបតម្រូវការចាំបាច់របស់ក្រុមប្រឹក្សាឃុំ។
- គណៈអភិបាលខេត្ត គណៈអភិបាលស្រុក មានភារកិច្ចអនុវត្តកិច្ចការប្រចាំថ្ងៃក្នុងការការទំនាក់ទំនងទៅវិញទៅមករវាងខេត្ត ស្រុក ក្នុងនាមក្រុមប្រឹក្សារបស់ខ្លួន។
- ក្រុមប្រឹក្សាខេត្តត្រូវបានទទួលការធ្វើប្រតិភូកម្មអំណាចក្នុងនាមរាជរដ្ឋាភិបាលដើម្បីផ្តល់ការគាំទ្រនិងការត្រួតពិនិត្យនីត្យានុកូលភាពលើសេចក្តីសម្រេច និងសកម្មភាពរបស់រដ្ឋបាលស្រុក ដើម្បីធានាថារដ្ឋបាលស្រុកបំពេញមុខងារ ភារកិច្ច ដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងស្របតាមគោលនយោបាយរបស់ជាតិ។ ការធ្វើប្រតិភូកម្មរួមមាន៖
  - ការវាយតម្លៃ និងការរៀបចំយុទ្ធសាស្ត្រសមស្របសម្រាប់ផ្តល់ការគាំទ្រខាងសមត្ថភាពដល់ក្រុមប្រឹក្សាស្រុកព្រមទាំងមន្ត្រីបុគ្គលិកនៃក្រុមប្រឹក្សាស្រុក។
  - ការណែនាំ និងសម្របសម្រួលគាំទ្រដល់ក្រុមប្រឹក្សាស្រុកក្នុងការអនុវត្តមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ឲ្យស្របទៅតាមច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយជាតិ
  - ត្រូវធានាថាស្រុកបានធ្វើការគាំទ្រយ៉ាងត្រឹមត្រូវដល់ឃុំក្នុងស្រុក
- ក្រុមប្រឹក្សាខេត្តត្រូវបំពេញតួនាទីខាងលើនេះលើមូលដ្ឋាននៃការធានាស្វ័យភាពរបស់ស្រុកឲ្យស្របតាមគោលការណ៍នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ និងច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ច្បាប់ អនុក្រឹត្យ លិខិតបទដ្ឋានគតិយុត្តនានាព្រមទាំងការសម្រេចរបស់ គ.ជ.អ.ប។
- ក្រុមប្រឹក្សាខេត្តត្រូវបានទទួលប្រតិភូកម្មពីរាជរដ្ឋាភិបាលដើម្បីផ្តល់ការគាំទ្រ ការសម្របសម្រួល និងការធ្វើសហប្រតិបត្តិការជាមួយរដ្ឋបាលស្រុក ដើម្បីរួមគ្នាសម្រេចឲ្យបាននូវគោលនយោបាយជាតិ។
- ក្រុមប្រឹក្សាខេត្តត្រូវធានាថារដ្ឋបាលស្រុកក្នុងខេត្ត បំពេញមុខងារ ភារកិច្ចដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្មឲ្យស្របទៅតាមរដ្ឋធម្មនុញ្ញ ច្បាប់ លិខិតបទដ្ឋានគតិយុត្តនានា និងគោលនយោបាយរបស់ជាតិ។
- ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ ដែលមានព្រំប្រទល់ជាប់គ្នាត្រូវធ្វើ

[20] សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ឆ្នាំ២០១០

ទំនាក់ទំនងកិច្ចសហប្រតិបត្តិការ និងការពិគ្រោះយោបល់ និងធ្វើការសម្របសម្រួលជាមួយគ្នាលើមុខងារ ភារកិច្ចមួយ ឬច្រើន និងបញ្ហានានា ដែលមានការពាក់ព័ន្ធគ្នា។

## ១.៩ ទំនាក់ទំនងរវាងរដ្ឋបាលស្រុកជាមួយរដ្ឋបាលឃុំ សង្កាត់ក្នុងស្រុក

ក្រៅពីទំនាក់ទំនងនានាដែលបានកំណត់ក្នុងតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក រដ្ឋបាលស្រុកនៅមានទំនាក់ទំនងមួយចំនួនទៀតជាមួយរដ្ឋបាលឃុំ រដ្ឋបាលសង្កាត់ដូចជា៖

*ការគាំទ្ររបស់រដ្ឋបាលស្រុកចំពោះរដ្ឋបាលឃុំ សង្កាត់*

- ដើម្បីបង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ ក្រុមប្រឹក្សាស្រុកត្រូវ៖
  - ជួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុកឲ្យបង្កើត ជំរុញ និងធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
  - រួមជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក ដើម្បីជំរុញឱ្យមានការចូលរួមពីសាធារណជនក្នុងដំណើរការអភិបាលកិច្ចនៅក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក
  - ស្វែងយល់ និងឆ្លើយតបចំពោះតម្រូវការក្នុងស្រុករបស់ខ្លួន និងចំពោះសំណើរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុក។
- ដើម្បីឲ្យក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ក្នុងស្រុកមានសមត្ថភាពគ្រប់គ្រាន់ក្នុងការទទួលបានមុខងារ និងធនធានកាន់តែច្រើន ក្រុមប្រឹក្សាស្រុកត្រូវពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ពាក់ព័ន្ធដើម្បី៖
  - វាយតម្លៃសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់នីមួយៗយ៉ាងហោចណាស់១ឆ្នាំម្តង
  - ធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាពដល់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់ និងបុគ្គលិករបស់ក្រុមប្រឹក្សាឃុំ ក្រុមប្រឹក្សាសង្កាត់
  - អប់រំ ផ្សព្វផ្សាយអំពីអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ និងវិមជ្ឈការ វិសហមជ្ឈការដល់ប្រជាពលរដ្ឋដើម្បីលើកកម្ពស់ការចូលរួមរបស់ប្រជាពលរដ្ឋក្នុងដំណើរការអភិបាលកិច្ចក្នុងស្រុក និងឃុំ សង្កាត់ក្នុងស្រុក។
  - ផ្អែកលើការវាយតម្លៃសមត្ថភាព និងការពិគ្រោះយោបល់ជាមួយក្រុមប្រឹក្សាឃុំ សង្កាត់ ក្រុមប្រឹក្សាស្រុកត្រូវសម្របសម្រួល និងគាំទ្រដល់ការបង្កើនសមត្ថភាពផ្នែករដ្ឋបាលធនធានផ្នែករដ្ឋបាលដែលចាំបាច់ដល់ក្រុមប្រឹក្សាឃុំ សង្កាត់ សំដៅធានាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ មានសមត្ថកិច្ច [21]។

## ១.១០ របបហិរញ្ញវត្ថុរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ក្រុមប្រឹក្សានៅថ្នាក់ក្រោមជាតិត្រូវមានធនធានហិរញ្ញវត្ថុសមស្របដើម្បី៖

[21] សៀវភៅណែនាំ ស្តីពី តួនាទី និងរបៀបរបបការងាររបស់រដ្ឋបាលស្រុក ឆ្នាំ២០១០

- គ្រប់គ្រង ចាត់ចែង និងអនុវត្តមុខងារជាកាតព្វកិច្ចរបស់ខ្លួន
- ធ្វើការជ្រើសរើសក្នុងការគ្រប់គ្រង ចាត់ចែងនិងអនុវត្តមុខងារជាជម្រើសរបស់ខ្លួន
- អនុវត្តតួនាទី ភារកិច្ចតាមច្បាប់ដែលកំណត់
- ចំណាយផ្នែករដ្ឋបាលរបស់ខ្លួន
- អនុវត្តមុខងារ ភារកិច្ច សម្រាប់ជំរុញដល់ការអនុវត្តតាមបែបប្រជាធិបតេយ្យក្នុងដែនសមត្ថកិច្ចរបស់ខ្លួន

### ១.១០.១ ប្រភពចំណូល

ក្រុមប្រឹក្សាមានសិទ្ធិទទួលបានចំណូលពីប្រភពនៅមូលដ្ឋាន ពីប្រភពនៅថ្នាក់ជាតិ និងប្រភពផ្សេងៗទៀត ដោយអនុលោមតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលរៀបចំឡើងស្របតាមច្បាប់នេះ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

- ប្រភពចំណូលមូលដ្ឋានរួមមាន៖
  - ពន្ធនៅមូលដ្ឋាន
  - ឈ្នួល កម្រៃ និងចំណូលមិនមែនសារពើពន្ធផ្សេងៗ
  - ចំណូលរបស់ក្រុមប្រឹក្សាស្រុកបានមកពីពន្ធ ឈ្នួល និងកម្រៃដែលត្រូវចែករំលែករវាងក្រុមប្រឹក្សាស្រុកជាមួយក្រុមប្រឹក្សាឃុំ និងក្រុមប្រឹក្សាសង្កាត់ក្នុងស្រុក
  - អំណោយស្ម័គ្រចិត្ត
  - ប្រភពផ្សេងៗទៀតដែលបានកំណត់ដោយច្បាប់ឬអនុក្រឹត្យពីដំណាក់កាលមួយទៅដំណាក់កាលមួយទៀត[22]។
- ចំណូលពីថ្នាក់ជាតិរួមមាន៖
  - ចំណូលចែករំលែក
  - មូលនិធិផ្ទេរពីថវិការរដ្ឋ និង
  - ចំណូលថ្លៃសេវាបានមកពីមុខងារភ្នាក់ងារដែលអនុវត្តដោយក្រុមប្រឹក្សាក្នុងនាមក្រសួង[23]

[22] មាត្រា២៥៧ នៃច្បាប់និងច្បាប់ស្តីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

[23] មាត្រា២៥៨នៃច្បាប់និងច្បាប់វិសោធនកម្មស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ

# ជំពូក ២
# ស្ថានភាពនៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់

## ២.១. ស្ថានភាពទីតាំងភូមិសាស្ត្រ និងប្រជាសាស្ត្រ

### ២.១.១. ស្ថានភាពទីតាំងភូមិសាស្ត្រ

ស្រុកមេមត់ ជាស្រុកមួយដែលមានផ្ទៃដីសរុប ១៦០.១៣០ហ.ត ឬ ១៦០១,៣០ គម² [24]។ នៅស្រុកមេមត់មាន ១៤ឃុំ ស្មើ១៨០ភូមិ ក្នុងនោះភូមិ១ ស្ថិតក្នុងទឹកដីវៀតណាម។ ព្រំប្រទល់របស់ស្រុកមេមត់ខាងជើងជាប់ស្រុកឆ្លូង និងស្រុកស្នួល ខាងកើតនិងខាងត្បូងជាប់នឹងប្រទេសវៀតណាមប្រវែង ១០១ គ.ម ២ខេត្តគឺ ខេត្តប៊ិញហ្វឿក និងខេត្តតៃនិញ។ ចំណែកឯខាងលិចជាប់ស្រុកពញាក្រែក និងស្រុកតំបែរ។

### ២.១.២. ស្ថានភាពប្រជាសាស្ត្រ

នៅស្រុកមេមត់មានប្រជាពលរដ្ឋសរុប ១៥៧ ,១៦៦ នាក់ ស្រី ៧៩,៩៨០នាក់ ស្មើនឹង ៣៣,០៨៩គ្រួសារក្នុងនោះប្រជាពលរដ្ឋអាយុ១៨ឆ្នាំឡើងទៅមាន ៨៨ ៨៥៩នាក់ ស្រី ៤៥ ៨៨៦នាក់[25]។ ប្រជាពលរដ្ឋដែលរស់នៅទីនោះ ៨៧.៧០%ជាកសិករ។

## ២.២. ស្ថានភាពសេដ្ឋកិច្ច

### ២.២.១. វិស័យកសិកម្ម

ស្រុកមេមត់មានផ្ទៃដីសរុប ១៦០.១៣០ ហ.ត ឬ ១៦០១,៣០ គ.ម² ចែកចេញជា១៤ ឃុំ និង១៨០ ភូមិផ្ទៃដីរួមទាំងអស់ត្រូវបានបែងចែកធ្វើកសិកម្មរួមមាន ផ្ទៃដីស្រែវស្សា ៧ ៣៤០ ហ.ត ផ្ទៃដីស្រែប្រាំង ៥០០ហត ផ្ទៃដីចំការ ៦៥ ៦៧០ ហ.ត[26] ។ ផ្ទៃដីចំការត្រូវបានបែងចែកជា ចំការកៅស៊ូរដ្ឋ ៨ ៥៦៥ ហ.ត ចំការកៅស៊ូគ្រួសារ ១៥ ៣២០ ហ.ត ចំការសណ្តែកសៀង ៦៨០ហ.ត ចំការសណ្តែកបាយ ៥៣០ ហ.ត ចំការម្រេច ២.៤៦០ ហ.ត ចំការសណ្តែកដី ៣០ ហ.ត ចំការស្វាយចន្ទី ១៨០៧ ហ.ត ចំការស្វាយកែវល្មៀត ១១៤ ហ.ត ចំការធុរេន មង្ឃុត សាម៉ាវ ៦២៧ ហ.ត ចំការពោត ៥៩០ ហ.ត ចំការដំឡូងមី ១៩ ៩៨០ ហ.ត ចំការអំពៅ ២០ ហ.ត[27]។

### ២.២.២. វិស័យឧស្សាហកម្ម និងសិប្បកម្ម

ទោះបីក្នុងស្រុកពុំទាន់មានមូលដ្ឋាន ឧស្សាហកម្ម សិប្បកម្ម រោងចក្រ សហគ្រាស ដែលមានទ្រង់ទ្រាយធំក្តី តែយើងមានមូលដ្ឋានសិប្បកម្មអាជីវកម្ម និង សេវាកម្មនានាទូទាំងស្រុកនៅមាន ចំនួន១៧ កន្លែង ក្នុងនោះមាន សិប្បកម្មទឹកកក ចំនួន០២កន្លែង គឺសិប្បកម្មទឹកកករបស់លោក តាំង ម៉ូវស៊ីម នៅភូមិម៉ាស៊ីនទឹក ឃុំមេមត់ និងសិប្បកម្មទឹកកករបស់លោក តាំង សុខចេង នៅភូមិសង្គមមានជ័យ ឃុំមេមត់។ សិប្បកម្មទឹកបរិសុទ្ធមាន០១កន្លែង ជារបស់លោក តាំង បេងលាប នៅភូមិត្បូងវត្ត ឃុំមេមត់ ។ រោងចក្រម្សៅដំឡូងមី ធីធីវាយ របស់លោកឧកញ៉ា ម៉ាឌី

---

[24] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ (២០១៤-២០១៨)

[25] សៀវភៅស្តីពីការធ្វើជំរឿនប្រជាពលរដ្ឋនៅស្រុកមេមត់ ឆ្នាំ ២០១៩

[26] សៀវភៅស្តីពី វិស័យសំខាន់ៗដែលមាននៅស្រុកមេមត់ ឆ្នាំ២០១៦

[27] សៀវភៅស្តី វិស័យសំខាន់ៗដែរលមាននៅក្នុងស្រុកមេមត់ ឆ្នាំ២០១៦

នៅភូមិជីប៉េះ ឃុំមេមត់ ។ សិប្បកម្មផលិត នំបុ័ងរបស់លោកស្រី យ៉ង ស៊ីម នៅភូមិម៉ាស៊ីនទឹក ឃុំមេមត់ ។ រោងចក្រកែច្នៃជ័រ កៅស៊ូក្រែបមាន០៥កន្លែង នៅភូមិចំការគ ក្នុងឃុំទ្រៀក ភូមិកំពាន់ ក្នុងឃុំកំពាន់ ភូមិព្រៃកពួយ ក្នុងឃុំគគីរ ភូមិខ្នងក្រពើ ក្នុងឃុំត្រមូង និងនៅភូមិម្រាន់ ក្នុងឃុំជាំក្រវៀន ។ លើសពីនេះមានសិប្បកម្មកែច្នៃម្រេចខ្មៅទៅជាម្រេចស របស់លោកស្រី ឆាយ ស នៅភូមិដារផ្សារ ឃុំដារ ស្រុកមេមត់ ។ ជាងនេះក៏មានរោងចក្រកាត់ដេរមួយកន្លែង(មិនដំណើរការ) នៅភូមិដារផ្សារ ឃុំដារ ស្រុកមេមត់។ បន្ថែមពីនេះក៏មានរោងចក្រម៉ាស៊ីនកិនស្រូវមួយកន្លែង របស់លោក លី សេងនៅភូមិត្បូងវត្ត ឃុំ មេមត់ ។ ការងារថាមពលអគ្គិសនីមានបីកន្លែង មាននៅភូមិគគីរ ឃុំគគីរ ភូមិក្តុល ផ្សារ ក្នុងឃុំទន្លូង និងនៅភូមិក្រវៀនធំ ក្នុងឃុំជាំក្រវៀន ស្រុកមេមត់ ។

## ២.៣. ស្ថានភាពសង្គមកិច្ច

### ២.៣.១. វិស័យអប់រំ

ក្នុងស្រុកមេមត់គ្រប់ភូមិសិក្សាបានផ្តល់ឱកាសអោយយុវជន និងកុមារបានចូលរៀនសូត្រ និងប្រកបដោយគុណភាព។ សម្រាប់វិស័យអប់រំនៅក្នុងស្រុកមេមត់មានអគារសិក្សារដ្ឋសរុបទាំងអស់១១៩កន្លែង ស្មើនឹង១៦៤ខ្នង និង៨០៧ បន្ទប់ក្នុងនោះមាន វិទ្យាល័យ០៣ កន្លែង<<ដារ មេមត់ ទន្លូង>> អនុវិទ្យាល័យ១៣ កន្លែង ( ក្រវៀន ជាំ ចាន់មូល ទ្រៀក រំចេក កំពាន់ គគីរ មេមង ជាំតាម៉ៅ ត្រមូង និងដារពីរកន្លែង)[28]។ ចំណែកបឋមសិក្សាមាន១០២ កន្លែង មត្តេយ្យដាច់ ០១កន្លែង មត្តេយ្យក្នុងបឋម៤៨កន្លែង។ សម្រាប់អគារសិក្សាវិស័យឯកជនមានសរុប ០៥កន្លែង ស្មើនឹង ០២ខ្នង មានដូចជា សាលាអន្តរជាតិអូស្ត្រាលី ០១កន្លែង សាលាអន្តរជាតិអ៊ីហ្វេន ០១ កន្លែង។ អគារសិក្សាដែលជាអំណោយរបស់ សម្តេច តេជោ ហ៊ុនសែន និងសម្តេចកិត្តិព្រឹទ្ធបណ្ឌិត នៅឆ្នាំ២០១៥មានចំនួន៨៣ខ្នង ២៦៤បន្ទប់។ នៅឆ្នាំ២០១៦ សម្តេច តេជោ ហ៊ុនសែនបានផ្តល់អំណោយអគារសិក្សានៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន ទន្លូង ២ខ្នង ២ជាន់ ១២ បន្ទប់ អគារស្នាក់នៅរបស់លោកគ្រូ អ្នកគ្រូ ១ខ្នង ២ជាន់ ១០បន្ទប់ និងអគារស្នាក់នៅរបស់សិស្សនៅវិទ្យាល័យ ប៊ុនរ៉ានី ហ៊ុនសែន មេមត់ ២ខ្នង ២ជាន់ ២៤បន្ទប់ ។

### ២.៣.២. វិស័យសុខាភិបាល

នៅស្រុកមេមត់មានការិយាល័យស្រុកប្រតិបត្តិ ០១កន្លែង មន្ទីរពេទ្យបង្អែក ០១កន្លែង មណ្ឌលសុខភាព ១៣ កន្លែង ប៉ុស្តិ៍សុខភាព ០១កន្លែង មណ្ឌលសុខភាពសង់ថ្មី ០២កន្លែង ស្ថិតនៅឃុំគគីរ ០១កន្លែង និង ឃុំរូង ០១កន្លែង កំពុងសាងសង់។ ការិយាល័យស្រុកប្រតិបត្តិមានបុគ្គលិក ១៨៤នាក់ ស្រី៦២នាក់[29] ។

### ២.៣.៣. ស្ថានភាពយេនឌ័រ

ស្រុកមេមត់បានរៀបចំរចនាសម្ព័ន្ធ ដែលមានស្ត្រីក្នុងសមាជិកក្រុមប្រឹក្សាស្រុកចំនួន ០៤ នាក់សមាសភាពគណៈអភិបាលចំនួន ០១នាក់ និង បុគ្គលិកការិយាល័យចំណុះចំនួន ០៦ នាក់ ។ ស្ត្រីជាមេគ្រួសារមាន ៣.១៥៨

[28] សៀវភៅស្តីពីវិស័យសំខាន់ៗដែលមាននៅក្នុងរដ្ឋបាលស្រុកមេមត់ ឆ្នាំ ២០១៦

[29] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ (២០១៤-២០១៨)

គ្រួសារ (១៤,៨១%)[30] ទោះជាយ៉ាងនេះក៏ដោយក៏នៅមានជួបប្រទះដូចជាអំពើហឹង្សាក្នុងគ្រួសារស្ត្រីមួយចំនួនមិនសូវយកចិត្តទុកដាក់លើការចូលរួមធ្វើសេចក្តីសំរេចចិត្តដោយសមត្ថភាពចំណេះដឹងការទទួលយកនូវមានកំរិតនៅឡើយពុំសូវបានឱកាសចូលរួមក្នុងការងារសង្គមដោយជាប់រវល់កិច្ចការផ្ទះច្រើន។

### ២.៣.៤. ស្ថានភាពនៃភាពក្រីក្រ

ស្ថានភាពភាពក្រក្រីក្នុងស្រុកស្រុកមេមត់ត្រូវបានកាត់បន្ថយជាបណ្តើរៗ ពីមួយឆ្នាំទៅមួយឆ្នាំដោយផ្អែកលើសូចនាករ ដូចជាគ្រួសារមានផ្ទះស្លឹក គ្រួសារមានម៉ូតូ គ្រួសារមានទូរទស្សន៍ និងជនរងគ្រោះ និងមានមូលហេតុជាច្រើនដែលនាំឱ្យភាពក្រក្រីថយចុះដូចជា ការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធជនបទ ផ្លូវលំជនបទ ប្រព័ន្ធស្រោចស្រព និងបានទទួល នូវការបណ្តុះបណ្តាល ការណែនាំការផ្សព្វផ្សាយ ការធ្វើបង្ហាញពីបច្ចេកទេសដាំដុះ និងការចិញ្ចឹមសត្វដែលបានរួមចំណែកដល់ការកាត់បន្ថយភាពក្រក្រី។ ទោះបីមានវឌ្ឍនភាពក្នុងការកាត់បន្ថយភាពក្រក្រីយ៉ាងណាក្តីក៏នៅមានការងារជាអាទិភាពមួយចំនួនទៀតដែលត្រូវអនុវត្តបន្ត ដូចជាការធ្វើឱ្យប្រសើរឡើងនូវជីវភាពនៃក្រុមជនរង-គ្រោះដូចនេះទាមទារអោយមានការយកចិត្តទុកដាក់ក្នុងការជួយដល់ក្រុមនេះជាបន្តទៀត។

### ២.៣.៥. ស្ថានភាពសាសនា

វត្តទូទាំងស្រុកមេមត់មានសរុបចំនួន ៣៧ វត្ត ក្នុងនោះមានអាស្រម ០៣[31]។ ព្រះសង្ឃសរុបមានចំនួន ២០៦ អង្គ ក្នុងនោះ គណៈធម្មយុត្ត ១០ អង្គ ភិក្ខុ០៥ សាមនេរ ០៥អង្គ ចំណែកឯមហានិកាយមាន ភិក្ខុ ៩៥អង្គ សាមនេរ ២៤៨អង្គ ។ សាសនាមានសរុបទាំងអស់០៤ មានដូចជា សាសនាព្រះពុទ្ធ ៣៧វត្ត សាសនាឥស្លាម១៨ និងស្វ៉ារ ២៨ សាសនាគ្រឹះ ០៣ ឃុំមេមត់ និង ឃុំត្រមូង ០៣ សាសនាចិន ០១ <<ឃុំមេមត់ មហាយាន>>។ សាលាពុទ្ធិកៈមាន ០២កន្លែង គឺ វត្តមេមត់ ០១កន្លែង និងវត្តជារ ០១កន្លែង។ កន្លងមកនេះយើងមានជួបបញ្ហាខ្លះៗ ដូចជាតាមវត្តមួយចំនួនកើតមានអធិករណ៍ និង ការសាមគ្គីរវាងព្រះសង្ឃ និង គណៈកម្មការវត្តពុំទាន់បានល្អប្រសើរ និង ការគោរពធម៌វិន័យរបស់ព្រះសង្ឃនៅពុំទាន់បានល្អទេនេះជាបញ្ហានាំអោយប្រជាពលរដ្ឋបាត់បង់ជំនឿទៅលើព្រះពុទ្ធសាសនា។

### ២.៣.៦. ការរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកមេមត់

**+ ករណីដីវិវាទដែលបានដោះស្រាយរួច**

ដីទំនាស់រវាងឧកញ៉ាម្នាក់ ជាមួយប្រជាពលរដ្ឋចំនួន ២៥ គ្រួសារ ស្មើនឹង ២៧ ក្បាលដីស្មើនឹង៤៨ ហ.ត[32] ត្រូវបានដោះស្រាយចប់សព្វគ្រប់នៅដោយបានប្រគល់ប័ណ្ណកម្មសិទ្ធិជូនរួចរាល់អស់ហើយ។

**+ករណីទំនាស់កំពុងដំណើរការដោះស្រាយ**

ដីខ្ទងក្រពើលិច-កើត ដែលមានប្រជាពលរដ្ឋ ៦៣៥គ្រួសារ ស្នើសុំកម្មសិទ្ធិនៅនឹងកន្លែង លើផ្ទៃដី ៥១ហ.ត << កំពុងដំណើរការបិទផ្សាយទិន្នន័យក្បាលដី >> ។ មួយទៀតដីទំនាស់រវាងប្រជាពលរដ្ឋ ៦៤៣គ្រួសារស្មើ

[30] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ (២០១៤-២០១៨)

[31] សៀវភៅស្តីពីវិស័យនានាក្នុងស្រុកមេមត់ ឆ្នាំ២០១៦

[32] សៀវភៅស្តីពីវិស័យនានាក្នុងស្រុកមេមត់ ឆ្នាំ២០១៦

នឹង ៦៥៧ ក្បាលដីស្មើនឹង១៩៧០ ហ.តជាមួយក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចរបស់បុគ្គលម្នាក់នៅភូមិចង្កំកណ្តាល ឃុំទន្លូង និង ភូមិថ្មរតាដោក ឃុំក្រវៀន ស្រុកមេមត់។

+**ករណីទំនាស់ និងសំណូមពរមិនទាន់បានដោះស្រាយ**

ដីទំនាស់នៅភូមិកំបាល់ ឃុំមេមង រវាងប្រជាពលរដ្ឋ១៤គ្រួសារ ជាមួយនឹងម្ចាស់ដី ៤ គ្រួសារ លើផ្ទៃដីចំនួន ២០ ហ.ត ស្មើនឹង១៨ក្បាលដី ( កើតឡើងពេលអនុវត្តបទបញ្ជាលេខ ០១បប )។ ដីទំនាស់ ១២០០ ហ.ត ដែលបទបញ្ជា ០១ បានចុះវាស់វែងហើយចំនួន ៤១១គ្រួសារ នៅភូមិចង្កំកណ្តាល ឃុំទន្លូង និងភូមិថ្មតោក ឃុំក្រវៀន តែមានប្រជាពលរដ្ឋ ១៧៣ គ្រួសារនៅឃុំទន្លូង ប្តឹងទាស់មិនអោយចេញប័ណ្ណកម្មសិទ្ធិ។ ដីទាស់ចំណតរថយន្តមេមត់ ពាក់ព័ន្ធប្រជាពលរដ្ឋប្រមាណ២០គ្រួសារកំពុងរស់នៅលើដីចំណតរថយន្ត។

**២.៣.៧. ការខាររ៉ែ និងថាមពលក្នុងស្រុកមេមត់**

+ **ការខារអគ្គិសនី:** ការចែកចាយផ្គត់ផ្គង់អគ្គិសនីមាន៤ សេវាករ[33] ៖

**១ អគ្គិសនីកំពង់ចាម សាខាមេមត់:** តម្លៃលក់ជូនអតិថិជន ៦៥០រៀល ក្នុងមួយគីឡូវ៉ាត់ម៉ោង ២៤h/២៤h ផ្គត់ផ្គង់ក្នុងឃុំដារ ទ្រៀក មេមត់ ត្រមូង ។

**២ សេវាករ ស៊ាង ស៊ីផាន:** តម្លៃលក់ជូនអតិថិជន ១០០០រៀលក្នុងមួយគីឡូវ៉ាត់២៤h/២៤h ផ្គត់ផ្គង់ក្នុងឃុំទន្លូងទាំងមូល និងផ្នែកខ្លះនៃឃុំជាំក្រវៀន ។

**៣ សេវាករ សូ ថាវិន:** តម្លៃលក់ជូនអតិថិនជន ១០០០រៀល ក្នុង ១ គីឡូវ៉ាត់ ២៤h/២៤h ផ្គត់ផ្គង់ក្នុងឃុំមេមត់, គគីរ , កំពាន់, រំចេក, ជាំតាម៉ៅ និងផ្នែកខ្លះនៃឃុំត្រមូង។

**៤ សេវាករអេឡិចត្រិក ស៊ីធី ដួនរ័ត្ន:** ទិញថាមពលពីវៀតណាម តម្លៃលក់ជូនអតិថិជន ៧៥០រៀល ក្នុង ១ គីឡូវ៉ាត់ ២៤h/២៤h ផ្គត់ផ្គង់ក្នុងឃុំរូង និងផ្នែកខ្លះនៃឃុំទ្រៀក ។

សម្រាប់ទិសដៅបន្ត ចុងឆ្នាំ ២០១៦ សាខាអគ្គិសនីកំពង់ចាម និងបង្កើតសាខាថ្មី ១កន្លែងទៀត ដើម្បីចែកចាយក្នុង ក្នុងឃុំជាំ និងជាំក្រវៀន និងផ្នែកខ្លះនៃឃុំចាន់មូល ។

+ **ការខាររ៉ែ:** ស្រុកមេមត់មានទីតាំងរ៉ែមាស ១ កន្លែង នៅឃុំជាំតាម៉ៅ ក្នុងឆ្នាំ២០១០ ក្រុមហ៊ុនធិន ស៊ីណូសាន់បានចូលមកធ្វើអាជីវកម្មជាលក្ខណៈសាកល្បង តែត្រូវបិទទៅវិញក្នុងឆ្នាំ ២០១៥ បច្ចុប្បន្ននេះមិនដំណើរការទេ មានតែប្រជាពលរដ្ឋមួយចំនួនធ្វើអាជីវកម្មជាលក្ខណៈគ្រួសារ ។

**២.៣.៨. ការខារមីក្រូហិរញ្ញវត្ថុក្នុងស្រុកមេមត់**

មីក្រូហិរញ្ញវត្ថុ ក្នុងស្រុកមេមត់មានចំនួន ១៤[34] ក្នុងនោះមាន៖

១- ធានាគារ អេស៊ីលីដា ភីអិលស៊ី ទីតាំង ឃុំមេមត់ ១

[33] សៀវភៅស្តីពីវិស័យនានានៅក្នុងរដ្ឋបាលស្រុកមេមត់ ឆ្នាំ២០១៦

[34] សៀវភៅស្តីពីវិស័យនានានៅក្នុងរដ្ឋបាលស្រុកមេមត់ ឆ្នាំ២០១៦

២- ធានាគារ អេស៊ីលីដា ភីអិលស៊ី ទីតាំង ឃុំដារ ១

៣- ធានាគារ កាណាឌីយ៉ា ភីអិលស៊ី ទីតាំង ឃុំមេមត់ ១

៤- ធានាគារ ABA ទីតាំង ឃុំមេមត់ ១

៥- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុស្ថាបនា លីមិតធីត ទីតាំង ឃុំមេមត់ ១

៦- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុប្រាសាក់ ទីតាំង ឃុំមេមត់ ១

៧- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុនិរន្តន៍ ទីតាំង ឃុំមេមត់ ១

៨- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអេអឹមខេ ទីតាំង ឃុំមេមត់ ១

៩- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុអម្រិត ទីតាំង ឃុំមេមត់ ១

១០- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ ទីតាំង ឃុំមេមត់ ១

១១- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុហត្ថាកសិករ ទីតាំង ឃុំដារ ១

១២- ធានាគារភូមិ ប្តូរទៅ អិលអូអិលស៊ី ទីតាំង ឃុំមេមត់ ១

១៣- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុក្រេឌិត ទីតាំង ឃុំមេមត់ ១

១៤- គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុសហគ្រិនភាព STMicro Finance PLC ទីតាំង ឃុំមេមត់ ១ ។

## ២.៤ តួនាទី ភារកិច្ច និងអង្គដឹកនាំរបស់សាលាស្រុក

### ២.៤.១ អង្គដឹកនាំរបស់សាលាស្រុកមេមត់

សាលាស្រុកត្រូវមានអង្គដឹកនាំ និងរចនាសម្ព័ន្ធជាក់លាក់មួយនៅក្នុងរដ្ឋបាលរបស់ខ្លួនតាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨។ ក្រុមប្រឹក្សាសាលាស្រុកមេមត់មានសមាសភាព ១៩ រូប ស្រី ០៤ រូប ។ គណៈអភិបាលមានចំនួន ០៥ រូប ស្រី ០១រូប នាយករដ្ឋបាលមានចំនួន ០១រូប នាយករងរដ្ឋបាលមានចំនួន ០២ រូប ។ ការិយាល័យរដ្ឋបាល និង ហិរញ្ញវត្ថុមាន ០៥រូប ការិយាល័យផែនការ និងគាំទ្រឃុំមានចំនួន ០២ រូប ការិយាល័យមាន ០៣ រូប[35]។

[35] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ (២០១៤-២០១៨)

**រចនាសម្ព័ន្ធរដ្ឋបាលថ្នាក់ស្រុកៈ**




*ប្រភពៈ សៀវភៅស្តីពី តួនាទី ភារកិច្ច និងរបៀបរបបការងាររដ្ឋបាលស្រុក*

**២.៤.២ តួនាទី ភារកិច្ច**

**២.៤.២.១ តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សារដ្ឋបាលស្រុកមេមត់**

ក្រុមប្រឹក្សាមានតួនាទីចាត់ចែងកិច្ចការចាំបាច់នានាដើម្បីសម្រេចនូវគោលបំណងក្នុងការបង្កើតការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យព្រមទាំងដើម្បីបំពេញមុខងារ ភារកិច្ចដែលបានប្រគល់ និងដែលបានធ្វើប្រតិកម្មតាមច្បាប់នេះ ឬដែលស្របច្បាប់នេះ។

ក្រុមប្រឹក្សា មានសិទ្ធិអំណាចធ្វើសេចក្តីសម្រេចខាងបញ្ញត្តិ និងសេចក្តីសម្រេចខាងប្រតិបត្តិ។

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចបញ្ញត្តិរបស់ខ្លួនដោយការធ្វើដីការស្របទៅតាមបទប្បញ្ញត្តិដូចមានចែងក្នុងផ្នែកទី៣ ជំពូកទី២ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ។

ក្រុមប្រឹក្សាប្រើប្រាស់សិទ្ធិអំណាចប្រតិបត្តិរបស់ខ្លួនដោយធ្វើសេចក្តីសម្រេចនៅក្នុងអង្គប្រជុំរបស់ក្រុមប្រឹក្សាផ្ទាល់។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់ អំពីជម្រើសជាអាទិភាពដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ក្រុមប្រឹក្សាអាចធ្វើការអង្កេតលើករណីទាំងឡាយណាដែលខ្លួនយល់ថាមានសារៈសំខាន់ដល់ប្រជាពលរដ្ឋដែលខ្លួនជាតំណាងព្រមទាំង

អាចធ្វើការផ្សព្វផ្សាយលទ្ធផលនៃការធ្វើអង្កេតនោះរួចហើយត្រូវផ្តល់គោលការណ៍ណែនាំអនុវត្តដល់គណៈអភិបាល និងអភិបាល។

ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាម រដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានានា។ រៀងរាល់កិច្ចប្រជុំរបស់ខ្លួន ក្រុមប្រឹក្សាត្រូវធ្វើសេចក្តីសម្រេច ឬដីការតាមការចាំបាច់ទាក់ទិនទៅនឹងៈ

- ការរៀបចំដើម្បីទទួលមុខងារ ភារកិច្ច និងធនធានថ្មី ស្របតាមច្បាប់នេះ
- មុខងារជាកាតព្វកិច្ចរបស់ក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- កម្មវិធីវិនិយោគបី(៣)ឆ្នាំ និងផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ រួមទាំងសមាសភាពនៃផែនការនោះដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ក្រុមប្រឹក្សារួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងទៀត ក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលនិងអ្នកពាក់ព័ន្ធនានា
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យម
- បញ្ហាហិរញ្ញវត្ថុផ្សេងទៀត
- ការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន រួមទាំងគណៈកម្មាធិការអង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការគ្រប់គ្រង និងការប្រើប្រាស់ទ្រព្យសម្បត្តិ
- ដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សានិងត្រូវធ្វើការផ្សព្វផ្សាយដំណើរការពិគ្រោះយោបល់ជាមួយសាធារណជនក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា និងការផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋ
- កិច្ចការផ្សេងទៀត ដែលកំណត់ដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋានដែលបានធ្វើឡើងស្របតាមច្បាប់នេះ។

ក្រុមប្រឹក្សាត្រូវរៀបចំនិងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលរយៈពេលប្រាំ(៥)ឆ្នាំដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ តាមការរៀបចំកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំ។

ក្នុងការរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សាត្រូវពិគ្រោះយោបល់ជាមួយៈ

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
- អ្នកពាក់ព័ន្ធនានា។

ក្រុមប្រឹក្សាត្រូវរៀបចំផែនការអភិវឌ្ឍដែលរួមមានៈ

- ចក្ខុវិស័យរបស់ក្រុមប្រឹក្សា ដោយបង្ហាញពីគោលដៅ និងគោលបំណងសម្រាប់អភិវឌ្ឍនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។
- ការប៉ាន់ប្រមាណពីកម្រិតនៃការអភិវឌ្ឍន៍ដែលមានស្រាប់នៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងការប៉ាន់ប្រមាណពីតម្រូវការអភិវឌ្ឍន៍សំខាន់ៗរួមមាន៖
  - តម្រូវការរបស់ក្រុមប្រឹក្សានៅក្នុងការរៀបចំទទួលយកនូវការផ្ទេរមុខងារ ភារកិច្ច និងធនធានថ្មីៗ
  - សេវា មធ្យោបាយ សម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធសាធារណៈជាមូលដ្ឋាននិងចាំបាច់នានា
  - ការកាត់បន្ថយភាពក្រីក្រ
  - តម្រូវការផ្សេងៗរបស់ស្ត្រី បុរស យុវវ័យ កុមារ ក្រុមជនងាយទទួលរងគ្រោះរួមទាំងជនក្រីក្រ ជនជាតិដើមភាគតិច។
- ក្របខ័ណ្ឌអភិវឌ្ឍដែលត្រូវចែងអំពីគោលការណ៍ណែនាំជាមូលដ្ឋានក្នុង ការប្រើប្រាស់ និងគ្រប់គ្រងការប្រើប្រាស់ដីធ្លី និងធនធានធម្មជាតិនៅតំបន់នេះ
- ផែនការគ្រប់គ្រងគ្រោះមហន្តរាយ
- ផែនការហិរញ្ញវត្ថុដោយរាប់បញ្ចូលទាំងផែនការអភិវឌ្ឍន៍មូលធន ការគ្រោងថវិកាសម្រាប់រយៈពេលដប់ពីរ (១២) ខែ ចាប់ពីពេលរៀបចំផែនការ និងសម្រាប់រយៈពេលបី(៣)ឆ្នាំ ចាប់ពីពេលរៀបចំផែនការ ហើយត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ
- យុទ្ធសាស្ត្រអនុវត្តផែនការអភិវឌ្ឍន៍ ដើម្បីធានាឲ្យមានតម្លាភាព និងគណនេយ្យភាព ចំពោះប្រជាពលរដ្ឋទាំងអស់នៅក្នុងផែនការអភិវឌ្ឍន៍
- សូចនាករបំពេញការងារសំខាន់ៗនិងគោលដៅនានាដែលទាក់ទិននឹងអាទិភាព និងទិសដៅអភិវឌ្ឍនីមួយៗដូចមានចែងក្នុងផែនការអភិវឌ្ឍន៍

ក្រុមប្រឹក្សាត្រូវកំណត់ឲ្យដាច់ពីគ្នានៅក្នុងផែនការអភិវឌ្ឍន៍ និងថវិកានូវមុខងារជាជម្រើស និងមុខងារជាកាតព្វកិច្ច។ បែបបទនីតិវិធីជាក់ស្តែងនៃការរៀបចំ ការគ្រប់គ្រង និងការអនុវត្តផែនការអភិវឌ្ឍន៍របស់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃបន្ទាប់ពីបានពិគ្រោះពិភាក្សាជាមួយក្រសួងផែនការ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។

ក្រុមប្រឹក្សាត្រូវតាមដាន និងវាយតម្លៃជារៀងរាល់ឆ្នាំទៅលើការអនុវត្តផែនការអភិវឌ្ឍន៍របស់ខ្លួនដោយរាប់ទាំងផ្នែកនៃផែនការអភិវឌ្ឍន៍ដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់៖

- ក្រុមប្រឹក្សាភេទរួមគ្នា
- ប្រភេទក្រុមប្រឹក្សាផ្សេងទៀត
- ក្រសួង ស្ថាប័ន អង្គភាពនានារបស់រាជរដ្ឋាភិបាល

- អ្នកពាក់ព័ន្ធនានា។

ក្រុមប្រឹក្សាត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ និងជាបន្ទាន់នូវផែនការអភិវឌ្ឍន៍បន្ទាប់ពីបានអនុម័តរួចហើយភ្លាម។ សាធារណជនអាចពិនិត្យឯកសារផែនការនេះនៅការិយាល័យរបស់ក្រុមប្រឹក្សាដោយឥតគិតថ្លៃឬអាចស្នើសុំជាឯកសារផែនការនេះពីក្រុមប្រឹក្សាដោយឥតគិតត្រឹមតម្លៃដើមក្រុមប្រឹក្សាត្រូវចាត់ចែងកិច្ចការហិរញ្ញវត្ថុឲ្យមានតម្លាភាពនិងមានគណនេយ្យភាពចំពោះប្រជាពលរដ្ឋខ្លួន[36]។

### ២.៤.២.២ តួនាទី ភារកិច្ច សិទ្ធអំណាចរបស់គណៈអភិបាលស្រុកមេមត់

ក្រុមប្រឹក្សារដ្ឋបាលស្រុកមេមត់ ត្រូវត្រួតពិនិត្យសកម្មភាព និងការអនុវត្តរបស់គណៈអភិបាលស្រុកមេមត់។ ក្នុងករណីចាំបាច់ក្រុមប្រឹក្សាស្រុកមេមត់អាចកោះអញ្ជើញគណៈអភិបាលស្រុកមេមត់ឬ អភិបាលស្រុកមេមត់ និងបុគ្គលដែលពាក់ព័ន្ធមកសាកសួរបំភ្លឺក្នុងកិច្ចប្រជុំសាមញ្ញ វិសាមញ្ញរបស់ក្រុមប្រឹក្សាស្រុកមេមត់។

គណៈអភិបាល ឬអភិបាលដែលបានសម្រេច ឬបានអនុវត្តកិច្ចការណាមួយដែលស្ថិតក្នុងសមត្ថកិច្ចរបស់ក្រុមប្រឹក្សាហើយពុំបានទទួលការសម្រេចពីក្រុមប្រឹក្សា ការសម្រេច ឬសកម្មភាពនោះពុំមានសុពលភាពបានឡើយ គណៈអភិបាលត្រូវផ្តល់យោបល់ និងរាយការណ៍ជូនក្រុមប្រឹក្សាពីការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធប្រព័ន្ធ និងធនធានរបស់ក្រុមប្រឹក្សា ដើម្បីទទួលយកនូវមុខងារ ភារកិច្ច និងធនធានដែលនឹងត្រូវផ្ទេរទៅឲ្យក្រុមប្រឹក្សាដោយច្បាប់នេះ ឬដែលស្របតាមច្បាប់នេះ។គណៈអភិបាលក្នុងនាមក្រុមប្រឹក្សាត្រូវមានវិធានការដើម្បីធានាឲ្យមន្ត្រីអង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សាបំពេញតួនាទី ភារកិច្ចរបស់ខ្លួន និងបំពេញការងារប្រចាំរបស់ក្រុមប្រឹក្សាព្រមទាំងអនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាប្រកបដោយប្រសិទ្ធភាព។ គណៈអភិបាលត្រូវផ្តល់អនុសាសន៍ និងដាក់ជូនក្រុមប្រឹក្សា ដើម្បីពិភាក្សាសម្រេចអំពី៖

- ការបង្កើត ឬ រំសាយអង្គភាព
- ការរៀបចំតួនាទី ភារកិច្ច និងលក្ខខ័ណ្ឌការងាររបស់បុគ្គលិក
- ការតែងតាំង ការដំឡើងឋានន្តរស័ក្តិ និងការបញ្ឈប់បុគ្គលិក ដោយផ្អែកតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់លក្ខណសម្បត្តិនៃការជ្រើសរើស ការតែងតាំង ការកំណត់ប្រាក់បៀវត្ស និងប្រាក់កម្រៃផ្សេងៗទៀតនៃបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់នីតិវិធីរដ្ឋបាល និងហិរញ្ញវត្ថុ សម្រាប់អង្គភាព និងបុគ្គលិករបស់ក្រុមប្រឹក្សា
- ការកំណត់យុទ្ធសាស្ត្រ ដើម្បីអភិវឌ្ឍសមត្ថភាពដល់ក្រុមប្រឹក្សា និងបុគ្គលិករបស់ខ្លួន។
  គណៈអភិបាលត្រូវរៀបចំដាក់ជូនក្រុមប្រឹក្សារបស់ខ្លួនដើម្បីពិនិត្យ និងអនុម័តនូវ៖
- កម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលឆ្នាំប្រចាំឆ្នាំ និងគម្រោងថវិកាប្រចាំឆ្នាំ

[36] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំ និងក្របខ័ណ្ឌចំណាយរយៈពេលមធ្យមដែលត្រូវធ្វើបច្ចុប្បន្នភាពរៀងរាល់ឆ្នាំ និងរបាយការណ៍ប្រចាំឆ្នាំរបស់ក្រុមប្រឹក្សាដូចមានចែងក្នុង មាត្រា៥០ នៃច្បាប់នេះដើម្បីផ្សព្វផ្សាយជូនប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។

  គណៈអភិបាលត្រូវលើសំណើរទៅក្រុមប្រឹក្សា ដើម្បីកំណត់អំពីយុទ្ធសាស្ត្រ និងរបៀបនៃការពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗរួមទាំងផែនការ អភិវឌ្ឍជាមួយៈ

- ប្រជាពលរដ្ឋនៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា
- ផ្នែកផ្សេងទៀតរបស់ក្រុមប្រឹក្សាដែលអនុវត្តមុខងារ និងភារកិច្ចនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន
- ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានារបស់រាជរដ្ឋាភិបាល
- ដៃគូរពាក់ព័ន្ធដទៃទៀត
- ពិគ្រោះយោបល់លើបញ្ហាចាំបាច់ផ្សេងៗ រួមទាំងផែនការអភិវឌ្ឍន៍ដែលត្រូវធ្វើឡើងដោយក្រុមប្រឹក្សាផ្ទាល់ ឬដោយគណៈអភិបាលក្នុងនាមក្រុមប្រឹក្សា។

គណៈអភិបាលត្រូវរាយការណ៍ជូនគ្រប់អង្គប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សាជាមួយនឹងអនុសាសន៍ចាំបាច់នានា សម្រាប់លើកកម្ពស់ការអនុវត្តៈ

- មុខងារជាកាតព្វកិច្ចដែលបានផ្ទេរទៅអោយក្រុមប្រឹក្សា
- មុខងារជាជម្រើសរបស់ក្រុមប្រឹក្សា
- កម្មវិធីបី(៣)ឆ្នាំរំកិលប្រចាំឆ្នាំនិងផែនការអភិវឌ្ឍរយៈពេលប្រាំ(៥)ឆ្នាំរបស់ក្រុមប្រឹក្សារួមទាំងសមាភាពនៃផែនការដែលស្ថិតនៅក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ៈ
  - ក្រុមប្រឹក្សារួមគ្នា
  - ប្រភេទក្រុមប្រឹក្សាផ្សេងៗ
  - ក្រសួង ស្ថាប័ន ឬ មន្ទីរ អង្គភាពនានារបស់រាជរដ្ឋាភិបាល
  - ដៃគូពាក់ព័ន្ធនានា។
- គម្រោងថវិកាប្រចាំឆ្នាំ និងក្របខណ្ឌចំណាយរយៈពេលមធ្យមរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ស្ថានភាពហិរញ្ញវត្ថុរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- ដីការរបស់ក្រុមប្រឹក្សា

គណៈអភិបាល ត្រូវពិគ្រោះយោបល់ជាមួយគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ដើម្បីធានាឲ្យផែនការសកម្មភាព និងថវិការបស់បណ្ដាក្រសួង ស្ថាប័ន មន្ទីរ អង្គការនានារបស់រាជរដ្ឋាភិបាលដែលផ្ដល់សេវាសម្ភារៈ និងហេដ្ឋារចនាសម្ព័ន្ធ ដោយសផ្ទាល់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សាបានដាក់បញ្ចូលទៅក្នុងផែនការ

អភិវឌ្ឍរយៈពេលប្រាំ(០៥)ឆ្នាំ និងកម្មវិធីវិនិយោគបី(០៣) ឆ្នាំរំកិលប្រចាំឆ្នាំព្រមទាំងថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។

គណៈអភិបាលត្រូវលើកទឹកចិត្ត សម្របសម្រួល និងគាំទ្រដល់សមាជិកក្រុមប្រឹក្សាបុគ្គលិករបស់ក្រុមប្រឹក្សា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃជាបន្ទាន់ នៅពេលដែលបានឃើញ ឬដែលបានសង្ស័យដោយមានហេតុផល ឬដែលមានការប្តឹងតវ៉ា ឬ ប្តឹងបរិហារកេរ្តិ៍ អំពីការរំលោភអំណាចដោយបុគ្គលណាម្នាក់នៅក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។

គណៈអភិបាលត្រូវផ្តល់អនុសាសន៍ជូនក្រុមប្រឹក្សាអំពីការបង្កើតគណៈកម្មាធិការនានាតាមការចាំបាច់ដើម្បីជួយដល់ក្រុមប្រឹក្សាក្នុងការអនុវត្តការងារអនុលោមតាមច្បាប់នេះ។

គណៈអភិបាលត្រូវធានាឲ្យមានក្តារបិទផ្សាយព័ត៌មាន និងមធ្យោបាយផ្សព្វផ្សាយព័ត៌មានផ្សេងៗទៀតតាមតម្រូវការរបស់ក្រុមប្រឹក្សារបស់ខ្លួន។ រាល់គ្រប់ឯកសារទាំងអស់ដែលបានបោះពុម្ពផ្សព្វផ្សាយត្រូវស្របតាមច្បាប់នេះ ហើយត្រូវតែបិទផ្សព្វផ្សាយនៅលើក្តារព័ត៌មាន ឬ ត្រូវផ្សព្វផ្សាយតាមមធ្យោបាយបានផ្សេងៗទៀតក្នុងដែនសមត្ថកិច្ចរបស់ក្រុមប្រឹក្សា។ គណៈអភិបាលត្រូវធ្វើការបែងចែកភារកិច្ចជាលាយល័ក្ខណ៍អក្សរនូវកិច្ចការដែលស្ថិតនៅក្នុងសិទ្ធិអំណាចរបស់ខ្លួន។ នៅក្នុងករណីចាំបាច់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃអាចលើកសំណើជូនរាជរដ្ឋាភិបាលដើម្បីកំណត់នូវតួនាទី ភារកិច្ច និងរបៀបរបបការងាររបស់គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខ័ណ្ឌ ដោយអនុក្រឹត្យ[37]។

**២.៤.២.៣ តួនាទី ភារកិច្ច សិទ្ធិអំណាចរបស់នាយករដ្ឋបាល**

នាយករដ្ឋបាល មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- អនុវត្តកិច្ចការប្រចាំថ្ងៃរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- ធានាឲ្យអង្គភាព បុគ្គលិករបស់ក្រុមប្រឹក្សា អនុវត្តសេចក្តីសម្រេចរបស់ក្រុមប្រឹក្សា និងគណៈអភិបាល
- អនុវត្តដីការបស់ក្រុមប្រឹក្សា
- ចូលរួម និងយោបល់រាល់កិច្ចប្រជុំរបស់ក្រុមប្រឹក្សា គណៈកម្មាធិការរបស់ក្រុមប្រឹក្សា និងគណៈអភិបាល ប៉ុន្តែពុំមានសិទ្ធិបោះឆ្នោតបានឡើយ
- ផ្តល់យោបល់ដល់ក្រុមប្រឹក្សា ដល់គណៈកម្មាធិការនានារបស់ក្រុមប្រឹក្សា ដើម្បីក្រុមប្រឹក្សាសម្រេចបាននូវគោលបំណងក្នុងការបង្កើត ការជំរុញ និងការធ្វើឲ្យមានចីរភាពដល់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ
- ផ្តល់យោបល់ដល់គណៈអភិបាល ដើម្បីគណៈអភិបាលអនុវត្ត មុខងារ និងភារកិច្ចរបស់ខ្លួនឲ្យមានប្រសិទ្ធភាព។

[37] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

គណៈអភិបាល អាចធ្វើប្រតិភូកម្មការងារទៅឲ្យ នាយករដ្ឋបាលនូវកិច្ចការណាមួយដែលស្ថិតក្នុងវិសាលភាពការងាររបស់គណៈអភិបាល ដើម្បីលើកយោបល់ជូនគណៈអភិបាលសម្រេច។

នាយករដ្ឋបាល ត្រូវធានាឲ្យប្រធានហិរញ្ញវត្ថុបំពេញភារកិច្ចរបស់ខ្លួនបានត្រឹមត្រូវ។

## ២.៥ ការិយាល័យចំណុះរដ្ឋបាលស្រុកមេមត់

សាលាស្រុកមេមត់ មានការិយាល័យចំណុះចាំបាច់ចំនួន ០៤ ដូចជា៖

- ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ
- ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់
- ការិយាល័យអន្តរវិស័យ
- អង្គភាពលទ្ធកម្ម

ការិយាល័យនីមួយៗត្រូវដឹកនាំដោយប្រធានការិយាល័យមួយរូប និងមានអនុប្រធានការិយាល័យមួយរូបជាជំនួយការ។ ប្រធានការិយាល័យនីមួយៗត្រូវមានការទទួលខុសត្រូវ និងត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះនាយករដ្ឋបាលសាលាស្រុក[38]។

### ក. តួនាទី ភារកិច្ចការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុ

ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុនៃសាលាស្រុកគឺ ជាសេនាធិការឲ្យក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកលើកិច្ចការសំខាន់ៗដូចខាងក្រោម[39]៖

- ការងាររដ្ឋបាល លិខិតស្នាមផ្សេងៗ ទំនាក់ទំនងសាធារណៈ និងការងារពិធីការ
- គ្រប់គ្រង និងថែរក្សាត្រារដ្ឋបាលស្រុកតាមការកំណត់
- ការងារស្ថិតិប្រជាពលរដ្ឋ និងការងារអត្រានុកូលដ្ឋាន
- ការងារបុគ្គលិក ក្របខ័ណ្ឌ បៀវត្ស និងកម្រៃផ្សេងៗរបស់មន្ត្រីបុគ្គលិកសាលាស្រុក
- សហការរៀបចំនីតិវិធីរដ្ឋបាល នីតិហិរញ្ញវត្ថុ និងលក្ខខណ្ឌការងាររបស់មន្ត្រី បុគ្គលិកសាលាស្រុក
- ការបណ្តុះបណ្តាល និងការកសាងសមត្ថភាពមន្ត្រី បុគ្គលិកសាលាស្រុក
- សិក្សា និងលើកយោបល់ទៅលើការបង្កើត ការកែសម្រួល និងការរំលាយការិយាល័យចំណុះសាលាស្រុក
- រៀបចំសេចក្តីព្រាងរបៀបវារៈ ខ្លឹមសារសម្រាប់របៀបវារៈនីមួយៗ និងឯកសារនៃកិច្ចប្រជុំរបស់ក្រុមប្រឹក្សាស្រុក និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក
- រៀបចំ និងបែងចែកលិខិតអញ្ជើញប្រជុំ ការរៀបចំទីកន្លែងប្រជុំ និងកំណត់ហេតុគ្រប់កិច្ចប្រជុំទាំងអស់របស់ក្រុមប្រឹក្សាស្រុក និងគណៈអភិបាល និងគណៈកម្មាធិការនានារបស់ក្រុមប្រឹក្សាស្រុក

---

[38] សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបការងាររបស់រដ្ឋបាលស្រុក

[39] សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបការងាររបស់រដ្ឋបាលស្រុក ,ឆ្នាំ ២០១០

- ទទួល និងបែងចែកលិខិតស្នាម ឯកសារនានាឲ្យបានត្រឹមត្រូវដល់សមាជិកក្រុមប្រឹក្សាស្រុក អភិបាលស្រុក និងអភិបាលរងស្រុក ព្រមទាំងក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ការិយាល័យជំនាញ និងអ្នកពាក់ព័ន្ធ
- រក្សាទុកដាក់ឲ្យបានត្រឹមត្រូវ និងគង់វង្សនូវឯកសារ លិខិតបទដ្ឋានទាំងអស់របស់ក្រុមប្រឹក្សាស្រុក គណៈអភិបាលស្រុក និងរដ្ឋបាលស្រុក
- រៀបចំរបាយការណ៍ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ
- រៀបចំ និងបិទផ្សាយព័ត៌មាននៅលើក្តារព័ត៌មាន និងស្វះស្វែងរកមធ្យោបាយផ្សព្វផ្សាយព័ត៌មាននានាជូនប្រជាពលរដ្ឋនៅក្នុងស្រុករបស់ខ្លួន
- សហការក្នុងការត្រៀមរៀបចំវេទិកាផ្សព្វផ្សាយ និងពិគ្រោះយោបល់នៅតាមសាលាឃុំ និងសង្កាត់នានាក្នុងស្រុក
- សិក្សា និងលើកយោបល់ទាក់ទងនឹងការពិនិត្យនីត្យានុកូលកូលភាពនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាឃុំ និងសង្កាត់នានាក្នុងស្រុក
- ការងារហិរញ្ញវត្ថុ ថវិកា និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋបាលស្រុក
- គ្រប់គ្រងបេឡារបស់សាលាស្រុក
- សហការត្រួតពិនិត្យ និងទូទាត់រាល់ការចំណាយ
- ការងារលទ្ធកម្ម សវនកម្ម និងរបាយការណ៍ហិរញ្ញវត្ថុរបស់ស្រុក។

### ខ. តួនាទី ភារកិច្ចការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់

ការិយាល័យផែនការ និងគាំទ្រឃុំ សង្កាត់នៃសាលាស្រុកគឺជាសេនាធិការឲ្យក្រុមប្រឹក្សាស្រុក និងគណៈ-អភិបាលស្រុកលើកិច្ចការសំខាន់ៗដូចខាងក្រោម[40]៖

- សិក្សា និងរៀបចំផែនការអភិវឌ្ឍន៍រយៈពេលប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលប្រចាំឆ្នាំរបស់ស្រុក រួមទាំងសមាសភាគនៃផែនការដែលស្ថិតិក្រោមការគ្រប់គ្រង និងត្រួតពិនិត្យរបស់ក្រុមប្រឹក្សាប្រភេទរួមគ្នា ប្រភេទក្រុមប្រឹក្សាផ្សេងៗគ្នាក្រសួងស្ថាប័ន មន្ទីរ ឬ ការិយាល័យ អង្គភាពនានារបស់រាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធ
- អនុវត្តគម្រោង កម្មវិធីអភិវឌ្ឍ សម្របសម្រួលកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍ និងការផ្តល់សេវារវាងឃុំ និងសង្កាត់នានាក្នុងស្រុក
- ជួយដល់ក្រុមប្រឹក្សាឃុំ និងសង្កាត់ដើម្បីវិភាគវាយតម្លៃដំណើរការអភិវឌ្ឍរបស់ឃុំ និងសង្កាត់ក្នុងស្រុក
- សហការគាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ក្នុងការរៀបចំថវិកាឃុំ សង្កាត់ក្នុងស្រុក
- សហការពិនិត្យ និងលើកអនុសាសន៍ជូនអភិបាលខេត្ត អំពីការធ្វើអនុលោមភាពថវិកាឃុំ និងសង្កាត់ក្នុងស្រុក

[40] សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបការងាររបស់រដ្ឋបាលស្រុក ,ឆ្នាំ ២០១០

- សិក្សា វាយតម្លៃ និងលើកយោបល់អំពីសមត្ថភាពរបស់ក្រុមប្រឹក្សាឃុំ សង្កត់ក្នុងស្រុក និងតម្រូវការគាំទ្រ
- ដោះស្រាយសំណើរ សំណូមពរ និងបញ្ហាប្រឈមនានារបស់ឃុំ សង្កាត់ក្នុងស្រុក
- គាំទ្រដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងស្រុកក្នុងការកសាង និងការអនុវត្តផែនការអភិវឌ្ឍន៍របស់ឃុំ និងសង្កាត់ក្នុងស្រុក
- ទំនាក់ទំនង សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ស្តីពីការកែសម្រួលទិន្នន័យ ផែនទី សេចក្តីត្រូវការ
- ទំនាក់ទំនង សហការជាមួយស្ថាប័ន អង្គភាពពាក់ព័ន្ធ ស្តីពីការកែសម្រួលទិន្នន័យ ផែនទី សេចក្តីត្រូវការជាអាទិភាពរបស់ស្រុក ឃុំ និងសង្កាត់ក្នុងស្រុក
- បញ្ចូល និងធ្វើបច្ចុប្បន្នភាពទិន្នន័យ ដែលពាក់ព័ន្ធស្រុក ឃុំ និងសង្កាត់
- ពិនិត្យរបាយការណ៍អនុវត្តផែនការអភិវឌ្ឍន៍របស់ស្រុក ឃុំ និងសង្កាត់
- កៀរគរធនធានសម្រាប់អភិវឌ្ឍស្រុក និងគាំទ្រឃុំ សង្កាត់ក្នុងស្រុក
- គាំទ្រឃុំ និងសង្កាត់ក្នុងស្រុក ដើម្បីអាចទទួលបាននូវមុខងារ និងធនធានកាន់តែច្រើនឡើង
- ពិនិត្យ និងវាយតម្លៃការប្រើប្រាស់មូលនិធិវិនិយោគស្រុក ឃុំ និងសង្កាត់ក្នុងស្រុក

### គ. តួនាទី ភារកិច្ចការិយាល័យអន្តរវិស័យ

ការិយាល័យអន្តរវិស័យនៃសាលាស្រុក គឺជាសេនាធិការឲ្យក្រុមប្រឹក្សាស្រុក និងគណៈអភិបាលស្រុកលើកិច្ចការសំខាន់ដូចខាងក្រោម[41]៖

- សិក្សា និងលើកយោបល់ទៅលើការរៀបចំយុទ្ធសាស្ត្រ និងការរៀបចំរចនាសម្ព័ន្ធ ប្រព័ន្ធ និងធនធាន ដើម្បីទទួលយកមុខងារ ភារកិច្ច និងធនធានដែលបានប្រគល់ ឬបានផ្ទេរស្របទៅតាមច្បាប់ និងលិខិតបទដ្ឋានកំណត់
- ការងារដីធ្លី និងសំណង់ដែលរួមមានពាក្យសុំកាន់កាប់ដីធ្លី សាងសង់ រុះរើ ជួលជុល កែលម្អ សំណង់នានា
- ការអនុវត្តមុខងារ ភារកិច្ចនានាដែលបានប្រគល់ ឬបានធ្វើប្រតិភូកម្ម
- ការងារសណ្តាប់ធ្នាប់សាធារណៈ កិច្ចការច្បាប់ និងសិទ្ធិមនុស្ស
- ការងារសម្រុះសម្រួល ផ្សះផ្សាទំនាស់ផ្សេងៗក្នុងដែនសមត្ថកិច្ចរបស់ស្រុក ស្របទៅតាមច្បាប់ និងនិតិវិធីជាធរមាន
- ការងារសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ សាសនា ការការពារបរិស្ថាន ធនធានធម្មជាតិ បេតិកភ័ណ្ឌ រមណីដ្ឋាន និងតំបន់ប្រវត្តិសាស្ត្រ ដែលកំណត់ដោយច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនានា។

### ឃ. អង្គភាពលទ្ធភាព

អង្គភាពលទ្ធភាពរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌមានភារកិច្ចដូចខាងក្រោម៖

[41] សៀវភៅណែនាំស្តីពីតួនាទី ភារកិច្ច និងរបៀបការងាររបស់រដ្ឋបាលស្រុក ,ឆ្នាំ ២០១០

- រៀបចំសេចក្ដីព្រាងផែនការលទ្ធកម្មប្រចាំឆ្នាំ និងផែនការលទ្ធកម្មកែតម្រូវការក្នុងករណីចាំបាច់
- រៀបចំឯកសារដេញថ្លៃ សម្រាប់ប្រភេទលទ្ធកម្មនីមួយៗ ផ្អែកតាមគំរូឯកសារដេញថ្លៃដែលបានកំណត់ដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- រៀបចំ និងផ្សព្វផ្សាយសេចក្ដីជូនដំណឹងអំពីកិច្ចលទ្ធកម្មនីមួយៗ
- លក់ ឬផ្ដល់ឯកសារដេញថ្លៃជូនអ្នកមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្ម
- ទទួលសំណើរដេញថ្លៃ និងបកស្រាយបំភ្លឺចំពោះអ្នកដេញថ្លៃ ក្នុងករណីមានសំណួរពាក់ព័ន្ធនឹងការដេញថ្លៃ
- រៀបចំទុកដាក់សំណើរដេញថ្លៃដែលបានទទួលឲ្យបានត្រឹមត្រូវ មានសុវត្ថិភាព និងត្រូវគ្រប់គ្រងឯកសារ ឬលិខិតស្នាមពាក់ព័ន្ធទាំងអស់មុនពេលបើកសំណើរដេញថ្លៃ
- ចាត់ចែងរៀបចំទីកន្លែងសម្រាប់បើកសំណើរដេញថ្លៃ
- រៀបចំបើកសំណើរដេញថ្លៃជាសាធារណៈ ដោយមានការដឹកនាំត្រួតពិនិត្យពីគណៈកម្មធិការលទ្ធកម្មរបស់រដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- រៀបចំធ្វើរបាយការណ៍ ឬកំណត់ហេតុស្ដីពីការបើកសំណើរដេញថ្លៃ
- ជួយសម្របសម្រួលក្នុងការវាយតម្លៃលើបច្ចេកទេសនៃសំណើដេញថ្លៃ
- ឆ្លើយតបចំពោះសសំណួរពាក់ព័ន្ធនឹងរបាយការណ៍វាយតម្លៃលើសំណើដេញថ្លៃ
- ធ្វើលិខិតជូនដំណឹងស្ដីពីការប្រគល់កិច្ចសន្យាទៅអ្នកដេញថ្លៃឈ្នះ និងចម្លងជូនទៅគ្រប់អ្នកដេញថ្លៃចាញ់
- ធ្វើសេចក្ដីព្រាងកិច្ចសន្យាឲ្យសមស្របតាមបទដ្ឋានឯកសារកិច្ចសន្យាដែលបានកំណត់
- ផ្សព្វផ្សាយលទ្ធផលនៃការដេញថ្លៃជាសាធារណៈ
- តាមដានការអនុវត្តកិច្ចសន្យា ដោយសហការជាមួយមន្ត្រីបច្ចេកទេស និងមន្ត្រីជំនាញពាក់ព័ន្ធផ្សេងទៀត
- រៀបចំរបាយការណ៍ស្ដីពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស

## ២.៦ ការគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលស្រុកមេមត់

រដ្ឋបាលស្រុកមេមត់ មានក្រុមប្រឹក្សាស្រុកចំនួន ១៩រូប ស្រី ០៤រូប ប្រុស ១៥រូប [42]។ គណៈអភិបាលមានចំនួន ០៥រូប ស្រី ០១រូប ប្រុស ០៤រូប។ នាយករដ្ឋបាលមានចំនួន ០១រូប ប្រុស នាយករងរដ្ឋបាលមានចំនួន ០២រូប ប្រុស។ ការិយាល័យរដ្ឋបាល និងហិរញ្ញវត្ថុមានចំនួន ០៥រូប ការិយាល័យផែនការ និងគាំទ្រឃុំមានចំនួន ០២រូប ការិយាល័យអន្តរវិស័យ មានចំនួន ០៣រូប បុគ្គលិកកិច្ចសន្យាមានចំនួន ០២រូប ។

ជាមួយគ្នានេះផងដែរ រដ្ឋបាលស្រុកមេមត់បាននឹងកំពុងយកចិត្តទុកដាក់យ៉ាងខ្លាំងជាមួយនឹងការគ្រប់គ្រង

ធនធានមនុស្សទាំងថ្នាក់ដឹកនាំរដ្ឋបាលស្រុក ហើយនិងមន្ត្រីសាលាស្រុក ដើម្បីសម្រេចឱ្យបាននូវលទ្ធផលរំពឹងទុករបស់រដ្ឋបាលស្រុក។

[42] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨

ដើម្បីគ្រប់គ្រងធនធានមនុស្សរបស់រដ្ឋបាលស្រុកអោយមានប្រសិទ្ធភាព រដ្ឋបាលស្រុកមេមត់បានរៀបចំថ្នាក់ដឹកនាំ និងមន្ត្រីដូចតទៅ ៖ ប្រធានក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សា សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរក្នុងរយៈពេល៥ឆ្នាំ (២០១៤-២០១៨) អភិបាល អភិបាលរង នាយករដ្ឋបាល នាយករងរដ្ឋបាល ប្រធានការិយាល័យនិងអង្គភាព អនុប្រធានការិយាល័យ និងអង្គភាពមន្ត្រីការិយាល័យ និងបុគ្គលិកកិច្ចសន្យា។

## ២.៧ ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ និងកម្មវិធីវិនិយោគបីឆ្នាំរំកិល

មាត្រា៣៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ចែងថាក្រុមប្រឹក្សាត្រូវរៀបចំ និងអនុម័តផែនការអភិវឌ្ឍន៍រយៈពេលប្រាំ (៥)ឆ្នាំ ដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំតាមរយៈការរៀបចំកម្មវិធីវិនិ-យោគបី (៣) ឆ្នាំរំកិល។ ក្រោយចូលកាន់ដំណែងក្រុមប្រឹក្សាត្រូវខិតខំរៀបចំផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់ខ្លួនឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន និងយ៉ាងយូរនៅក្នុងឆ្នាំទី២ នៃអាណត្តិរបស់ខ្លួន[43]។ ផែនការអភិវឌ្ឍន៍នេះត្រូវអនុវត្តតាមការកំណត់របស់កម្មវិធីវិនិយោគបីឆ្នាំរំកិលដែលត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

ផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ គឺជាចក្ខុវិស័យរបស់ក្រុមប្រឹក្សាស្រុកដែលកំណត់អំពីរូបភាពនៃការអភិវឌ្ឍន៍នៅក្នុង

មូលដ្ឋាននៃដែនសមត្ថកិច្ចរបស់ខ្លួនហើយដែលក្រុមប្រឹក្សាស្រុកចង់ឃើញ និងចង់សម្រេចអោយបាននៅចុងអាណត្តិឆ្នាំរបស់ក្រុមប្រឹក្សាដោយឈរលើមូលដ្ឋាននៃធនធាននិងសក្តានុពលរបស់រដ្ឋបាលដែនដីរបស់ខ្លួន។ផែនការអភិវឌ្ឍន៍ប្រាំនេះមានរយៈពេលដូចអាណត្តិរបស់ក្រុមប្រឹក្សាដែរវា ជាមធ្យោបាយមួយយ៉ាងសំខាន់របស់រដ្ឋបាលថ្នាក់ក្រោមជាតិដែលត្រូវប្រើប្រាស់សម្រាប់កំណត់ អំពីបញ្ហា តម្រូវការ និងយុទ្ធសាស្ត្រនានា ដើម្បីដោះស្រាយបញ្ហាទាំងនោះ។ ចំណែកឯកម្មវិធីវិនិយោគបី(៣)ឆ្នាំរំកិលគឺ ជាការធ្វើអោយខ្លឹមសារនៃការកសាងផែនការអភិវឌ្ឍន៍ស្រុកទៅជាគម្រោងសកម្មភាព ឬសេវាកម្មជាក់ស្តែងដោយមានការភ្ជាប់នូវចំណាយមូលនិធិសំដៅលើកកម្ពស់នៃការផ្តល់សេវាសាធារណៈនិងកិច្ចអភិវឌ្ឍន៍នៅស្រុកសម្រាប់រយៈពេលបីឆ្នាំ។ កម្មវិធីវិនិយោគនេះត្រូវធ្វើបច្ចុប្បន្នភាពជារៀងរាល់ឆ្នាំ។

### ២.៧.១ គោលការណ៍សំខាន់ៗនៃការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ

ដើម្បីធានាថាតម្រូវការ បញ្ហា និងក្តីកង្វល់របស់ប្រជាពលរដ្ឋត្រូវបានឆ្លើយតបនិងដោះស្រាយនៅក្នុងការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់រដ្ឋបាលស្រុក ក្រុមប្រឹក្សាត្រូវណែនាំដល់គណៈអភិបាល និងក្រុមការងារកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំឱ្យយកចិត្តទុកដាក់ក្នុងការរៀបចំកិច្ចការនេះឱ្យមានប្រសិទ្ធភាពខ្ពស់ដោយត្រូវផ្អែកតាមគោលការណ៍សំខាន់ៗដូចខាងក្រោម[44] ៖

- ការចែករំលែកព័ត៌មាន
- តម្លាភាព
- សង្គតិភាព និងសុខុដុមនីយកម្ម

[43] ប្រការ១២ នៃប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
[44] ប្រការ ២១ នៃប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- ការចូលរួមពិគ្រោះយោបល់ទូទៅ
- ការឆ្លើយតបនឹងតម្រូវការ
- គណនេយ្យភាពតាមបែបប្រជាធិបតេយ្យ
- ប្រសិទ្ធភាព និងសុក្រឹតភាព
- ធានាចីរភាពធនធានធម្មជាតិ និងបរិស្ថាន
- ការធានាសមធម៌។

### ២.៧.២ តួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាក្នុងការកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំ

ក្នុងដំណើរការណែនាំក្រុមប្រឹក្សាការងារកសាងផែនការអភិវឌ្ឍន៍ ក្រុមប្រឹក្សារាជធានី មានតួនាទី ភារកិច្ចដូចខាងក្រោម [45]៖

- **ពិនិត្យ និងអនុម័តប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍ ៖** បន្ទាប់ពីក្រុមការងារកសាងផែនការអភិវឌ្ឍន៍បានរៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការកសាងផែនការអភិវឌ្ឍន៍រួចក្រុមប្រឹក្សាស្រុកត្រូវពិនិត្យ និងផ្តល់យោបល់លើសេចក្តីព្រាងព្រមទាំងអនុម័តប្រតិទិនការងារនោះ។ ការផ្តល់យោបល់ និងអនុម័តលើសេចក្តីព្រាងប្រតិទិនការងារត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំរបស់ក្រុមប្រឹក្សាដូចមានចែងក្នុងច្បាប់ លិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមប្រឹក្សាស្រុក។
- **ផ្តល់គោលការណ៍ណែនាំផ្អែកលើគោលនយោបាយសម្រាប់កសាងផែនការអភិវឌ្ឍន៍ ៖** ក្រុមប្រឹក្សាស្រុកត្រូវណែនាំក្រុមការងារកសាងផែនការស្រុករៀបចំសេចក្តីព្រាងគោលការណ៍ណែនាំគោលនយោបាយ ដោយត្រូវផ្តោតទៅលើចំណុចសំខាន់ៗដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍របស់ប្រទេសជាតិ។
- **ចូលរួមក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ ៖** សេចក្តីណែនាំស្តីពីបច្ចេកទេសនៃការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ស្រុកបានកំណត់ថា ត្រូវមានតំណាងក្រុមប្រឹក្សាចូលរួម ការប្រជុំរាល់កិច្ចប្រជុំនៃដំណើរការកសាងផែនការអភិវឌ្ឍន៍។ ក្នុងន័យនេះប្រធានក្រុមប្រឹក្សាស្រុកត្រូវចាត់បញ្ជូលសមាជិកក្រុមប្រឹក្សារបស់ខ្លួនដែលមានបទពិសោធន៍ និងចំណេះដឹងសមស្របដើម្បីចូលរួមក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍ជាមួយគណៈអភិបាលស្រុក និងអ្នកពាក់ព័ន្ធផ្សេងៗទៀតដើម្បីធានាថារាល់តម្រូវការ កង្វល់ និងបញ្ហាប្រឈមរបស់ប្រជាពលរដ្ឋត្រូវបានបញ្ចូលទៅក្នុងផែនការ សំដៅឆ្លើយតប និងដំណោះស្រាយជូនពួកគាត់ប្រកបដោយប្រសិទ្ធភាព។
- **តាមដាន និងវាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ស្រុក ៖** ក្រុមប្រឹក្សាធ្វើការតាមដាន និងវាយតម្លៃក្នុងដំណើរការកសាងផែនការអភិវឌ្ឍន៍ស្រុកតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាដោយតម្រូវឱ្យតំណាងក្រុម

[45] ប្រការ ៦ នៃប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

ការងារកសាងផែនការរាយការណ៍ជូន( របាយការណ៍ ឬផ្ទាល់មាត់ ) អំពីវឌ្ឍនភាពនៃដំណើរការកសាងផែនការអភិវឌ្ឍន៍។ ក្នុងកិច្ចការនេះក៏ត្រូវបានធ្វើឡើយតាមរយៈតំណាងរបស់ខ្លួនដែលបានចាត់បញ្ជូលឱ្យទៅចូលចូលរួមក្នុងដំណើរការនៃការកសាងផែនការអភិវឌ្ឍន៍។

- **ពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍ ៖** ក្រុមប្រឹក្សាស្រុកត្រូវមានមូលដ្ឋានក្នុងការពិនិត្យ និងអនុម័តផែនការអភិវឌ្ឍន៍។
- **ពិនិត្យ និងអនុម័តដំណើរការវិសោធនកម្មផែនការអភិវឌ្ឍន៍ ក្នុងករណីចាំបាច់ ៖** ផែនការអភិវឌ្ឍន៍របស់ស្រុកអាចជាកម្មវត្ថុនៃការកែសម្រួល ដោយយោងទៅតាមស្ថានភាពចាំបាច់សំដៅឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍មូលដ្ឋាន និងការបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានច្រើនបំផុត។ សេចក្តីស្នើផែនការអភិវឌ្ឍន៍នេះត្រូវអនុម័តតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សាស្រុក។
- **តាមដាន និងវាយតម្លៃការអនុវត្តផែនការអភិវឌ្ឍន៍ ៖** ក្រុមប្រឹក្សាស្រុក ត្រូវចាត់ចែងឱ្យមានការតាមដានជាប្រចាំនូវវឌ្ឍនភាពនៃការអនុវត្តផែនការអភិវឌ្ឍន៍ និងត្រូវពិនិត្យផ្តល់យោបល់លើបញ្ហាប្រឈមនានា ដើម្បីធានាឱ្យផែនការអភិវឌ្ឍន៍ត្រូវបានអនុវត្តយ៉ាងពេញលេញប្រកបដោយប្រសិទ្ធភាព។ ការតាមដាន វាយតម្លៃរបស់ក្រុមប្រឹក្សា ធ្វើឡើងតាមរយៈការត្រួតពិនិត្យរបាយការណ៍វឌ្ឍនភាព ការកោះហៅអ្នកពាក់ព័ន្ធមកធ្វើការបំភ្លឺនិងចុះពិនិត្យមើលដោយផ្ទាល់។

### ២.៧.៣ តួនាទីរបស់ក្រុមប្រឹក្សាស្រុកក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល

នៅក្នុងការរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិល ក្រុមប្រឹក្សាស្រុកមានតួនាទី ភារកិច្ចដូចខាងក្រោម[46]៖

- **ចេញសេចក្តីណែនាំស្តីពីការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល៖** ក្រុមប្រឹក្សាស្រុកត្រូវធានាថាកម្មវិធីវិធីវិនិយោគបីឆ្នាំរំកិលមានភាពគ្រប់ជ្រុងជ្រោយ និងឆ្លើយតបទៅនឹងសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋទាំងអស់ជាពិសេសក្រុមប្រជាពលរដ្ឋដែលត្រូវការការយកចិត្តទុកដាក់ជាចម្បងរួមមានជាអាទិ៍ ស្ត្រី កុមារ ជនពិការ យុវជន និងជនងាយរងគ្រោះ។ ល។ ដោយគោរពតាមគោលការណ៍ តម្លាភាព សមធម៌ និងបរិយាបន្ន។
- **ពិនិត្យ និងអនុម័តប្រតិទិនរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ៖** បន្ទាប់ពីក្រុមការងារកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលបានរៀបចំសេចក្តីព្រាងប្រតិទិនការងារសម្រាប់ដំណើរការនៃការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរួច ក្រុមប្រឹក្សាត្រូវពិនិត្យនិងផ្តល់យោបល់លើដំណើរសេចក្តីព្រាង ព្រមទាំងអនុម័តប្រតិទិនការងារនេះ។ ការផ្តល់យោបល់ និងអនុម័តសេចក្តីព្រាងប្រតិទិនការងារត្រូវធ្វើឡើងតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សារបស់ខ្លួន ដូចមានចែងក្នុងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត និងបទបញ្ជាផ្ទៃក្នុងរបស់ខ្លួន។

[46] ប្រការ ៦ នៃប្រកាសអន្តរក្រសួង ស្តីពីការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ

- **ចូលរួមក្នុងដំណើរការរៀបចំ និងកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល ៖** យោងតាមអនុក្រឹត្យលេខ ២៩១ អនក្រ.បក ស្តីពីផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគបីឆ្នាំរំកិលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានក្រុមប្រឹក្សាស្រុកត្រូវចូលរួមក្នុងកិច្ចប្រជុំរៀបចំកម្មវិធីវិនិយោគបីឆ្នាំរំកិលនៃស្រុករបស់ខ្លួន។
- **ពិនិត្យ និងអនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល៖** ក្រុមប្រឹក្សាស្រុកត្រូវមានមូលដ្ឋានក្នុងការពិនិត្យ និង អនុម័តកម្មវិធីវិនិយោគបីឆ្នាំរំកិល ។
- **ពិនិត្យ និងអនុម័តលើសំណើតម្រូវការកម្មវិធីវិនិយោគបីឆ្នាំរំកិលក្នុងករណីចាំបាច់៖** ដូចគ្នានឹងផែនការអភិវឌ្ឍប្រាំឆ្នាំដែរកម្មវិធីវិនិយោគបីឆ្នាំរំកិលជាកម្មវត្ថុនៃការកែសម្រួលដោយយោងទៅតាមស្ថានភាពចាំបាច់ សំដៅឆ្លើយតបទៅនឹងផែនការអភិវឌ្ឍន៍មូលដ្ឋាន និងការបំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋបានច្រើនបំផុត។ សេចក្តីស្នើផែនការអិវឌ្ឍន៍នេះត្រូវអនុម័តតាមរយៈកិច្ចប្រជុំក្រុមប្រឹក្សាដោយសម្លេងឆ្នោតគាំទ្រលើសពីពាក់កណ្តាលនៃសមាជិកទាំងអស់របស់ក្រុមប្រឹក្សាស្រុក។
- **តាមដាន និងវាយតម្លៃលើការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិល ៖** ក្រុមប្រឹក្សាត្រូវចាត់ចែងឱ្យមានការតាមដានជាប្រចាំពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីវិនិយោគបីឆ្នាំរំកិលនិងត្រូវត្រួតពិនិត្យផ្តល់យោបល់លើបញ្ហាប្រឈមនានា ដើម្បីធានាឱ្យកម្មវិធីវិនិយោគបីឆ្នាំរំកិលត្រូវបានអនុវត្តយ៉ាងមានប្រសិទ្ធភាព។

### ២.៧.៤ ដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់រដ្ឋបាលស្រុក

ខាងក្រោមនេះ ជាសេចក្តីសង្ខេបនៃដំណើរការរៀបចំ និងកសាងផែនការអភិវឌ្ឍន៍ប្រាំឆ្នាំរបស់រដ្ឋបាលស្រុកដែលមាន៣ជំហាន ដូចខាងក្រោម៖

***ជំហានទី១*** ៖ ការរៀបចំនិងផ្សព្វផ្សាយស្តីពីការរៀបចំផែនការអភិវឌ្ឍន៍ស្រុកជំហាននេះមានដំណាក់កាលឬសកម្មភាពដូចខាងក្រោម៖

- ដំណាក់កាលមុនកិច្ចប្រជុំផ្សព្វផ្សាយ
- ដំណាក់កាលក្រោយប្រជុំផ្សព្វផ្សាយ
- ដំណាក់ក្រោយពេលកិច្ចប្រជុំផ្សព្វផ្សាយ

***ជំហានទី២ ៖*** ការរៀបចំ និងការចងក្រងសេចក្តីព្រាងផែនការអភិវឌ្ឍន៍រាជធានី ជំហាននេះមានដំណាក់កាលឬសកម្មភាពដូចខាងក្រោម ៖

- ការវិភាគស្ថានភាព
- ការរៀបចំសេចក្តីព្រាងក្របខ័ណ្ឌអភិវឌ្ឍន៍
- ការរៀបចំកម្មវិធីអភិវឌ្ឍមូលដ្ឋានរយៈពេលប្រាំឆ្នាំ
- ការរៀបចំក្របខណ្ឌចំណាយរយៈពេលមធម្យម
- ការពិនិត្យ និងការផ្តល់យោបល់នៃគណៈអភិបាល

- ការពិនិត្យ និងកម្មវិធីសម្រេចលើសេចក្តីព្រាងក្របខណ្ឌអភិវឌ្ឍ និងកម្មវិធីអភិវឌ្ឍមូលដ្ឋាន
- ការរៀបចំក្របខ័ណ្ឌតាមដាន និងវាយតម្លៃ
- ការរៀបចំក្របខ្លឹមសារស្ថានភាពសេដ្ឋកិច្ចសង្គមកិច្ច
- ការចងក្រងសេចក្តីព្រាងសៀវភៅផែនការអភិវឌ្ឍ
- កិច្ចប្រជុំពិគ្រោះយោបល់លើសេចក្តីផែនការអភិវឌ្ឍ
- ការពិនិត្យ និងផ្តល់យោបល់។

***ជំហានទី៣ ៖*** ការពិនិត្យអនុម័ត និងការផ្សព្វផ្សាយផែនការអភិវឌ្ឍន៍ស្រុក ជំហាននេះមានបីដំណាក់កាលឬសកម្មភាពដូចខាងក្រោម៖

- ការអនុម័តផែនការអភិវឌ្ឍន៍ស្រុក
- ការបោះពុម្ពនិងការផ្សព្វផ្សាយសៀវភៅផែនការអភិវឌ្ឍន៍ស្រុក។

**២.៧.៥ ដំណើរការរៀបចំ និង ការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល**

ខាងក្រោមនេះ ជាសេចក្តីសង្ខេបនៃដំណើរការរៀបចំ និងការកសាងផែនការវិនិយោគបីឆ្នាំរំកិលរបស់ស្រុកមេមត់ ដែលមានបីជំហានដូចខាងក្រោម ៖

***ជំហានទី១៖*** ការប្រមូលព័ត៌មានស្តីពីតម្រូវការរបស់មូលដ្ឋានសម្រាប់កសាងកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុក ជំហាននេះមានសកម្មភាពដូខខាងក្រោម ៖

- ប្រជុំណែនាំអំពីការប្រមូលតម្រូវការអទិភាព
- ប្រជុំបូកសរុប និងរៀបបញ្ជី គម្រោង និងសកម្មភាពអាទិភាព

***ជំហានទី២ ៖*** ការរៀបចំសេចក្តីព្រាងសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិលរបស់ស្រុកជំហាននេះមានសកម្មភាពដូចខាងក្រោម ៖

- កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីណែនាំស្តីពីការរៀបចំ និងការកសាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ពិនិត្យ និងចាត់អាទិភាពគម្រោងសកម្មភាពនៃកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការចូលរួមសិក្ខាសាលាសមាហរណកម្មនៅតាមបណ្តាស្រុក
- ចងក្រងសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការរៀបចំការតាមដាន និងការវាយតម្លៃការអនុវត្តកម្មវិនិយោគបីឆ្នាំរំកិល។

***ជំហានទី៣ ៖*** ការពិនិត្យអនុម័ត និងការផ្សាព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ជំហាននេះមានសកម្មភាពដូចខាងក្រោម៖

- កិច្ចប្រជុំពិនិត្យ និងអនុម័តសេចក្តីព្រាងកម្មវិធីវិនិយោគបីឆ្នាំរំកិល
- ការផ្សព្វផ្សាយសៀវភៅកម្មវិធីវិនិយោគបីឆ្នាំរំកិល ។

## ២.៨ ថវិការបស់រដ្ឋបាលស្រុក

ស្រុកត្រូវមានថវិកាផ្ទាល់របស់ខ្លួនដែលហៅថា ថវិការដ្ឋបាលថ្នាក់ក្រោមជាតិ។ ការគ្រប់គ្រង និងការអនុវត្ត ថវិកាប្រចាំឆ្នាំ ត្រូវផ្អែកតាមច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ដែលរៀបចំឡើងស្របតាមច្បាប់[47]។

**ចំណូលដែលរដ្ឋបាលស្រុកបានទទួលមានដូចជា៖**

- ចំណូលសារពើពន្ធ
- ផលទុននៃទ្រព្យសម្បត្តិរដ្ឋ
- ផលទុននៃការជួលទ្រព្យសម្បត្តិរដ្ឋនិងសេវា
- ការឧបត្ថម្ភអំណោយ
- ចំណូលនៃមូលនិធិបម្រុង
- ឧបត្ថម្ភធនវិនិយោគ។

**ការអនុវត្តចំណាយដែលរដ្ឋបាលស្រុកបានចំណាយមានដូចជា៖**

- ការទិញ
- សេវា
- អត្ថប្រយោជន៍សង្គម
- ពន្ធ និងអាករ
- បន្ទុកបុគ្គលិក
- ឧបត្ថម្ភធន និងជំនួញសង្គម
- បន្ទុកហិរញ្ញវត្ថុ
- បន្ទុកពិសេស
- ទាយជ្ជទានឱ្យដល់រលោះ
- អចលនកម្មរូបី
- ចំណាយមិនបានគ្រោងទុក

[47] មាត្រា ៤៤ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ,២០០៨

# ជំពូក ៣
# ការសិក្សាលើរបកគំហើញ

## ៣.១ ការងាររដ្ឋបាល

### ៣.១.១ ការងារលិខិតស្នាម និងឯកសារប្រជាពលរដ្ឋ

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ អាជ្ញាធរគ្រប់លំដាប់ថ្នាក់, អង្គភាពប្រដាប់អាវុធទាំងបី, ការិយាល័យជុំវិញស្រុក បានខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងយកចិត្តទុកដាក់ខ្ពស់ ដោយអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងទិសដៅរបស់ខេត្ត ក្រសួងមហាផ្ទៃ និងក៏ដូចជាខ្សែបណ្ដោយនីមួយៗ សម្រេចបានគួរជាទីមោទន។ ជាពិសេសក្នុងការលើកកម្ពស់ ការផ្ដល់សេវាសាធារណៈបានល្អប្រសើរ។ ជាក់ស្តែងគឺបានដាក់ចេញនូវៈ ដីការចំនួន៤៥ច្បាប់, សេចក្ដីសម្រេចចំនួន១៥៤ច្បាប់, លិខិតរដ្ឋបាលផ្សេងៗទៀតចំនួន ១៦,៩៨១ច្បាប់បានទទួលលិខិតរដ្ឋបាលចូលចំនួន ៥,៥១៥ និង សៀវភៅស្នាក់នៅចំនួន៦,៤០០ (មានលម្អិតក្នុងតារាងទី១)[48]។

**តារាងទី១៖ លិខិតស្នាម និងឯកសារប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ដីការដែលបានដាក់ចេញ | ១៨ | ១១ | ០៤ | ០៩ | ០៣ | ៤៥ |
| ២ | សេចក្ដីសម្រេចដែលបានដាក់ចេញ | ២៦ | ៣៤ | ៣៦ | ២២ | ៣៦ | ១៥៤ |
| ៣ | លិខិតដែលបានដាក់ចេញ | ១,៧២០ | ២,៧៣០ | ៣,៤០៣ | ៣,៩៣៨ | ៥,១៩០ | ១៦,៩៨១ |
| ៤ | លិខិតដែលបានទទួល | ១,១៦៩ | ១,១៨០ | ១,០៨៨ | ១,២១៧ | ៨៦១ | ៥,៥១៥ |
| ៥ | សៀវភៅស្នាក់នៅ | ៤៤៥ | ៦១៤ | ៤,៤៥៥ | ២២២ | ៦៦៤ | ៦,៤០០ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

### ៣.១.២. ការគ្រប់គ្រងប្រជាពលរដ្ឋ

ការគ្រប់គ្រងប្រជាពលរដ្ឋក្នុងរយៈពេល៥ឆ្នាំនេះរួមមាន៖ គ្រួសារសរុប ៣៤,០៨៩គ្រួសារ ក្នុងនោះគ្រួសារអចិន្ត្រៃយ៍សរុប ៣៣,៧២៤គ្រួសារ គ្រួសារបណ្ដោះអាសន្ន ៣៦៥គ្រួសារ។ ប្រជាពលរដ្ឋសរុប ១៥៧,១៦៦នាក់ ស្រី ៧៩,៩៨០នាក់, អាយុ១៨ឆ្នាំឡើង ៨៩,១១៣នាក់[49]។

---

[48] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨

[49] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨

- **ប្រជាពលរដ្ឋចំណាកស្រុក៖** សរុប ៣៦៧៣នាក់ ស្រី១៨១២នាក់[50] ក្នុងនោះ

  ១. ចំណាកស្រុកក្រៅប្រទេស (មិនដឹងទៅប្រទេសណាខ្លះ)

  - ស្របច្បាប់ ១១៣២នាក់ ស្រី៥៣១នាក់
  - មិនស្របច្បាប់ ៩១នាក់

  ២. ចំណាកស្រុកក្នុងប្រទេស ចំនួន ២៤៥០នាក់ ស្រី១១៩០នាក់

- **អន្តោប្រវេសន៍ជនជាតិវៀតណាម៖** មានចំនួន ៥៣គ្រួសារ មនុស្សរួម ៩៧នាក់ ក្នុងនោះ ស្រី៤៨នាក់, អាយុ ១៨ឆ្នាំឡើង ៨០ឆ្នាំឡើង ៨០នាក់ ស្រី ៣៣នាក់ មុខរបរ ៖ លក់ដូរ និងជាងសំណង់។
- **ខ្មែរកម្ពុជាក្រោម៖** មានចំនួន ១៨គ្រួសារ មនុស្សរួម ៦៦នាក់ ក្នុងនោះ ស្រី ៣៥នាក់, អាយុ១៨ឆ្នាំឡើង ៥៣ នាក់ ស្រី ៣៧នាក់។

**តារាងទី២៖ ការគ្រប់គ្រងប្រជាពលរដ្ឋ**

| ល.រ | ការបរិយាយ | ចំនួន |
|---|---|---|
| ១ | សរុបគ្រួសារ | ៣៤,០៨៩ |
| ២ | គ្រួសារអចិន្ត្រៃយ៍ | ៣៣,៧២៤ |
| ៣ | គ្រួសារបណ្តោះអាសន្ន | ៣៦៥ |
| ៤ | ប្រជាពលរដ្ឋសរុប | ១៥៧,១៦៦ |
| ៥ | ប្រជាពលរដ្ឋជាស្ត្រី | ៧៩,៩៨០ |
| ៦ | ប្រជាពលរដ្ឋដែលមានអាយុ១៨ឆ្នាំឡើង | ៨៩,១១៣ |
| ៧ | ប្រជាពលរដ្ឋចំណាកស្រុក | ៣,៦៧៣ |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

### ៣.១.៣.ការខារអត្រានុកូលដ្ឋាន

ក្នុងរយៈពេលមួយអាណត្តិទី២នេះរដ្ឋបាលស្រុកបានចេញសេចក្តីចម្លងសំបុត្រកំណើត៤៧១ច្បាប់, , សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ១៣,១៩៣ច្បាប់, សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍១៤៤ច្បាប់ និង សេចក្តីចម្លងសំបុត្រមរណភាពចំនួន៤៨ច្បាប់ជូនប្រជាពលរដ្ឋសម្រាប់ប្រើប្រាស់តាមសេចក្តីត្រូវការដែលមានដូចក្នុងតារាងខាងក្រោម៖

[50] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨

**តារាងទី៣៖ ការចេញសេចក្តីចម្លងសំបុត្រអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន(ច្បាប់) | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | សេចក្តីចម្លងសំបុត្រកំណើត | ១៨ | ២០ | ៦០ | ៨៩ | ២៨៤ | ៤៧១ |
| ២ | សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត | ១,១៧៧ | ២,១៥២ | ២,១០១ | ៣,០៣៣ | ៤,៧២៦ | ១៣,១៩៣ |
| ៣ | សេចក្តីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ០៨ | ០៥ | ១០ | ៤៣ | ៧៨ | ១៤៤ |
| ៤ | សេចក្តីចម្លងសំបុត្រមរណភាព | ០៦ | ០៩ | ០៤ | ០៩ | ២០ | ៤៨ |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

**៣.១.៤ ការផ្សព្វផ្សាយព័ត៌មាន ទំនាក់ទំនងសាធារណៈ និងសហប្រតិបត្តិការអន្តជាតិ**

ក្នុងរយៈពេល៥ឆ្នាំនេះអាជ្ញាធរស្រុកតែងតែរៀបចំកិច្ចប្រជុំនិងជួបពិភាក្សាផ្លាស់ប្តូរយោបល់ផ្តល់ព័ត៌មានឲ្យគ្នាទៅវិញទៅមក និងបានពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអាជ្ញាធរ ស្ថាប័ន ថ្នាក់ស្រុក ថ្នាក់ឃុំ និងតាមបណ្តាសមត្ថកិច្ចពាក់ព័ន្ធ ដើម្បីទប់ស្កាត់នូវបទល្មើសទំនិញខុសច្បាប់ផ្សេងៗ។ ល.។ ក៏ដូចជាការបង្ករលក្ខណៈងាយស្រួលក្នុងទំនាក់ទំនងសាមគ្គីភាពបងប្អូនជាប់ព្រំដែនគ្នា ( កម្ពុជា-វៀតណាម ) ដោយមិនធ្វើឲ្យប្រជាពលរដ្ឋជួបការលំបាកឈរលើស្មារតីទទួលខុសត្រូវបានល្អប្រសើរ។

**៣.១.៥ ការងារគណៈអភិបាល**

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះរដ្ឋបាលស្រុកបានរៀបចំកិច្ចប្រជុំអឌ្ឍមាសរបស់គណៈអភិបាលចំនួន៧៦លើក និងកិច្ចប្រជុំប្រចាំខែរបស់គណៈអភិបាលចំនួន ៦០លើក ដូចមានលម្អិតក្នុងតារាងទី៤៖

**តារាងទី៤៖ កិច្ចប្រជុំគណៈអភិបាល**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | កិច្ចប្រជុំអឌ្ឍមាសរបស់គណអភិបាល | ១៣ | ១២ | ១៥ | ១៧ | ១៩ | ៧៦ |
| ២ | កិច្ចប្រជុំប្រចាំខែរបស់គណៈអភិបាល | ១២ | ១២ | ១២ | ១២ | ១២ | ៦០ |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

### ៣.១.៦ ការងារក្រុមប្រឹក្សា និងគណៈកម្មាធិការនានា

ក្នុងអាណត្តិទី២នេះក្រុមប្រឹក្សាស្រុក និងគណៈកម្មាធិការនានាបានអនុវត្តតួនាទីរបស់ខ្លួនរួមមានៈ ប្រជុំសាមញ្ញចំនួន ៥៥លើក ប្រជុំវិសាមញ្ញចំនួន ២០លើក,កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស ៥ លើក និងគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារចំនួន ៥៤លើក ដូចមាននៅក្នុងតារាងខាងក្រោមៈ

**តារាងទី៥៖ កិច្ចប្រជុំក្រុមប្រឹក្សា និងគណៈកម្មាធិការនានា**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ៧ | ១២ | ១២ | ១២ | ១២ | ៥៥ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ៣ | ៦ | ៣ | ២ | ០៦ | ២០ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ០ | ០ | ០ | ០ | ០ | ០ |
| ៤ | កិច្ចប្រជុំគណៈកម្មាធិការសម្របសម្រួលបច្ចេកទេស | ០ | ០ | ២ | ១ | ២ | ៥ |
| ៥ | កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារ | ៦ | ១២ | ១២ | ១២ | ១២ | ៥៤ |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

### ៣.១.៧. ការងាររៀបចំវេទិការ

ក្នុងរយៈពេល៥ឆ្នាំកន្លងមកនេះក្រុមប្រឹក្សាស្រុក បានអនុវត្តតួនាទីភារកិច្ចទៅតាមច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ដែលក្នុងនោះ ក្រុមប្រឹក្សាស្រុកមេមត់ បានរៀបចំវេទិការផ្សព្វផ្សាយ និងពិគ្រោះយោបល់ជាមួយប្រជាពលរដ្ឋចំនួន ៤លើក ប្រជាពលរដ្ឋចូលរួមសរុបមានចំនួន១១១៤នាក់ ប្រជាពលរដ្ឋជាស្រីដែលបានចូលរួមមានចំនួន៤៨៥នាក់ ក្នុងគោលបំណង ដើម្បីផ្សព្វផ្សាយពីសមិទ្ធផលនានាដែលក្រុមប្រឹក្សាស្រុកសម្រេចបាននិងដើម្បីពិភាក្សាពិគ្រោះយោបល់ពីតម្រូវការអាទិភាពនានាដែលប្រជាពលរដ្ឋត្រូវការ។ក្រៅពីនេះគណៈអភិបាលបានរៀបចំវេទិការគោលនយោបាយភូមិឃុំមានសុវត្ថិភាពបានជាច្រើនលើកដែលផ្តោតសំខាន់លើកត្តា៩ចំណុចជាសំខាន់។

**តារាងទី៦៖ ការរៀបចំវេទិការ**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ការរៀបចំវេទិកាសាធារណៈ | ០ | ១ | ១ | ១ | ០១ | ០៤ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ២ | ប្រជាពលរដ្ឋសរុបដែលបានចូលរួម | 0 | ២៥០ | ៣៧២ | ២៤១ | ២៥១ | ១១១៤ |
| ៣ | ប្រជាពលរដ្ឋជាស្ត្រីដែលបានចូលរួម | 0 | ៩៥ | ៩៧ | ១៤៣ | ១៥០ | ៤៨៥ |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

## ៣.២. ការងារផែនការ និងការគាំទ្រឃុំ

### ៣.២.១. ការកសាងផែនការអភិវឌ្ឍន៍ និងកម្មវិធីវិនិយោគ

ក្រុមប្រឹក្សាស្រុកមេមត់បានរៀបចំសៀវភៅផែនការ៥ឆ្នាំ ចំនួន១ដង ពីឆ្នាំ២០១៥-២០១៩ និងបានរៀបចំសៀវភៅកម្មវិធីវិនិយោគ៣ឆ្នាំរំកិលចំនួន៤ដង (ទី១, ចាប់ពីឆ្នាំ២០១៥-២០១៧ ទី២, ចាប់ពីឆ្នាំ២០១៦-២០១៨ ទី៣, ចាប់បីឆ្នាំ២០១៧-២០១៩ និងទី៤, ចាប់ពីឆ្នាំ២០១៨-២០២០) ដោយមានការពិគ្រោះយោបល់ពីគណៈកម្មាធិការសម្របសម្រួលបច្ចេកទេសស្រុក និងគណៈអភិបាលស្រុក និងចុងក្រោយត្រូវបានពិនិត្យ និងអនុម័តដោយក្រុមប្រឹក្សាស្រុក។ គម្រោង និងថវិកាវិនិយោគត្រូវបែងចែកជា៤ផ្នែក គឺមានផ្នែកទី១៖ សេដ្ឋកិច្ច, ផ្នែកទី២៖ សង្គមកិច្ច, ផ្នែកទី៣៖ គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ គ្រោះមហន្តរាយ និងផ្នែកទី៤៖ មានដូចជា រដ្ឋបាលសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ។ លើសពីនេះ នៅពេលសមាហរណកម្មនៅថ្នាក់ស្រុកក៏មានការគាំទ្រពីមន្ទីរនានា អង្គការដៃគូសប្បុរសជននានា និងការិយាល័យជំនាញនានាក្នុងនោះមាននៅឆ្នាំ២០១៤សរុបមានចំនួន ២០ គម្រោង សរុបថវិកាមានចំនួន ១,៦៣៩,៩៤០,000រៀល, ឆ្នាំ២០១៦ សរុបមាន ១៧គម្រោង សរុបថវិកាមានចំនួន ៣,៦៨១,៤៧០,000រៀល, ឆ្នាំ២០១៧ សរុបមាន ៣៦គម្រោង សរុបថវិកាមានចំនួន ៦,៨១៥,០៩៦,000រៀល និងឆ្នាំ២០១៨ សរុបមាន ៣៦គម្រោង សរុបថវិកាចំនួន ៦,៨១៥,០៩៦,000រៀល។

ដោយឡែកការវិភាជន៍ថវិកាដល់រដ្ឋបាលស្រុកនីមួយៗទើបតែមាននៅចុងឆ្នាំ២០១៤សម្រាប់ឆ្នាំ២០១៥ ហើយចំពោះឆ្នាំ២០១៦ រដ្ឋបាលខេត្តបានផ្តល់ថវិកាគុណប្រយោជន៍ខេត្ត ដល់រដ្ឋបាលស្រុកនីមួយៗផងដែរ។

**តារាងទី៧៖ ចំនួនគម្រោង និងថវិកាដែលគ្រោងវិនិយោគ**

| ល.រ | ការបរិយាយ | ចំនួនគម្រោង និងថវិកាវិនិយោគ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៤ | | ២០១៥ | | ១០១៦ | | ២០១៧ | | ២០១៨ | | សរុប |
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | |
| ១ | សេដ្ឋកិច្ច | 05 | 954.44 | 0 | 0 | 10 | 1350.5 | 7 | 1,721,646 | 7 | 1,721 | |
| ២ | សង្គមកិច្ច | 07 | 380.74 | 0 | 0 | 16 | 674.67 | 15 | 917,450 | 15 | 917,450 | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | 4 | 114.06 | 0 | 0 | 7 | 1608.8 | 11 | 4,086 | 11 | 4,068 | |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 4 | 160.7 | 0 | 0 | 5 | 47.5 | 3 | 90 | 3 | 90 | |
| សរុប | | 20 | 1,639.94 | 0 | 0 | 17 | 3,681.47 | 36 | 6,815,096 | 36 | 6,815,096 | |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

<u>ចំណាំ៖ ថវិកាដែលគ្រោងវិនិយោគគិតជាលានរៀល</u>

### ៣.២.២ ការអនុវត្តគម្រោងវិនិយោគ

ឆ្លើយតបទៅនឹងការរៀបចំគម្រោងថវិកា និងគម្រោងវិនិយោគតាមឆ្នាំនីមួយៗ ត្រូវបានប្រើប្រាស់ពីប្រភពថវិការបស់ស្រុកផ្ទាល់ ឬថវិកាពីដៃគូអភិវឌ្ឍនានា ដែលត្រូវបានរាប់បញ្ចូលតាមផ្នែកនីមួយៗ។ ជាងនេះក៏មានការគាំទ្រពីមន្ទីរនានានិងការិយាល័យជំនាញក្នុងស្រុកដោយបានគាំទ្រសកម្មភាពរបស់ខ្លួនដល់រដ្ឋបាលស្រុកមេមត់។

**តារាងទី៨៖ ចំនួនគម្រោង និងថវិកាដែលបានអនុវត្តជាក់ស្តែង**

| ល.រ | ការបរិយាយ | ចំនួនគម្រោង និងថវិកាដែលបានអនុវត្ត | | | | | | | | | | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០១៤ | | ២០១៥ | | ១០១៦ | | ២០១៧ | | ២០១៨ | | |
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | |
| ១ | សេដ្ឋកិច្ច | 0 | 0 | ២ | ២៤៥.៤ | ២ | ១៩៦.១០១ | ១ | ២៥៧.៦៩៣ | ៣ | ៤៧៤.៦៩៥ | |
| ២ | សង្គមកិច្ច | 0 | 0 | ៦ | ៤៩៣.០៩០ | ២ | ២៤.០៨៥ | ២ | ៤៧.១៦៨ | ១២ | ២៣៩.៣០៦ | |
| ៣ | គ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |

| | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | រដ្ឋាបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | 0 | |
| សរុប | | 0 | 0 | ៨ | ៧៣៨.៥៥០ | ៤ | ១៧០.១៥៥ | ៣ | ៣០៤.៥៦១ | ១៥ | ៧១៤.០០១ | |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

<u>ចំណាំ៖ ថវិកាគិតជាលានរៀល</u>

### ៣.២.៣. ការគាំទ្រឃុំ

ជាមួយនឹងការគាំទ្រទៅដល់ឃុំ ស្រុកមានការិយាល័យផែនការ និងគាំទ្រឃុំ ដែលជាការិយាល័យចំណុះរបស់សាលាស្រុក ដើម្បីជួយសម្របសម្រួលជាមួយក្រុមប្រឹក្សាឃុំ ក្នុងការរៀបចំផែនការ៥ឆ្នាំ របស់ក្រុមប្រឹក្សាឃុំចំនួន ១ដង នៃអាណត្តិទី៣ (ពីឆ្នាំ ២០១៣-២០១៧) និងកម្មវិធីវិនិយោគ ៣ឆ្នាំរំកិលបានចំនួន ៥ដង (ទី១, ពីឆ្នាំ ២០១២-២០១៤ ទី២, ពីឆ្នាំ ២០១៣-២០១៥ និងទី៣, ពីឆ្នាំ២០១៤-២០១៦) [51]។ ក្រៅពីនេះ ដោយមានការិយាល័យផែនការនិងគាំទ្រឃុំ បានជួយសម្របសម្រួលរៀបចំផែនការថវិកាប្រចាំឆ្នាំរបស់ឃុំរៀបចំការបិទបញ្ជីថវិកាប្រចាំឆ្នាំ។ សម្របសម្រួលរៀបចំការបង្កើតគណៈកម្មាការគ្រប់គ្រងគម្រោង គណៈកម្មាការលទ្ធកម្ម និងការសិក្សា និងត្រួតពិនិត្យគម្រោង។ ជួយសម្របសម្រួលរៀបចំផែនការថវិកា និងផែនការសកម្មភាពប្រចាំឆ្នាំរបស់ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំដំណើរការបានល្អ និងគណៈកម្មាធិការកសាងផែនការ និងថវិកាឃុំ។

## ៣.៣ ការងារហិរញ្ញវត្ថុ

### ៣.៣.១ ការអនុវត្តចំណូល និងចំណាយ

រដ្ឋបាលស្រុកមេមត់រយៈពេល៥ឆ្នាំនេះបានទទួលថវិកា និងអនុវត្តថវិកា ដូចមានក្នុងតារាងខាងក្រោម៖

**តារាងទី៩៖ ចំណូល ចំណាយ**

| ឆ្នាំ | ចំណូល (គិតជាលានរៀល) | | | ចំណាយ (គិតលានរៀល) | | |
|---|---|---|---|---|---|---|
| | អនុម័ត | ជាក់ស្តែង | % | អនុម័ត | ជាក់ស្តែង | % |
| ២០១៤ | ៤៥២,១០០,០០០៛ | ៤៥១,៤២០,០០០៛ | ៩៩.៨៥ | ៤៥២,១០០,០០០៛ | ៤៣៨,១៦១,០០០៛ | ៩៦.៩២ |
| ២០១៥ | ៦៦៣,០៧០,០០៛ | ៦៥៦,២៤២,០០០៛ | ៩៨.៩៧ | ៦៦៣,០៧០,០០០៛ | ៦៣០,៨៤៧,២៥០៛ | ៩៥.១៤ |
| ២០១៦ | ៧៤៥,៩៩០,០០០៛ | ៧៤៤,៦៦៥,៦០០៛ | ៩៩.៨២ | ៧៦០,០៩០,០០០៛ | ៧៣០,៧០៦,០០០៛ | ៩៦.១៣ |
| ២០១៧ | ៩៨៩,០០០,០០០៛ | ៩៨៩,៧៩៥,៥២០៛ | ១០០.០៨ | ១,០១១,៣៧០,០០០៛ | ៩០២,២៥៤,៨៧០៛ | ៨៩.២១ |

[51] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨

| | | | | | | |
|---|---|---|---|---|---|---|
| ២០១៨ | ១,០៩៧,៦៦០,០០០៛ | ១,១២៥,៣០៧,០២០៛ | ១០២.៥២ | ១,១០៥,០៦០,០០០៛ | ១,០៩១,១៧០,៥៣០៛ | ៩៨.៧៤ |
| សរុប | ៣,៩៤៧,៨២០,០០០៛ | ៣,៩៦៧,៤០៣,១៤០៛ | ១០០.៤៩ | ៣,៩៩១,៦៩០,០០០៛ | ៣,៧៩៣,១៤០,៩៨០៛ | ៩៥.០២ |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

### ៣.៣.២ ការគ្រប់គ្រងទ្រព្យសម្បត្តិ

**តារាងទី១០៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ទ្រព្យសម្បត្តិដែលបានទិញ ឬទទួល(ថ្មី) | ១៨ | 0 | 0 | 0 | 0 | ១៨ |
| ២ | ទ្រព្យសម្បត្តិដែលបានកាត់ចេញ | 0 | 0 | 0 | 0 | 0 | 0 |
| ៣ | **ទ្រព្យសម្បត្តិសរុប** | **៦១** | **៦១** | **៦១** | **៦១** | **៦១** | |

*ប្រភព៖ របាយការបូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨*

## ៣.៤. ការខាររលទ្ធផល

- **ក្នុងឆ្នាំ២០១៤ ស្រុកបានរៀបចំដេញថ្លៃគម្រោង បានចំនួន ៣គម្រោងក្នុងនោះមាន[52]៖**
  - លទ្ធកម្មទំនិញដោយពិគ្រោះថ្លៃ (ពថ) ប្រេងឥន្ធនៈ៖ ដែលមានឥណទានក្នុងការធានាចំណាយសរុប ១៧,៩៩៦,០០០រៀល ហើយអនុវត្តជាក់ស្តែង បានចំនួន១៧,៣៤១,៦០០រៀល។
  - លទ្ធកម្មទំនិញដោយស្ទង់តម្លៃ (សត) គ្រឿងសង្ហារឹម៖ ដែលមានឥណទានក្នុងការធានាចំណាយសរុប ៤,៩៦០,០០០រៀល ហើយអនុវត្តជាក់ស្តែង បានចំនួន៤,៨៨០,០០០រៀល។
  - លទ្ធកម្មទំនិញដោយស្ទង់តម្លៃ (សត) សម្ភារៈបរិក្ខា៖ ដែលមានឥណទានក្នុងការធានាចំណាយសរុប ៦,០០០,០០០រៀល ហើយអនុវត្តជាក់ស្តែង បានចំនួន ៥,៩៥០,០០០រៀល។
- **ក្នុងឆ្នាំ២០១៥ ស្រុកបានរៀបចំដេញថ្លៃគម្រោងផ្លូវបេតុង ចំនួន២គម្រោងក្នុងនោះមាន៖**
  - ថវិកាស្រុក ១ខ្សែមានប្រវែង ២២៩ម ទទឹង ៦ម ថវិកាសរុប ១២៤,៨៣៨,៥០០រៀល
  - ថវិកាស៊ីជា ១ខ្សែមានប្រវែង ១៦៤ម ទទឹង ៥មនិងប្រឡាយ ២២៤ម ថវិកាសរុប ១១៤,៩៥០,៥០០៛
- **ក្នុងឆ្នាំ២០១៦នេះ ស្រុកបានអនុវត្តគម្រោងចំនួន ០៣រួមមាន៖**
  - កិច្ចលទ្ធកម្មប្រេងឥន្ធនៈចំនួន ២,៩២៦លីត្រ សរុបថវិកា ១១,៩៩៦,៦០០រៀល

[52] របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤-២០១៨

- កិច្ចលទ្ធកម្មគម្រោងជួសជុលប្រភពទឹកស្អាត (អណ្ដូងស្នប់ ២៥អណ្ដូង)សរុបថវិកា ២០,៤៨៤,០០០រ

- **ក្នុងឆ្នាំ២០១៧ ស្រុកបានអនុវត្តគម្រោងរួមមាន៖**

- បានពិគ្រោះថ្លៃប្រេងឥន្ធនៈ ១គម្រោង សម្រាប់ប្រើប្រាស់ឆ្នាំ២០១៧ ចំនួន ២,៨៥៧លីត្រ។
- រៀបចំវិធីសាស្ត្រស្ទង់ តម្លៃជួសជុលអគារសាលាស្រុក ប្រព័ន្ធទឹក និងបង្គន់អនាម័យ ១០គម្រោង។
- បានធ្វើផែនការលទ្ធកម្មប្រចាំឆ្នាំ២០១៧ របស់រដ្ឋបាលស្រុក មានចំនួន០៣គម្រោង សម្រាប់ អនុវត្ត។
- បានធ្វើការប្រជុំបើកសំណើរគម្រោងផ្លូវបេតុងប្រវែង ៥៣៨ម៉ែត្រ ០១គម្រោង ថវិការដ្ឋបាលស្រុក ឆ្នាំ២០១៧ ។

- **ក្នុងឆ្នាំ២០១៨ ស្រុកបានអនុវត្តគម្រោងមាន៖**

- បានពិគ្រោះថ្លៃប្រេងឥន្ធនៈ ១គម្រោង សម្រាប់ប្រើប្រាស់ឆ្នាំ២០១៨ ចំនួន ៣,២៥៥លីត្រ ។
- បានពិគ្រោះថ្លៃការងារជួសជុលផ្លូវបេតុង ០១គម្រោង ប្រវែង ៧៤ម៉ែត្រ នៅឃុំមេមត់ ។
- ស្ទង់តម្លៃជួសជុលអណ្ដូងទឹកស្អាត ០១គម្រោង ចំនួន ០៨អណ្ដូង ។
- ដេញថ្លៃការងារជួសជុលផ្លូវបេតុងប្រវែង ២៤៤ម៉ែត្រ ០១គម្រោង នៅឃុំមេមត់ ។

## ៣.៥ ការងារអន្តរវិស័យ

### ៣.៥.១. ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់

ក្នុងឆ្នាំ២០១៤ ដល់ ២០១៨នេះ បញ្ហាទំនាស់ដីធ្លីរវាងប្រជាពលរដ្ឋ និងក្រុមហ៊ុន រវាងប្រជាពលរដ្ឋនិងប្រជាពលរដ្ឋ និងទំនាស់ផ្សេងៗ អភិបាលស្រុក និងជាប្រធានគណៈកម្មការដោះស្រាយដីរដ្ឋថ្នាក់ស្រុក បានខិតខំរកគ្រប់នីតិវិធីផ្លូវច្បាប់ ដោយយកគោលការណ៍ឈ្នះ-ឈ្នះរបស់សម្ដេចតេជោជាកត្តាសំខាន់។ ជាក់ស្ដែងបានធ្វើការសម្របសម្រួលបញ្ចប់ចំនួន ១៥ករណី, សាមីខ្លួនស្នើសុំដកពាក្យ ០៩ករណី, បញ្ជូនឡើង ០២ករណី និងបានច្រានចោល ០១ករណី។

**តារាងទី១១៖ ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | ករណីដែលបានដោះស្រាយឬសម្រុះសម្រួលរួច | ០ | ០១ | ០១ | ០២ | ១១ | ១៥ |
| ២ | ករណីដែលាបានបញ្ជូនទៅស្ថាប័នពាក់ព័ន្ធ | ០ | ០ | ០ | ០១ | ០១ | ០២ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.៥.២. កិច្ចការសេវាសង្គម និងការបង្កើតសិទ្ធិអំណាចស្ត្រី

គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារ ដែលជាគណៈកម្មាធិការរបស់ក្រុមប្រឹក្សាស្រុកបានបង្កើនការយកចិត្តទុកដាក់ទៅលើការគាំទ្រផ្នែកសេវាសង្គមដូចជា៖ សុខភាពមាតា និងទារក, ច្បាប់អំពើហិង្សាក្នុងគ្រួសារ, ច្បាប់រំលោភបំពានផ្លូវភេទ, ការជួញដូរមនុស្ស ចំណាកស្រុក និងរៀបចំវគ្គបណ្តុះបណ្តាលក្រុមប្រឹក្សាឃុំ គ.ក.ន.ក និងគាំទ្រភ្នាក់ងារសុខភាពភូមិអោយមានសមត្ថភាព ក្នុងការផ្សព្វផ្សាយសុខភាពក្នុងសហគមន៍យ៉ាងផុសផុល។

**តារាងទី១២៖ ការអនុវត្តសកម្មភាពសេវាសង្គម និងការងាររបស់គ.ក.ស.ក**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០១៤ | ២០១៥ | ២០១៦ | ២០១៧ | ២០១៨ | សរុប |
| ១ | កិច្ចប្រជុំប្រចាំខែរបស់ គ.ក.ស.ក | ៦ | ១២ | ១២ | ១២ | ១២ | ៥៤ |
| ២ | ថវិកាគាំទ្រសកម្មភាពសេវាសង្គម និងការងាររបស់ គ.ក.ស.ក (លានរៀល) | ១ | ២ | ២ | ២ | ២ | ៩ |
| ៣ | វគ្គបណ្តុះបណ្តាលដែល គ.ក.ស.កបានទទួល | ២ | ២ | ២ | ៣ | ៦ | ១៥ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.៥.៣. ការងារគ្រប់គ្រងច្រកព្រំដែន

ស្រុកមេមត់ ជាស្រុកមួយក្នុងចំណោមក្រុង ស្រុកទាំង៧ នៃខេត្តត្បូងឃ្មុំ ដែលមានព្រំប្រទល់ជាប់នឹងសាធារណរដ្ឋសង្គមនិយមវៀតណាម និងមានច្រកទ្វារព្រំដែនចំនួន ០៦កន្លែង ក្នុងនោះមាន៖ ច្រកទ្វារព្រំដែនទ្វេភាគីចំនួន ០២គឺ ច្រកទ្វារទ្វេភាគីទន្លេចាម ឡុកធិញ (ឃុំជាំក្រវៀន) ០១កន្លែង និងច្រកទ្វារទ្វេភាគីដូង ៧ដើម (ឃុំដារ) ០១កន្លែង។ ច្រកទ្វារតំបន់មាន ០៤កន្លែង គឺច្រកទ្វារតំបន់ដូនរ័ត្ន(ឃុំរូង) ០១កន្លែង, ច្រកទ្វារតំបន់ចាន់មូល(ឃុំចាន់មូល) ០១កន្លែង, ច្រកទ្វារតំបន់សាទុំ ឃុំជាំក្រវៀន ០១កន្លែង និងច្រកទ្វារតំបន់ទន្លូង(ឃុំទន្លូង) ០១កន្លែង។

ការគ្រប់គ្រង ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ អាជ្ញាធរស្រុក តែងខិតខំបង្កើននូវកិច្ចសហប្រតិបត្តិការបានយ៉ាងល្អជាមួយអាជ្ញាធរស្រុក ឃុំ និងសមត្ថកិច្ចពាក់ព័ន្ធនៅជាប់ព្រំដែនភូមិផងរបងជាមួយ ជាពិសេសកិច្ចសហការជាមួយប៉ុស្តិ៍ អង្គភាពព្រំដែនតាមរយៈកិច្ចប្រជុំ ដកពិសោធន៍ធ្វើឲ្យសន្តិសុខ សណ្តាប់ធ្នាប់តាមបន្ទាត់ព្រំដែន ក៏ដូចជាការសម្រួលការនាំចេញ នាំចូលកសិផលទៅលក់ឆ្លងប្រទេសដំណើរការបានយ៉ាងប្រសើរ។

## ៣.៦. ការងាររបស់ការិយាល័យ អង្គភាពជំនាញ

### ៣.៦.១ សេដ្ឋកិច្ច

### ៣.៦.១.១ ការងារ កសិកម្ម

*<u>ការងារបង្កបង្កើនផល</u>*

១. ការងារបង្កបង្កើនផលរដូវប្រាំង

- ស្រូវ៖ អនុវត្តបាន ៥២០ ហ.ត= ១០៤% នៃផែនការចំនួន ៥០០ ហ.ត
- ដំណាំរួមផ្សំ (បន្លែ)៖ អនុវត្តបាន ២៥ ហ.ត = ១២៥% នៃផែនការចំនួន ២០ ហ.ត

***<u>ការងារបង្កបង្កើនផលរដូវវស្សា</u>***

- ស្រូវ៖ អនុវត្តបាន ៧៣៣០ ហ.ត= ១០០% នៃផែនការចំនួន ២០ ហ.ត
- ដំណាំរួមផ្សំ៖ អនុវត្តបាន ២២,១៩០ ហ.ត= ១០០.០៩% នៃផែនការចំនួន ២,២១៧០ហ.ត។ ក្នុងនោះមាន៖
  - ពោត ៥៨០ ហ.ត (ពោតក្រហម ២៣០ ហ.ត)
  - ដំឡូងមី ១៩,៩៦០ ហ.ត
  - សណ្តែកដី ២៥០ ហ.ត
  - អំពៅ ២៨០ ហ.ត
  - បន្លែគ្រប់មុខ ៤៨០ ហ.ត
  - សណ្តែកបាយ ២៨០ ហ.ត
  - សណ្តែកសៀង ៣៦០ ហ.ត

**<u>ដំណាំអចិន្ត្រៃយ៍</u>៖** ដំណាំម្រេចអនុវត្តបាន ១,២០៣ ហ.ត, ដំណាំកៅស៊ូគ្រួសារ ២,០៧៥ ហ.ត, ដំណាំស្វាយចន្ទី ១,៥០៥ ហ.ត, ស្វាយហូបផ្លែ ១៧៩ ហ.ត, ដំណាំចេក ១៦៨ ហ.ត, ដំណាំធុរេន ៣២៦ ហ.ត, ដំណាំខ្នុរ ២១៨ ហ.ត, ដំណាំទៀប ៤ ហ.ត, ដំណាំមង្ឃុត ៨៨ ហ.ត, ដំណាំសាវម៉ៅ ២១៣ ហ.ត ។

**<u>ផ្នែកផលិតកម្ម និងបសុព្យាបាល</u>៖** ភ្នាក់ងារពេទ្យសត្វភូមិចុះបាញ់ថ្នាំការពារជម្ងឺផ្តាសាយបក្សី និងវ៉ាក់សាំងអុតក្តាម ដល់សត្វគោ ក្របី និងចុះត្រួតពិនិត្យ តាមដានសុខភាពនៅតាមបណ្តាភូមិ និងសត្តឃាតដ្ឋាន ហើយបានចុះផ្សព្វផ្សាយ និងធ្វើឡជីវៈឧស្ម័ន។ សហការជាមួយអង្គការនានាបើកវគ្គបណ្តុះបណ្តាលស្តីពីការចិញ្ចឹមមាន់ និងសហការជាមួយអង្គការមួយចំនួនទៀតបានជាច្រើន។

**<u>ការងារផ្សព្វផ្សាយ</u>៖** ចុះត្រួតពិនិត្យការតាំងលក់ថ្នាំកសិកម្មនៅផ្សារដារ និងផ្សារមេមត់បានចំនួន ៣២លើក និងបានបើកវគ្គបណ្តុះបណ្តាលដល់អាជីវករលក់សម្ភារៈកសិកម្មបានចំនួន ១០វគ្គ។

### ៣.៦.២. ការអភិវឌ្ឍន៍

- ក្រសួងបានធ្វើការសាងសង់ផ្លូវក្រាលកៅស៊ូចំនួន ០៤ខ្សែ រួមមាន៖
  - ខ្សែទី១ ពីផ្លាកសំរោង ទៅភូមិកំពាន់ ប្រវែង ២២គ.ម
  - ខ្សែទី២ ពីភូមិកំបាស់ ទៅវាលតូច ស្រុកតំបែរ ប្រវែង ៤៤គ.ម
  - ខ្សែទី៣ ពីវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ ទៅច្រកទ្វារដូនរ័ត្ន ឃុំរូង ប្រវែង ១០គ.ម
  - ខ្សែទី៤ ពីផ្លូវជាតិលេខ៧ កែងប៉ុស្តិ៍ទិស ទៅឃុំដារ ប្រវែង ១៣គ.ម
- មន្ទីរអភិវឌ្ឍបានធ្វើការជួសជុលផ្លូវក្រាលគ្រួសក្រហម ចំនួន ០៣ខ្សែ រួមមាន៖
  - ខ្សែទី១ ពីជាំទៀក ឃុំត្រមូង ទៅឃុំជាំតាម៉ៅ ប្រវែង ១០គ.ម
  - ខ្សែទី២ ពីភូមិតាម៉ៅកើត ទៅទួលគ្រួស ក្នុងឃុំជាំតាម៉ៅ ប្រវែង ១២០ម

- ខ្សែទី៣ ពីទន្លូង ទៅភូមិម្កោរ ក្នុងឃុំទន្លូង ប្រវែង ១១០០ម

- ប្រទេសឥណ្ឌាបានសាងសង់អណ្តូងស្នប់ចំនួន ២៣៦អណ្តូង ក្នុងនោះរួមមាន៖ ឃុំត្រមូង ៦៧អណ្តូង, ទន្លូង ៨០អណ្តូង,រូង ៤៤អណ្តូង និងឃុំជាំតាម៉ៅ ៤៥អណ្តូង។

### ៣.៦.៣. ការងារសាធារណៈការស្រុក

**ក. ផ្លូវខេត្តលេខ៣៧៣C**

ផ្លូវខេត្តលេខ៣៧៣ c ចាប់ពីផ្សារមេមត់ ទៅកំបាស់ មន្ទីរសាធារណៈការខេត្តត្បូងឃ្មុំ បានធ្វើការជួសជុលនៅចំណុចវាលស្រែមេមង ប្រវែង ១០០០ម ជួសជុលរួច១០០%។

**ខ. ផ្លូវលំគ្រួសក្រហម**

– ផ្លូវលំគ្រួសក្រហម ១ខ្សែ ស្ថិតនៅក្នុងឃុំជាំតាម៉ៅ ចាប់ពីគីឡូម៉ែត្រ៥៥ ដល់គីឡូម៉ែត្រ៦២ មានប្រវែង៧ គ.ម ជួសជុលដោយមន្ទីរសាធារណៈការខេត្តត្បូងឃ្មុំ បានហើយជាស្ថាបពរ។

– ផ្លូវលំគ្រួសក្រហម ១ខ្សែ ស្ថិតនៅក្នុងឃុំជាំក្រវៀន ចាប់ពីផ្លូវជាតិលេខ៧ ទៅដល់ឬទន្លេចាម មានប្រវែង ៣១ គ.ម ជួសជុលដោយមន្ទីរសាធារណៈការខេត្តត្បូងឃ្មុំ ហើយជាស្ថាបពរ។

**គ. ស្រង់ស្ថិតិយានដ្ឋានកែច្នៃ និងបាញ់ថ្នាំ និងតម្លើង**

– យានដ្ឋាន សរុបក្នុងស្រុកមេមត់ ចំនួន ៦៤កន្លែង

– យានដ្ឋាន បានចុះបញ្ជីមានចំនួន ៤០កន្លែង

– យានដ្ឋាន មិនទាន់បានចុះបញ្ជីមានចំនួន ២៤កន្លែង។

**ឃ. ផ្សព្វផ្សាយច្បាប់ចរាចរណ៍ផ្លូវគោកលើកទី១៣**

– នៅថ្ងៃទី០៣ ខែវិច្ឆិកា ឆ្នាំ២០១៨ មន្ទីរសាធារណៈការខេត្តត្បូងឃ្មុំ បានផ្សព្វផ្សាយច្បាប់ចរាចណ៍ផ្លូវគោក នៅមុខប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំដារ មានអ្នកចូលរួមចំនួន ៥២២នាក់, មានចែកមួកសុវត្ថិភាពចំនួន ២៧០មួក (ក្នុងនោះមួកសុវត្ថិភាពចំនួន ២០០មួក ឧបត្ថម្ភដោយក្រុមហ៊ុនធានារ៉ាប់រងForte) និងចែកសៀវភៅច្បាប់ចរាចរណ៍ ចំនួន ៦០០ក្បាល។

**ង. ត្រួតពិនិត្យយានដ្ឋានកែច្នៃខុសលក្ខណៈបច្ចេកទេសឆ្លងកាត់ស្រុកមេមត់៖**

– ត្រួតពិនិត្យរថយន្តសរុបចំនួន ៥០៣៧គ្រឿង នៅក្នុងនោះរថយន្តដឹកសំពីងសំពោងបានធ្វើកិច្ចសន្យាណែនាំអប់រំ ឲ្យគោរពច្បាប់ចរាចរណ៍ ៥៩១គ្រឿង និងរថយន្តកែច្នៃខុសលក្ខណៈបច្ចេកទេសកាត់ទ្រុងរួចចំនួន ៦៩គ្រឿង។

**ច. ផ្លូវជាតិលេខ៧**

ផ្លូវជាតោលេខ៧ ចាប់ពីព្រំប្រទល់ស្រុកពញាក្រែកទៅដល់ស្រុកស្នួល មានប្រវែង ៥២គ.ម ក្រុមហ៊ុនចិនបានសាងសង់លូមូល មានមុខកាត់ ១ ម នៅចំណុច PK205+500 ទៅដល់ PK206+800 កសាងលូអមសងខាងផ្លូវ

ផ្លូវ នៅដើមគ្រាមានប្រវែង ៧០០ម នៅក្នុងគ្រាប្រវែង ១៨៤៤ម បូកយោងចំនួន ២៥៤៤ម។

ក្រុមហ៊ុនចល័តត្រួតពិនិត្យលក្ខណៈបច្ចេកទេស(ឈៀក) បានចុះត្រួតពិនិត្យបច្ចេកទេសជូនប្រជាពលរដ្ឋនៅស្រុកមេមត់ចំនួន ០២លើក សរុបរថយន្តបានចំនួន ៣៨៤គ្រឿង។

## ៣.៧ សង្គមកិច្ច

### ៣.៧.១ ការងារអប់រំ

ស្រុកមេមត់មានសាលារៀនសរុបចំនួន ១១៧កន្លែង ក្នុងនោះសាលាបឋមចំនួន ១០០កន្លែង,អនុវិទ្យាល័យមានចំនួន ១៣កន្លែង, វិទ្យាល័យ ០៣កន្លែង និងសាលាមត្តេយ្យ ០១កន្លែង។ ស្ថិតិគ្រូមត្តេយ្យមានចំនួន ២១នាក់ ស្រី ១៨នាក់, គ្រូបឋមចំនួន ៤៣១នាក់ ស្រី ១៦០នាក់, គ្រូអនុវិទ្យាល័យមានចំនួន ២០៧នាក់ ស្រី ៦០នាក់, គ្រូវិទ្យា-ល័យចំនួន ៣៣នាក់ ស្រី១១នាក់ និងមានសាលាឯកជនចំនួន ០៥កន្លែង។ ជាមួយនេះដែរក្នុងស្រុក ក៏មានការឧបត្ថម្ភគាំទ្រដល់វិស័យសិក្សាអប់រំ ពីដៃគូរអភិវឌ្ឍន៍ចំនួន៣គឺ SAVE, KAP និងWFP។

- ចុះជួយការងារកុមារតូចតាមផ្ទះបានចំនួន ១៨ភូមិ មានអ្នកម្តាយចូលរួមចំនួន ៤២៤នាក់។
- សហការជាមួយមន្ទីរ អ.យ.ក ខេត្ត ចុះជួយមត្តេយ្យសហគមន៍លើកការងារបច្ចេកទេសបង្រៀន និងការ ផលិតសម្ភារៈបង្រៀននៅភូមិដារលិច, ស្ពាន និងភូមិមែកពុក ឃុំដារ។
- ចុះពិនិត្យការបង្រៀន និងរៀននៅតាមសាលាបឋមសិក្សាចំនួន ៤០សាលា។
- ចុះពិនិត្យការងារប្រើប្រាស់បុគ្គលិកចំនួន ២៣សាលា។
- រៀបចំឯកសារតម្លើងថ្នាក់ជូនបុគ្គលិកសម្រាប់ឆ្នាំ២០១៨ ចំនួន ៥៨៤នាក់។
- បានចូលរួមត្រួតពិនិត្យការប្រឡងសញ្ញាប័ត្រមធ្យមសិក្សាបឋមភូមិ តាមមណ្ឌលក្នុងស្រុកជាលទ្ធផល អត្រាប្រឡងជាប់ ៩៣.៤២%។
- បានចូលរួមជាគណៈមេប្រយោគប្រឡងសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិចំនួន ០៥លើក។
- កសាងផែនការតម្រូវការគ្រូឆ្នាំ២០១៨ ជូនមន្ទីរ និងក្រសួង។
- ចុះជួយសាលារៀនរៀបចំធ្វើផែនការអភិវឌ្ឍន៍សាលារៀនដោយមានការចូលរួមពីសហគមន៍នៅសាលារៀនបឋមសិក្សាសាឡង់២ និងក្ររៀនធំ។
- ចុះជួយរៀបចំបរិស្ថានសាលាបឋមសិក្សាសំបូរ និងជួយគ្រូក្នុងការបង្រៀនមុខវិជ្ជាភាសាខ្មែរផ្នែកអំណានថ្នាក់ទី៣។
- សហការជាមួយមន្ទីរ អ.យ.ក ខេត្ត និងអង្គការសង្គ្រោះកុមារចុះជួយមត្តេយ្យសហគមន៍នៅភូមិដារលិច និងភូមិជាំទៀក លើការងារបច្ចេកទេសបង្រៀន និងការផលិតសម្ភារៈឧបទេស។
- សហការជាមួយមន្ទីរ អ.យ.ក ខេត្ត និងអង្គការសង្គ្រោះកុមារ ចុះធ្វើតេស្តអ្នកម្តាយៗ និងកុមារស្តីពីការប្រែប្រួលឥរិយាបថក្នុងការជួយកូនៗរបស់អ្នកម្តាយៗ នៅឃុំជាំតាម៉ៅចំនួន ១២ភូមិ ដែលមានអ្នកម្តាយៗចូល

រួមសរុបចំនួន ១៦៤នាក់ និងកុមារចំនួន ១៧២នាក់។

- ចុះពិនិត្យមជ្ឈមណ្ឌលសហគមន៍នៅឃុំដារ លើជំនាញកែសម្ផស្ស និងកុំព្យូទ័រចំនួន ០៥លើក។
- ចុះពិនិត្យការស្រង់ស្ថិតិកុមារគ្រប់អាយុចូលរៀននៅតាមសាលារៀនគ្រប់កម្រងទាំង១២។

### ៣.៧.២. ការងារសុខាភិបាល

ស្រុកមេមត់ មានមន្ទីរពេទ្យបង្អែកចំនួន ០១កន្លែង, មណ្ឌលសុខភាព ១៣កន្លែង, ប៉ុស្តិ៍សុខភាព០១កន្លែង និងសេវាឯកជនមានឱសថស្ថានចំនួន ១០កន្លែង, ឱសថស្ថានរង ០៧កន្លែង។ ដោយឡែកក្នុងរយៈពេល៥ឆ្នាំនេះ បានផ្តល់សេវាដល់ប្រជាពលរដ្ឋទូទៅដូចជា៖

ក. <u>សកម្មភាព និងលទ្ធផលសម្រេចបាន</u>

- ពិនិត្យ ពិគ្រោះជំងឺក្រៅបានចំនួន ៦២៣,៥៣១ នាក់
- ចាក់ថ្នាំបង្ការជំងឺ១១មុខដល់កុមារក្រោមអាយុ១ឆ្នាំបានចំនួន ២៤១,៧២៣ នាក់
- ពិនិត្យផ្ទៃពោះមុនសំរាល បានចំនួន ៨៧,៩០០ នាក់
- ចាក់ថ្នាំបង្ការតេតាណុសដល់ស្ត្រីក្នុងវ័យបន្តពូជ បានចំនួន ២៨,៣៩៣ នាក់
- ពន្យាកំណើតដល់ស្ត្រីក្នុងវ័យបន្តពូជ បានចំនួន ១២៣,៨៤៣ នាក់
- សំរាលកូននៅមូលដ្ឋានសុខាភិបាល បានចំនួន ២៣, ០៨៤ នាក់
- អ្នកជំងឺបានព្យាបាលជាសះស្បើយចេញពីមន្ទីរពេទ្យ បានចំនួន ២២,៥០៤ នាក់
- អត្រាប្រើប្រាស់គ្រែក្នុងមន្ទីរពេទ្យ បានចំនួន ១១០%

ខ. <u>សកម្មភាពផ្សេងៗ ការិយាល័យស្រុកប្រតិបត្តិ</u>

- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីសុខាភិបាលនៅតាមមណ្ឌលសុខភាព និងRH ចំនួន ០៦មណ្ឌល (ស្លា, កំពាន់, ជាំក្រវៀន, រំចេក, ថ្មទឹង, មន្ទីរពេទ្យបង្អែកមេមត់) សរុប ១៥នាក់ ស្តីពីសុខភាពបន្តពូជ រយៈពេល ៥ថ្ងៃ គ្រូសម្របសម្រួលថ្នាក់ខេត្ត ០៣នាក់។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីសុខាភិបាលនៅតាមមណ្ឌលសុខភាពស្តីពីការព្យាបាលជម្ងឺគ្រុនចាញ់ ចំនួន ០១វគ្គ រយៈពេល០៣ថ្ងៃ មានមន្ត្រីចូលរួមសរុបចំនួន ២៩នាក់។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីគណនេយ្យនៅតាមមណ្ឌលសុខភាពទាំង ១៣កន្លែង និងមន្ត្រីមន្ទីរពេទ្យបង្អែកមេមត់ ស្តីពីការចាយចរិកា ៦,២០៨ របស់ក្រសួងសុខាភិបាល ១វគ្គ រយៈពេល៤ថ្ងៃ អ្នកចូលរួមសរុបចំនួន ២០នាក់ និងគ្រូសម្របសម្រួល ០២នាក់។
- បើកកិច្ចប្រជុំគណកម្មាធិការហិរញ្ញប្បទានសុខាភិបាលប្រចាំត្រីមាសទី៣ ០១លើក អ្នកចូលរួមសរុបចំនួន ២៦នាក់។
- សហការជាមួយក្រុមគ្រូពេទ្យវៀតណាម ចុះមកព្យាបាលជម្ងឺជូនប្រជាពលរដ្ឋបានចំនួន ១,៧២០នាក់។

- ចូលរួមការងារសុខាភិបាលក្នុងការធ្វើដំណើរ ៤០គីឡូម៉ែត្រឆ្ពោះទៅកាន់ទីប្រវត្តិសាស្ត្រ។
- ចូលរួមការពារ សុខភាពក្នុងខួបលើកទី៤០ នៃអនុស្សាវរីយ៍២ធ្នូ ស្រុកស្នួល ខេត្តក្រចេះ។
- ចុះអភិបាលការងារនៅតាមមណ្ឌលសុខភាពទាំង១៣ ។
- ចុះបង្វឹកការងារបច្ចេកទេស និងបុគ្គលិកមណ្ឌលទាំង១៣ ។
- ចុះវាយតម្លៃតាមមណ្ឌលសុខភាពទាំង១៣ ។
- ក្រុមគ្រូពេទ្យវៀតណាម ចុះត្រួតពិនិត្យ និងព្យាបាលចំនួន ០៣លើក អ្នកជម្ងឺសរុប ១,២៣៥នាក់ ក្នុងនោះស្រី ៩១០នាក់ ។

### ៣.៧.៣. ការងារសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បានជូនដំណឹងកុមារីឈ្មោះ **ឆេង សុជាតា** អាយុ ១៥ឆ្នាំ នៅភូមិត្របែក ឃុំមេមត់ ទៅរៀនជំនាញកាត់ដេរ ជាមួយអង្គការសង្គ្រោះដោតវាសនា ចំនួន ០១លើក ។
- សហការជាមួយលោកស្រីអភិបាលរងស្រុក, លោកស្រីប្រធាន គ.ក.ស.ក ស្រុក ចុះចែករទេះដល់ជនពិការ ចំនួន ០៣គ្រឿង នៅក្នុងឃុំដារ ០២គ្រឿង និងឃុំកំពាន់ ០១គ្រឿង ។
- បានទទួលអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរថតចម្លង ពីមុខសញ្ញាសោធននិវត្តចំនួន ៥៤នាក់ បញ្ជូនទៅមន្ទីរសង្គមកិច្ចខេត្តត្បូងឃ្មុំ ដើម្បីធ្វើប័ណ្ណសមធម៌ជូនពួកគាត់ ។
- បានបំពេញសំណុំបែបបទសោធននិវត្តដែលទទួលមរណភាពចំនួន ០២នាក់ ឡើងទៅក្រសួងដើម្បីលប់ឈ្មោះចេញពីបញ្ជី ។
- ការបង្កើតសមាគមន៍មនុស្សចាស់ទាំង ១៤ឃុំ មានអ្នកចូលរួមសរុបចំនួន ១,៩១៧នាក់។
- បានចុះធ្វើឯកសារជូនគ្រួសារសពជាមុខសញ្ញាអតីតយុទ្ធជន ០១សព នៅឃុំដារ ។
- បានធ្វើលិខិតផ្ទេរសិទ្ធិជូនមុខសញ្ញាអតីតយុទ្ធជនបានចំនួន ០៥នាក់ ឲ្យកូនទៅបើកប្រាក់បៀវត្សជំនួស។
- មុខសញ្ញាអតីតយុទ្ធជនបានសុំផ្ទេរចំនួន ០៤នាក់ ឲ្យប្រពន្ធកូនទៅបើកជំនួស ព្រោះពួកគាត់មានជម្ងឺ ។
- បានបំពេញបែបបទជូនដល់មុខសញ្ញាអតីតយុទ្ធជនដែលទើបចូលនិវត្តថ្មីជាមន្ត្រីនគរបាលចំនួន ០៤នាក់ និងជាយោធាចំនួន ០៦នាក់ ។
- ក្រសួងសង្គមកិច្ច សហការជាមួយការិយាល័យសង្គមកិច្ចស្រុក បានចុះបើកប្រាក់ជូនគ្រួសារមុខសញ្ញាអតីតយុទ្ធជនមានពិការភាព ដែលទទួលមរណភាព ជាប្រាក់ឧបត្ថម្ភចុងក្រោយចំនួន ០៣សព ។
- បានរៀបចំសំណើរសុំប្រាក់សមាគមជូនមុខសញ្ញាជនពិការ ដែលទទួលមរណភាពនៅឃុំរំចេក និងបានជូនប្រាក់ចំនួន ៤,០០០,០០០៛ បើកជូនដល់ផ្ទះគ្រួសារសព ។
- គ្រួសារសពដែលត្រូវបើកប្រាក់បន្តនៅធនាគារអេស៊ីលីដារ ចំនួន ០៦នាក់ ។

- ក្រសួងសង្គមកិច្ច សហការជាមួយការិយាល័យសង្គមកិច្ចស្រុក បានចុះបើកប្រាក់ជូនគ្រួសារសពដោយផ្ទាល់ចំនួន ០៣សព ក្នុងនោះនៅឃុំរូងមានចំនួន ០១សព, ឃុំទៀកចំនួន ០១សព និងឃុំមេមត់ ០១សព។
- ប្រធានសមាគមបានយកប្រាក់មរណៈសង្គ្រោះចំនួន ០៤លានរៀល ជូនដល់គ្រួសារសពចំនួន ០១សព ដែលបានទទួលមរណៈភាពនៅឃុំជាំតាម៉ៅចំនួន ០១លើក។

មុខសញ្ញាជនមានពិការភាព ដែលទទួលមរណៈភាពជាប្រាក់ឧបត្ថម្ភចុងក្រោយចំនួន ០៣សព។

- បានរៀបចំឯកសារសមាគមជូនដល់សញ្ញាអតីតយុទ្ធជន ជាយោធាចំនួន ០៤នាក់ និងជានគរបាលចំនួន ០២នាក់ ដែលទើបនឹងចូលនិវត្តន៍ថ្មី ។
- សញ្ញាអតីតយុទ្ធជនបានសុំផ្ទេរសិទ្ធិបើកប្រាក់ខែមានចំនួន ០២នាក់ ឲ្យប្រពន្ធបើកជំនួសព្រោះពួកគាត់មានជម្ងឺ ។

### ៣.៧.៤. ការងារធម្មការ និងសាសនា

ក្នុងស្រុកមេមត់មានសាសនាចំនួន ០៤ គឺ ១. សាសនាព្រះពុទ្ធ, ២. សាសនាឥស្លាម, ៣. សាសនាគ្រឹះ និង ៤.សាសនាធានយានមិឡិក។ សាសនាព្រះពុទ្ធ មានវត្តអារាមចំនួន ៣៧វត្ត និងអាស្រមចំនួន ០១កន្លែង ដោយឡែកកំពុងសាងសង់មានចំនួន ១២វត្ត ។ ព្រះសង្ឃសរុបចំនួន ២០៦អង្គ, យាយជីចំនួន ២,១៦៣នាក់, តាជីចំនួន ១,៧៤៣នាក់។ សាលាពុទ្ធិកបឋមសិក្សាចំនួន ០១កម្រង មានសាមនសិស្សសរុបចំនួន ១០៥អង្គ នាក់(មានបីថ្នាក់ និង០២កន្លែង ស្ថិតនៅឃុំមេមត់ ០១កន្លែង និងឃុំដារ ០១កន្លែង)។ សាសនាគ្រឹះ មានចំនួន០៣កន្លែង ។ សាសនាឥស្លាម មានវិហារចំនួន ១៨កន្លែង និងសាសនាធានយានមិឡិក ០១កន្លែង ។

- បានបញ្ជូនលោកអាចារ្យទៅរៀនវគ្គបណ្តុះបណ្តាលស្តីពីតួនាទី និងក្រមសីលធម៌អាចារ្យខ្មែរចំនួន ១០លើក សរុប ២៦នាក់ ។
- បានដឹកនាំព្រះសង្ឃ, លោកអាចារ្យ គណៈកម្មការវត្ត និងយាយជី តាជីចូលរួមព្រះរាជពិធីបង្សុកូលព្រះវិញ្ញាណក្ខន្ធព្រះបរមរតនកោដិ ០៥លើក ។
- ចុះផ្សព្វផ្សាយអនុក្រឹត្យលេខ ១៥៤ តាមបណ្តាវត្តអារាមចំនួន ១២ដង ។
- បានសហការជាមួយគ្រូចៅអធិកា និងគណៈកម្មការវត្តក្នុងការធ្វើប័ណ្ណកម្មសិទ្ធិដីវត្តបាន ៥វត្ត ។
- បានប្រជុំផ្សព្វផ្សាយសារាចរណ៍អន្តរក្រសួង ស្តីពីការប្រតិបត្តិសាសនា នានាក្នុងព្រះរាជាណាចក្រកម្ពុជាបានចំនួន ១០លើក ។
- សហការជាមួយគណៈអ៊ីម៉ាំស្រុកមេមត់ ដើម្បីស្រង់ស្ថិតិប្រជាពលរដ្ឋខ្មែរ - ឥស្លាម ចំនួន ០១លើកដូចខាងក្រោម៖
- គ្រួសារមាន ២,៦៩០គ្រួសារ, ប្រជាពលរដ្ឋមាន ១១,១៥០នាក់ ស្រី ៥,៦៧១នាក់, វិហារមាន ១៨វិហារ ។
- ស៊ូរ៉ាវមាន ២៦ស៊ូរ៉ាវ,សាលារៀនមាន១៨ខ្នង មាន ៤៤បន្ទប់, គ្រូខ្មែរ-ឥស្លាម មាន ៣៨នាក់ ស្រី០៥នាក់។

### ៣.៧.៥ ការងារកិច្ចការនារី

ក្នុងរយៈពេល៥ឆ្នាំនេះកិច្ចការនារីស្រុកបានខិតខំប្រឹងប្រែងអនុវត្តការងាររបស់ខ្លួនយ៉ាងសកម្មជាក់ស្តែងមានដូចខាងក្រោម៖

**១. ការងារកិច្ចប្រជុំ**

- សហការជាមួយមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ ប្រជុំវាយតម្លៃសកម្មភាពរបស់ស្ត្រីជាសមាជិកក្រុមប្រឹក្សាឃុំ នៅតាមបណ្តាឃុំ ដើម្បីឆ្ពោះទៅរកសមភាពយេនឌ័រនៅថ្នាក់សម្រេចចិត្ត អ្នកចូលរួម ០៨នាក់ ជាក្រុមប្រឹក្សាឃុំជាស្ត្រី ។
- បានរៀបចំកិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់កិច្ចការស្ត្រី និងកុមារស្រុកចំនួន ០៦លើក នៅសាលប្រជុំសាលាស្រុកមេមត់ ។

**២. ការងារវគ្គបណ្តុះបណ្តាល**

- សហការជាមួយមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ បើកវគ្គបណ្តុះបណ្តាលស្តីពី ការពង្រឹងសមត្ថភាពដល់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ អ្នកចូលរួមចំនួន ១៤នាក់ ជាស្ត្រី ។
- បើកវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពក្រុមប្រឹក្សាឃុំ និងថ្នាក់ដឹកនាំភូមិជាស្ត្រី ស្តីពី ជំនាញក្នុងការនិយាយនៅពេលផ្សព្វផ្សាយដល់សហគមន៍ អ្នកចូលរួមចំនួន ៣១នាក់ ។
- បានបើកវគ្គបណ្តុះបណ្តាលផ្នែកកែច្នៃចំណីអាហារ ដល់ស្ត្រីក្នុងសហគមន៍សរុបចំនួន ០៣វគ្គ (នៅឃុំមេមត់ ភូមិត្របែក ០១វគ្គ, នៅឃុំជាំតាម៉ៅ ភូមិថ្នល់កែង ០១វគ្គ, ភូមិទូលគ្រួស ០១វគ្គ) សរុបអ្នកចូលរួមចំនួន ១០៣នាក់ ជាស្ត្រី ។

**៣. ការងារវេទិកា ការផ្សព្វផ្សាយដល់សហគមន៍**

- សហការជាមួយការិយាល័យធម្មការ និងសាសនាស្រុកមេមត់ ចុះអប់រំផ្សព្វផ្សាយស្តីពី ការធ្វើអនាម័យខ្លួនប្រាណ និងអំពើហិង្សាលើកុមារ ដល់កុមារ (ក្មេងស្នាក់នៅវត្តអារាម) ចំនួន ០៥វត្ត ដែលមានកុមារចូលរួមចំនួន ៣៨នាក់ ។
- ផ្សព្វផ្សាយអំពើហិង្សាក្នុងគ្រួសារ ដោយផ្ទាល់នៅឃុំរំចេក សរុបចំនួន ១១គ្រួសារ ។
- ជំរុញដល់អាណាព្យាបាលក្នុងការការពារកុមារឲ្យនៅកន្លែងសុវត្ថិភាព នៅភូមិញ៉ៅ និងភូមិសុខសាន្តចំនួន ១៣គ្រួសារ ។
- បានសហការជាមួយមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ និងក្រសួងកិច្ចការនារី ចុះប្រមូលព័ត៌មានអំពីតម្រូវការអភិវឌ្ឍន៍សមត្ថភាពរបស់ស្ត្រីជាក្រុមប្រឹក្សាឃុំ ចំនួន ០៣ឃុំ (ឃុំមេមត់, ឃុំត្រមូង និងឃុំចាន់មូល)
- បានសហការជាមួយមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ ចុះសម្ភាសន៍សហគមន៍ ដើម្បីវិភាគយេនឌ័រ នៅភូមិស្រែលើសែនជ័យ ឃុំក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ដោយជ្រើសរើសសំណាកចំនួន ៥០គ្រួសារ ។

- បានសហការជាមួយមន្ទីរកិច្ចការនារីខេត្តត្បូងឃ្មុំ ចុះផ្សព្វផ្សាយពី អំពើហិង្សាក្នុងគ្រួសារ ដោយផ្ទាល់នៅភូមិស្រែលើសែនជ័យ ក្រវៀន ស្រុកមេមត់ ខេត្តត្បូងឃ្មុំ អ្នកចូលរួមចំនួន ៥០នាក់ ស្រី ៤៨នាក់ ។
- បានរៀបចំវេទិកាសហគមន៍ ស្តីពីការលើកម្ពស់សីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ ចំនួន ០៣វេទិកា (នៅឃុំត្រមូង ០២វេទិកា, នៅឃុំជាំតាម៉ៅ ០២វេទិកា) អ្នកចូលរួមសរុប ៣១៥នាក់ ស្រី ១៦១នាក់ ។
- បានផ្សព្វផ្សាយអំពីយេនឌ័រ និងសុខភាពបន្តពូជ ដល់ក្រុមយុវវ័យ នៅតាមសាលា នៅវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ ០១លើក អ្នកចូលរួមចំនួន ២៥៦នាក់ ស្រី ១១៨នាក់ ។
- បានផ្សព្វផ្សាយអំពីយេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារ ដោយផ្ទាល់ជាមួយប្រជាពលរដ្ឋនៅឃុំមេមត់ចំនួន ១៣គ្រួសារ ។
- បានសហការជាមួយ គ.ក.ន.ក ឃុំជាំតាម៉ៅ អប់រំផ្សព្វផ្សាយស្តីពី ការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅភូមិថ្នល់កែង ឃុំជាំតាម៉ៅ ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ចំនួន ០១លើក អ្នកចូលរួម ៣០នាក់ ជាស្ត្រី ។
- បានអប់រំផ្សព្វផ្សាយដោយផ្ទាល់ស្តីពី ផលប្រយោជន៍នៃការចុះសំបុត្រអាពាហ៍ពិពាហ៍ ដល់ស្ត្រីដែលបានរៀបអាពាហ៍ពិពាហ៍រួច មិនទាន់បានចុះសំបុត្រអាពាហ៍ពិពាហ៍ចំនួន ០៤នាក់ ។
- បានផ្សព្វផ្សាយអំពី យេនឌ័រ និងសុខភាពបន្តពូជ ដល់សិស្សនៅវិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនមេមត់ អ្នកចូលរួមចំនួន ៧៥នាក់ ស្រី ៤៧នាក់ ។
- បានសហការជាមួយ គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារស្រុក (គ.ក.ស.ក) និង (គ.ក.ន.ក) ឃុំ ចុះផ្សព្វផ្សាយអំពី យេនឌ័រ និងអំពើហិង្សាក្នុងគ្រួសារចំនួន ០១លើក នៅឃុំដារ សរុបអ្នកចូលរួមចំនួន ៤៣ ចំនួន ៤៣នាក់ ស្រី ២៨នាក់ ។

### ៣.៧.៦. ការិយាល័យការងារ

- ចុះធ្វើអធិការកិច្ចជាមួយមន្ទីរការងារខេត្ត បានចំនួន ០៦គ្រឹះស្ថាន ។
- ចុះស្រង់ស្ថិតិតាមបណ្តាគ្រឹះស្ថានឯកជនបានចំនួន ៤៥គ្រឹះស្ថាន និងចុះជំរុញឲ្យបំពេញបែបបទនៅមន្ទីរ បានចំនួន ២១គ្រឹះស្ថាន ។

### ៣.៧.៧. ការិយាល័យឧស្សាហកម្ម និងសិប្បកម្ម

- បានចុះជំនាញម្ចាស់រោងចក្រ និងសិប្បកម្មឲ្យដាក់ពាក្យដំណើរការរោងចក្រ និងសិប្បកម្ម បានចំនួន ៨មូលដ្ឋាន ចុះបញ្ជីនៅក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ការងារស្តង់ដារ និងមាត្រាសាស្ត្រៈក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានចុះផ្ទៀងផ្ទាត់នៅក្នុងស្រុកមេមត់ បានចំនួន ២២ស្ថានីប្រេងឥន្ធនៈ
- ចុះយកផលិតផលទៅពិនិត្យមន្ទីរពិសោធន៍ឧស្សាហកម្ម កម្ពុជាបានចំនួន ០២មូលដ្ឋាន
- ការងារទឹកស្អាតធ្វើការសិក្សាសមិទ្ធផល ការធ្វើអាជីវកម្មផ្គត់ផ្គង់ទឹកស្អាត ក្នុងស្រុកមេមត់ បានចំនួន ០៥ឃុំ

## ៣.៨ ការគ្រប់គ្រងដីធ្លី ធនធានធម្មជាតិ បរិស្ថាន ការប្រែប្រួលអាកាសធាតុ និងគ្រោះមហន្តរាយ

### ៣.៨.១ ការងារភូមិបាល

ក្នុងរយៈពេល៥ឆ្នាំនេះមន្ត្រីការិយាល័យជំនាញភូមិបាលស្រុកបានខិតខំប្រឹងប្រែងអនុវត្តការងាររបស់ខ្លួនយ៉ាងសកម្ម ធ្វើអោយសម្រេចបានលទ្ធផលដូចខាងក្រោមៈ

- ចុះវាស់វែង និងប្រមូលទិន្នន័យសរុប ១៧,៥៦៨ក្បាលដី (សម្រេចទាំងកំណត់ព្រំ និងវិនិច្ឆ័យ) ។
- ចុះធ្វើអត្តសញ្ញាណកម្មក្បាលដីរយៈពេល ០៤ថ្ងៃ នៅភូមិកោះថ្ម ឃុំទន្លូង ។
- ចុះស្វែងរកព្រំដីរដ្ឋដែលបានចុះបញ្ជីជាប្រព័ន្ធរួច នៅភូមិខ្នងក្រពើលិច ភូមិខ្នងក្រពើកើត ឃុំត្រមូង ស្រុកមេមត់ ខេត្តត្បូងឃ្មុំ ។
- ធ្វើការបិទផ្សាយទិន្នន័យជាសាធារណៈសរុបចំនួន ៧,៥៩៣ក្បាលដី ។
- ចែកវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុជូនបងប្អូនប្រជាពលរដ្ឋជាម្ចាស់ដីសរុបចំនួន១១,០១៦ ប័ណ្ណ

**ក. ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ**

+ ការងារចុះបញ្ជីដំបូង
  - អង្កេតវាស់វែងបានចំនួន ១៥៨ក្បាលដី
  - ចេញប័ណ្ណបានចំនួន ១១៧ប័ណ្ណ
+ ការងារចុះបញ្ជីបន្ត
  - ផ្ទេរសិទ្ធិលក់ផ្តាច់បានចំនួន ៣១៣ប័ណ្ណ
  - អំណោយផ្តាច់បានចំនួន ៥២ប័ណ្ណ
  - ប្តូរប្រភេទក្បាលដីចំនួន ០១ប័ណ្ណ

**ខ. ការងារសំណង់**

- ចុះហាមឃាត់សំណង់គ្មានច្បាប់បានចំនួន ១៥៥ករណី ។
- ចេញលិខិតអនុញ្ញាតឲ្យសាងសង់ផ្ទះចំនួន ២២គម្រោង ។

### ៣.៨.២. ការងារបរិស្ថាន

បានចុះត្រួតពិនិត្យការចាក់សំរាមអនាធិបតេយ្យតាមដងផ្លូវសាធារណៈ តាមទីផ្សារ និងត្រួតពិនិត្យ បរិស្ថាននៅតាមរោងចក្រ និងអាជីវកម្មជរចំនួន ៤៥លើក ក្នុងនោះនៅឃុំមេមត់ ១៤លើក , ឃុំត្រមូង ១២លើក និងឃុំដារ ១៩លើក ។

– ការិយាល័យបរិស្ថានស្រុក បានខិតខំទំនាក់ទំនងជាមួយបងប្អូនអាជីវកម្មមួយចំនួនក្នុងស្រុក ដើម្បីរកថវិកាយកមកសាងសង់ស្លាកសញ្ញាបរិស្ថាន បានចំនួន ២០ស្លាក ដាក់នៅតាមដងផ្លូវជាតិ ផ្លូវលំ ។

– ចុះត្រួតពិនិត្យទីប្រជុំជនផ្សារ ចំណតរថយន្តមេមត់ ណែនាំជម្រុញម្ចាស់អាជីវកម្មផ្នែកយកភាស៊ីឲ្យយកចិត្តទុកដាក់ប្រមូលសំរាមនៅតាមទីប្រជុំជនផ្សារចំនួន ០៥លើក ។

– សហការជាមួយកម្លាំងប៉ុស្តិ៍នគរបាលរដ្ឋបាលឃុំ និងអាជ្ញាធរឃុំ ចុះត្រួតពិនិត្យ តាមដានបទល្មើសលួចចោលសំរាមតាមទីសាធារណៈ តាមដងផ្លូវជាតិលេខ៧ ចំនួន ០៧លើក ។

– ចូលរួមជាមួយមន្ទីរបរិស្ថានខេត្ត និងគណៈអភិបាលស្រុក រៀបចំវេទិកាបរិស្ថានស្តីពី ការអប់រំបរិស្ថានដល់ប្រជាពលរដ្ឋ កងកម្លាំងប្រដាប់អាវុធ មន្ត្រីរាជការ និងសិស្សានុសិស្សចំនួន ០១លើក ។

– ចូលរួមជាមួយលោកមេឃុំស្តីពី ការគ្រប់គ្រងកាកសំណល់សំរាមតាមលំនៅដ្ឋាន ភូមិ ឃុំ ចូលរួមចំណែកក្នុងកិច្ចការពារបរិស្ថានចំនួន ០៤លើក ។

– បានចុះផ្សព្វផ្សាយច្បាប់បរិស្ថាន តាមរយៈការប្រជុំនានារបស់ក្រុមប្រឹក្សាឃុំ និងបានថតចម្លងឯកសារច្បាប់ថ្មីៗ ដែលមន្ទីរបានផ្តល់ជូនដល់ក្រុមប្រឹក្សា និងមេភូមិចំនួន ២៥លើក។

– ភ្នាក់ងារបរិស្ថានស្រុក បានចុះតាមដានត្រួតពិនិត្យជាប្រចាំនៅតាមរោងចក្រ និងទីតាំងអាជីវកម្មមួយចំនួនដែលមានការបំពុលបរិស្ថានក្នុងស្រុកចំនួន ០២លើក ។

– បានចុះសហការជាមួយលោកមេឃុំមេមត់ យកអេស្កាវទៅរុញសំរាមតាមដងផ្លូវ ក្បែរវត្តពោធិ ៨ដើម ចំនួន ០២លើក ។

## ៣.៩ រដ្ឋបាល និងសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ

### ៣.៩.១. សភាពការណ៍សន្តិសុខនយោបាយ

មានសភាពស្ងប់ស្ងាត់ពុំមានអ្វីកើតឡើងគួរអោយ កត់សម្គាល់ទេ ។

**ក. សភាពការណ៍បទល្មើសព្រហ្មទណ្ឌ៖** កើតឡើងចំនួន ១៦៥លើក និងចុះបង្ក្រាបបទល្មើស ព្រហ្មទណ្ឌបានចំនួន ១៦១លើក ។

**ខ. សភាពការណ៍សណ្តាប់ធ្នាប់សាធារណៈ៖** ករណីគ្រោះថ្នាក់ចរាចរណ៍កើតឡើងចំនួន ១៧១លើក ។

**គ. ការងារបង្ក្រាបគ្រឿងញៀន៖** ចុះបង្ក្រាបបទល្មើសគ្រឿងញៀនបានចំនួន ១៤៤លើក ឃាត់មុខសញ្ញាចំនួន ២៧១នាក់, ថ្នាំញៀន ចំនួន ១១៥៩កញ្ចប់ (ធំ ៣៣កញ្ចប់) ។

### ៣.៩.២. អំពីការបង្ក្រាបបទល្មើសព្រៃឈើ និងសត្វព្រៃ

ក្នុងរយៈពេល ៥ឆ្នាំនៃអាណត្តិទី២នេះ សង្កាត់រដ្ឋបាលព្រៃឈើ បានចុះបង្ក្រាបបទល្មើសចំនួន ៧៨លើក រឹបអូសឈើចម្រុះគ្រប់ប្រភេទចំនួន ២៣៦ម៣ ៧៧៥, អុសចម្រុះ និងដើមអាកាស្យា ៩៨,៣៤០.៥ស្ទែរ, ធ្យូង ២៤.៩៦០ គ.ក្រ, ជំនៀរឈើ ៤៩១ដុំ, ជន្លង់ម្រេច ៥៣៧ដើម និងរឹបអូសសត្វព្រៃចម្រុះចំនួន ៣១ក្បាល ព្រមទាំងមធ្យោបាយដឹកជញ្ជូនបទល្មើសសរុប ៣១គ្រឿង។

### ៣.៩.៣ ការងារផែនការ

នៅក្នុងរយៈពេល៥ឆ្នាំនេះ ការិយាល័យផែនការស្រុក បានអនុវត្តការងាររបស់ខ្លួនដូចខាងក្រោម៖

- បានចុះស្រង់ទិន្នន័យអត្តសញ្ញាណកម្មគ្រួសារក្រីក្រ (ក្រីក្រ១ + ក្រីក្រ២) ទូទាំងស្រុកបានចំនួន ៥,៩៨៧គ្រួសារ ស្មើនឹង ១៧.៦៧% នៃគ្រួសារសរុប ៣៤,០៨៩គ្រួសារ ក្នុងនោះក្រីក្រ ១ចំនួន ១,៧៥២គ្រួសារ និងក្រីក្រ ២ចំនួន ៥,៩៨៧គ្រួសារ ។
- ចុះធ្វើជំរឿនប្រជារាស្ត្រ ទូទាំងស្រុក ចំនួន ១៤ឃុំ ទទួលបានទិន្នន័យគ្រួសារសរុបចំនួន ៣៣,៦៣០គ្រួសារ មនុស្សរួម ១៤៤,៥៥០នាក់ ក្នុងនោះស្រី៧៣,៥៨០នាក់ ។
- បានចុះស្រង់ទិន្នន័យភូមិ ឃុំ ស្រុកប្រចាំឆ្នាំនីមួយៗ ចំនួន ០៥លើក។

## ៣.១០. ការងាររដ្ឋបាលឃុំ សង្កាត់

### ៣.១០.១. ស្ថិតិក្រុមប្រឹក្សា និងបុគ្គលិក

ក្រុមប្រឹក្សាឃុំ ទាំងអស់នៅក្នុងស្រុកមេមត់មានសមាជិក១០២ រូប ស្រី ១៨ រូប។ សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរក្នុងរយៈពេល ៥ឆ្នាំម្តងមានចំនួន ៤ រូប ស្រី ១ រូប។ ជំទប់ទី១ ១៤ រូប ស្រី ១រូប ,ជំទប់ទៅទី២ ១៤ រូប ស្រី ១ រូប, ស្មៀនឃុំ ១៤ រូប, បុគ្គលិកកិច្ចសន្យា ១៣ រូប ស្រី ៤ រូប, មេភូមិ ១៧៧ រូប ស្រី ០៥ រូប, អនុប្រធានភូមិ ១៧៧ រូប ស្រី ១៧ រូប ,សមាជិកភូមិ ១៧៧ រូប ស្រី៣៥ រូប, អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាក្រុមប្រឹក្សាឃុំ ៤ រូប ស្រី ៣ រូប, ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ ១១ រូប។

**តារាងទី១៣៖ ស្ថិតិក្រុមប្រឹក្សាឃុំ សង្កាត់ និង បុគ្គលិក**

| ល.រ | ការបរិយាយ | សរុប | ស្ត្រី |
|---|---|---|---|
| ១ | សមាជិកក្រុមប្រឹក្សាឃុំ | ១០២ | ១៨ |
| ២ | សមាជិកក្រុមប្រឹក្សាដែលបានផ្លាស់ប្តូរក្នុងរយៈពេល៥ឆ្នាំ | ៤ | ១ |
| ៣ | មេឃុំ | ១៤ | ១ |
| ៤ | ជំទប់ទី១ | ១៤ | ១ |
| ៥ | ជំទប់ទី២ | ១៤ | ១ |
| ៦ | ស្មៀនឃុំ | ១៤ | ០ |
| ៧ | បុគ្គលិកកិច្ចសន្យា | ១៣ | ៤ |
| ៨ | មេភូមិ | ១៧៧ | ០៥ |
| ៩ | អនុប្រធានភូមិ | ១៧៧ | ១៧ |
| ១០ | សមាជិកភូមិ | ១៧៧ | ៣៥ |
| ១១ | អ្នកទទួលបន្ទុកកិច្ចការនារីនិងកុមារដែលមិនមែនជាក្រុមប្រឹក្សាឃុំ | ៤ | ៣ |
| ១២ | ជនបង្គោលតាមដានត្រួតពិនិត្យ និងវាយតម្លៃឃុំ | ១១ | ០ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.២.ដីកា សេចក្តីសម្រេច និងលិខិត

ក្នុងរយៈពេល៥ឆ្នាំកន្លងកន្លងទៅនេះអាជ្ញាធររដ្ឋបាលឃុំ សង្កាត់បានខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។ ជាក់ស្តែងគឺបានដាក់ចេញនូវ៖ ដីកា៦៤ច្បាប់, សេចក្តីសម្រេចបានដាក់ចេញ ៤៤២ច្បាប់, លិខិតរដ្ឋបាលបានដាក់ចេញសម្រេច៩,២៦០ច្បាប់, លិខិតដែលបានទទួល៤,៤១៤ច្បាប់។

**តារាងទី១៤៖ ដីកា សេចក្ដីសម្រេច និងលិខិត**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | ដីការដែលបានដាកចេញ | ១១ | ១១ | ១៥ | ១៤ | ១៣ | ៦៤ |
| ២ | សេក្ដីសម្រេចដែលបានដាក់ចេញ | ៥៦ | ៦៤ | ៧៩ | ១៣៥ | ១០១ | ៤៤២ |
| ៣ | លិខិតរដ្ឋបាលដែលបានដាក់ចេញ | ១,៧២៥ | ១,៧៩៤ | ២,០៤២ | ១,៨៩៤ | ១,៨០៥ | ៩,២៦០ |
| ៤ | លិខិតដែលបានទទួល | ៧៩៩ | ៨៩៤ | ៨៣៤ | ៨៦៩ | ១,០២២ | ៤.៤១៤ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.៣.កិច្ចប្រជុំក្រុមប្រឹក្សាឃុំ និង គ.ក.ន.ក

ក្នុងរយៈពេល៥ឆ្នាំកន្លងទៅនេះ ក្រុមប្រឹក្សាឃុំ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារ ហៅកាត់ គ .ក.ន.ក បានអនុវត្តតួនាទីរបស់ខ្លួនរួមមាន៖ ប្រជុំសាមញ្ញចំនួន ៨៦៣លើក ប្រជុំវិសាមញ្ញចំនួន ៦០៨លើក ប្រជុំសម្ងាត់របស់ក្រុបប្រឹក្សាចំនួន ៥២លើក ប្រជុំគ.ក.ន.ក ចំនួន ៣១០លើក។

**តារាងទី១៥៖ កិច្ចប្រជុំរបស់ក្រុមប្រឹក្សា និង គ.ក.ន.ក**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | កិច្ចប្រជុំសាមញ្ញរបស់ក្រុមប្រឹក្សា | ១៧៤ | ១៧៩ | ១៧៧ | ១៧៦ | ១៥៦ | ៨៦៣ |
| ២ | កិច្ចប្រជុំវិសាមញ្ញរបស់ក្រុមប្រឹក្សា | ១១៨ | ១២៧ | ១១៤ | ១១១ | ១៣៨ | ៦០៨ |
| ៣ | កិច្ចប្រជុំសម្ងាត់របស់ក្រុមប្រឹក្សា | ៨ | ៧ | ៧ | ៥ | ២៥ | ៥២ |
| ៤ | កិច្ចប្រជុំ គ.ក.ន.ក | ៥០ | ៦៤ | ៦០ | ៦៩ | ៦៧ | ៣១០ |

*ប្រភព៖  របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.៤. ចំនួនគម្រោង និងថវិកាវិនិយោគដែលមានការសន្យាគាំទ្រដោយថវិកាឃុំ

គម្រោងនិងថវិកាវិនិយោគត្រូវបានបែងចែកជា៤ផ្នែក៖ ផ្នែកទី១៖ សេដ្ឋកិច្ច, ផ្នែកទី២៖ សង្គមកិច្ច, ផ្នែកទី៣៖ ធនធានធម្មជាតិបរិស្ថាន, ផ្នែកទី៤៖ រដ្ឋបាលសន្តិសុខសណ្ដាប់ធ្នាប់សាធារណៈ។ ចំនួនគម្រោង និងថវិកាវិនិយោគដែលគាំទ្រដោយថវិកាឃុំក្នុងនោះមាននៅឆ្នាំ២០០៩សរុបមាន ៥៧គម្រោង ថវិកាសរុប ៧០៦,៥២៧,៥៥០លានរៀល , ឆ្នាំ២០១០សរុបមាន ៧១គម្រោង ថវិកាសរុប១,១៤៥,២៨៥,០២២លានរៀល, នៅឆ្នាំ២០១១សរុបមាន ៥៧គម្រោង ថវិកាសរុប១,៤៩៧,៣១៧,៨២២លានរៀល, ឆ្នាំ២០១២សរុបមាន ២១គម្រោង ថវិកាសរុប៧,៥០០,០០០លានរៀល, នៅឆ្នាំ២០១៣សរុបមាន ១៩ គម្រោង ថវិកាសរុប៤៤១,០០០លានរៀល។

## តារាងទី១៦៖ ចំនួនគម្រោង និងថវិកាវិនិយោគដែលគាំទ្រដោយថវិកាឃុំ

| ល.រ | ការបរិយាយ | ចំនួនគម្រោង និងថវិកាវិនិយោគ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០០៩ | | ២០១០ | | ២០១១ | | ២០១២ | | ២០១៣ | | សរុប |
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | |
| ១ | សេដ្ឋកិច្ច | ៣៥ | ៥៨២,០២៧,៥៥០ | ៣០ | ៧៦៧,១៤២,៩២២ | ២៩ | ១,១៥៨,៥១៧,៨២២ | ៣២ | ៩៩២,៦៧០,៤៨០ | ៤៦ | ១,០៣០,៥៧០,២៧១ | |
| ២ | សង្គមកិច្ច | ១៤ | ១១៥,៥០០,០០០ | ២៤ | ២៣៧,៣៥៥,០០០ | ១៩ | ២៤០,៨០០,០០០ | ២៥ | ១,១៥៥,០៤៤,០០០ | ៨៧ | ១១,៨២៣,៦២០ | |
| ៣ | ធនធានធម្មជាតិ បរិស្ថាន | ៣ | ៤,០០០,០០០ | ១០ | ២៩,៨០៦,១០០ | ៣ | ៣,០០០,០០០ | ៣ | ២,២០០,០០០ | ១២ | ២៧០,០០០ | |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ | ៧ | ៥,០០០,០០០ | ៧ | ១១០,០០០,០០០ | ៦ | ៩៥,០០០,០០០ | ២១ | ៧,៥០០,០០០ | ១៩ | ៤៤១,០០០ | |
| សរុប | | ៥៧ | ៧០៦,៥២៧,៥៥០ | ៧១ | ១,១៤៤,២៨៤,០២២ | ៥៧ | ១,៤៩៧,៣១៧,៨២២ | ៨១ | ២,១៥៧,៤១៤,៤៨០ | ១៦៤ | ១,០៤៣,១០៤,៨៩១ | |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.៥. ចំនួនគម្រោង និងតម្លៃគម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង

ចំនួនគម្រោងដែលគាំទ្រដោយថវិកាឃុំបានអនុវត្តជាក់ស្តែងមានដូចតទៅ៖ នៅឆ្នាំ២០០៩ គម្រោងជាក់ស្តែងដែលបានអនុវត្តមាន ២៧គម្រោង ចំណាយថវិកាសរុប ៦៨៣,៧១១,៤០០លានរៀល, នៅឆ្នាំ២០១០ អនុវត្តបាន ៤០គម្រោង ចំណាយថវិកាសរុប ៧៤៧,៤០៦,៥០៥ លានរៀល, នៅឆ្នាំ២០១១ អនុវត្តបាន ៣៨គម្រោង ចំណាយថវិកាសរុប ១,០៦៥,៩៣៥,៥០២លានរៀល, នៅឆ្នាំ២០១២ អនុវត្តបាន ៣៣គម្រោង ចំណាយថវិកាសរុប ១៣,០១៦,៩៣៥,៥០២លានរៀល, នៅឆ្នាំ២០១៣ អនុវត្តបាន ៥៣គម្រោង ចំណាយចិវកាសរុ១,៤៨៧,២៧៥,៤៩៦ លានរៀល។

**តារាងទី១៧ ៖ ចំនួនគម្រោង និងតម្លៃគម្រោងវិនិយោគដែលបានអនុវត្តជាក់ស្តែង**

| ល.រ | ការបរិយាយ | ចំនួនគម្រោង និងថវិកាវិនិយោគ | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | ២០០៩ | | ២០១០ | | ២០១១ | | ២០១២ | | ២០១៣ | | សរុប |
| | | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | ចំនួន | តម្លៃ | |
| ១ | សេដ្ឋកិច្ច | ១៤ | ៦៨៣,៧១១,៤០០ | ១៤ | ៧៤៤,០៧១,៥០៥ | ១៣ | ៩៧៥,២៨៣,៥០២ | ១៧ | ១១,៩០៤,៩៩៥,០០០ | ១៦ | ១,៣៧០,៤៥៧,៤៩៦ | |
| ២ | សង្គមកិច្ច | ៧ | | ១៨ | ៣,៣៣៥,០០០ | ១៥ | ៩០,៦៥២,០០០ | ១៣ | ១,១១១,០៥២,០០០ | ២៧ | ១១៧,២៦៨,០០០ | |
| ៣ | ធនធានធម្មជាតិ បរិស្ថាន | | | | | | | | | | | |
| ៤ | រដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ | ៦ | | ៨ | | ១០ | | ៣ | | ៥ | | |
| សរុប | | ២៧ | ៦៨៣,៧១១,៤០០ | ៤០ | ៧៤៧,៤០៦,៥០៥ | ៣៨ | ១,០៦៥,៩៣៥,៥០២ | ៣៣ | ១៣,០១៦,៩៣៥,៥០២ | ៥៣ | ១,៤៨៧,២៧៥,៤៩៦ | |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.៦.ការអនុវត្តថវិកាឃុំ

ខាងក្រោមនេះជាថវិកាចំណូលនិងចំណាយរបស់ឃុំ៖

| ឆ្នាំ | ចំណូល (គិតលានរៀល) | | | ចំណាយ (គិតលានរៀល) | | |
|---|---|---|---|---|---|---|
| | អនុម័ត | ជាក់ស្តែង | % | អនុម័ត | ជាក់ស្តែង | % |
| ២០០៩ | ១,០៨១,១៣៧,៤០០ | ១,០៨១,១៣៧,៤០០ | ១០០% | ១,០៨១,១៣៧,៤០០ | ១,០៨១,១៣៧,៤០០ | ១០០% |
| ២០១០ | ១,៤២០,០៨២,២០០ | ១,៤២០,០៨២,២០០ | ១០០% | ១,៤២០,០៨២,២០០ | ១,៤២០,០៨២,២០០ | ១០០% |
| ២០១១ | ១,៥៥៩,០០៩,៨០០ | ១,៥៥៩,០០៩,៨០០ | ១០០% | ១,៥៥៩,០០៩,៨០០ | ១,៥៥៩,០០៩,៨០០ | ១០០% |
| ២០១២ | ១,៧៥៧,៦៥៣,២០០ | ១,៧៥៧,៦៥៣,២០០ | ១០០% | ១,៧៥៧,៦៥៣,២០០ | ១,៧៥៧,៦៥៣,២០០ | ១០០% |
| ២០១៣ | ១,៩៦២,៧១៩,០០០ | ១,៩៦២,៧១៩,០០០ | ១០០% | ១,៩៦២,៧១៩,០០០ | ១,៩៦២,៧១៩,០០០ | ១០០% |
| សរុប | ៧,៧៨០,៦០១,៦០០ | ៧,៧៨០,៦០១,៦០០ | ១០០% | ៧,៧៨០,៦០១,៦០០ | ៧,៧៨០,៦០១,៦០០ | ១០០% |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.៧.ការគ្រប់គ្រងទ្រព្យសម្បត្តិ

- ទ្រព្យសម្បត្តិដែលឃុំបានទិញ និងទទួលថ្មីនៅរយៈពេល៥ឆ្នាំកន្លងមានសរុប ២៥៣

– ទ្រព្យសម្បត្តិដែលបានកាត់ចេញមានចំនួន៣២

**តារាងទី១៨៖ ការគ្រប់គ្រងទ្រព្យសម្បត្តិ**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | ទ្រព្យសម្បត្តិដែលបានទិញ ឬទទួល(ថ្មី) | ១២២ | ៥១ | ៤៦ | ១ | ៤៣ | ២៥៣ |
| ២ | ទ្រព្យសម្បត្តិដែលបានកាត់ចេញ | ០ | ០ | ៩ | ០ | ២៣ | ៣២ |
| ៣ | ទ្រព្យសម្បត្តិសរុប | ១៦៤ | ២១៥ | ២៥២ | ២៥៣ | ១១៦ | |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.៨.ការអភិវឌ្ឍសមត្ថភាព

វគ្គបណ្តុះបណ្តាលសមត្ថភាពរបស់មន្ត្រីរាជការរយៈពេល៥ឆ្នាំកន្លងមកមានសរុប ២៨៥វគ្គ សិក្ខាកាមដែលចូលរួមសរុបមាន២,១៤៧នាក់ សិក្ខាកាមជាស្រីសរុប៩១៨នាក់។

**តារាងទី១៩៖ ការអភិវឌ្ឍសមត្ថភាព**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | វគ្គសិក្សា | ៥៣ | ៦៣ | ៥២ | ៦០ | ៥៧ | ២៨៥ |
| ២ | សិក្ខាកាមសរុបដែលបានចូលរួមវគ្គសិក្សា | ៤៤២ | ៤៨៤ | ៤០០ | ៤៥៩ | ៣៦២ | ២,១៤៧ |
| ៣ | សិក្ខាកាមជាស្ត្រីដែលបានចូលរួមវគ្គសិក្សា | ១៥៨ | ២២៩ | ១៧២ | ២០០ | ១៥៩ | ៩១៨ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

### ៣.១០.៩.សកម្មភាពសេវាសង្គម

សេវាសង្គមដែលមានការគាំទ្រពីឃុំកន្លងមកជាក់ស្តែងនៅឆ្នាំ២០០០៩ មតេយ្យសិក្សាសហគមន៍ដែលគាំទ្រដោយឃុំមានចំនួនសរុប១៣ខ្នង, គ្រួសារងាយរងគ្រោះដែលគាំទ្រដោយឃុំបានកែលម្អអនាម័យមាន ចំនួនសរុប ២៩៧គ្រួសារ, គ្រួសារងាយរងគ្រោះដែលគាំទ្រដោយឃុំបានទឹកស្អាតប្រើប្រាស់មានចំនួន ១,០៨២គ្រួសារ, គ្រួសារងាយរងគ្រោះដែលគាំទ្រដោយឃុំទទួលបានបង្គន់អនាម័យមានចំនួន ៣២៣គ្រួសារ, គ្រួសារងាយរងគ្រោះដែលឃុំកំណត់អត្តសញ្ញាណមានចំនួន ៥,១៣៣គ្រួសារ, ស្ត្រីរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារទទួលបានការគាំទ្រពីឃុំមានចំនួន១៥៤ គ្រួសារ។

**តារាងទី២០៖ សកម្មភាពសេវាសង្គម**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | មត្តេយ្យសិក្សាសហគមន៍កំពុងដំណើរការដែលគាំទ្រពីឃុំ | ០ | ២ | ១ | ៥ | ៥ | ១៣ |
| ២ | គ្រួសារងាយរងគ្រោះគាំទ្រពីឃុំ សម្រាប់កែលម្អអនាម័យ(ការលាងដៃនឹងសាប៊ូ) | ៣៧ | ៤១ | ៤១ | ១៣៨ | ៤០ | ២៩៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៣ | គ្រួសាររងាររងគ្រោះគាំទ្រពីឃុំ ដើម្បីទទួលបានទឹកស្អាតប្រើប្រាស់ | ១៩៤ | ៣ | ១៦១ | ៤៨៤ | ២៤០ | ១,០៨២ |
| ៤ | គ្រួសាររងាររងគ្រោះគាំទ្រពីឃុំ ដើម្បីទទួលបានបង្គន់អនាម័យប្រើប្រាស់ | ០ | ០ | ១៨ | ២ | ៣០៣ | ៣២៣ |
| ៥ | គ្រួសាររងាររងគ្រោះដែលឃុំចុះកំណត់អត្តសញ្ញាណ | ១,៦៤១ | ៥៨៩ | ៩៣៨ | ៣៤៩ | ១,៦១៦ | ៥,១៣៣ |
| ៦ | ស្ត្រីរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារដែលទទួលការគាំទ្រពីឃុំ | ៣៦ | ៤១ | ២៦ | ២០ | ៣១ | ១៥៤ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

**៣.១០.១០.ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់**

ករណីដែលឃុំបានដោះស្រាយឬសម្របសម្រួលទំនាស់រយៈពេលកន្លងមកមានសរុប១,០៦១ករណី, ករណីដែលបានបញ្ជូលទៅស្ថាបនពាក់ព័ន្ធមានចំនួន ៥៧ករណី។

**តារាងទី២១៖ ការដោះស្រាយ និងការសម្រុះសម្រួលទំនាស់**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | ករណីដែលបានដោះស្រាយឬសម្របសម្រួលរួច | ២៣៤ | ២៤៥ | ២២១ | ១៩៨ | ១៦៣ | ១,០៦១ |
| ២ | ករណីដែលបានបញ្ជូលទៅស្ថាប័នពាក់ព័ន្ធ | ២០ | ១៨ | ១៣ | ១៧ | ១៩ | ៨៧ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

**៣.១០.១១.ការងារអត្រានុកូលដ្ឋាន**

ឃុំបានយកចិត្តទុកដាក់និងមានទំនួលខុសត្រូវជាមួយប្រជាពលរដ្ឋយ៉ាងមានស្មារតីទទួលខុសត្រូវជាក់ស្តែងនារយៈពេល៥ឆ្នាំកន្លងមកឃុំបានចេញនូវសំបុត្រកំណើតសរុបចំនួន៤,៨៨៨ច្បាប់, សំបុត្របញ្ជាក់កំណើត ៦,៩៣៤ច្បាប់, សេចក្តីចម្លងសំបុត្រកំណើតចំនួន ៦៧៤ច្បាប់, សេចក្តីចម្លងសំបុត្របញ្ជាក់កំណើត ៤៦០ច្បាប់, សំបុត្រអាពាហ៍ពិពាហ៍ចំនួន ១,០២០ច្បាប់, សេចក្តីសម្លងសំបុត្រអាពាហ៍ពិពាហ៍មានចំនួន ១៥២ច្បាប់, សំបុត្រមរណភាពមានចំនួន ៤១៣ច្បាប់, សេចក្តីសម្លងសំបុត្រមរណភាពចំនួន ១១៤ច្បាប់។

**តារាងទី២២៖ការងារអត្រានុកូលដ្ឋាន**

| ល.រ | ការបរិយាយ | ចំនួន | | | | | |
|---|---|---|---|---|---|---|---|
| | | ២០០៩ | ២០១០ | ២០១១ | ២០១២ | ២០១៣ | សរុប |
| ១ | សំបុត្រកំណើត | ៦៦៦ | ៦៥៣ | ៧៤៣ | ១,១១១ | ១,៧១៥ | ៤,៨៨៨ |
| ២ | សំបុត្របញ្ជាក់កំណើត | ៩៦៧ | ១,២៣១ | ១,០៣១ | ១,៤៤០ | ២,២៦៥ | ៦,៩៣៤ |
| ៣ | សេក្តីចម្លងសំបុត្រកំណើត | ១៤២ | ៤៤ | ៥១ | ១០៦ | ៣៣១ | ៦៧៤ |
| ៤ | សេចក្តីសម្លងសំបុត្របញ្ជាក់កំណើត | ២៤ | ១០៤ | ៤៤ | ១០៤ | ១៨៤ | ៤៦០ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៥ | សំបុត្រអាពាហ៍ពិពាហ៍ | ១៣៣ | ១៤៥ | ២១៦ | ១៩៨ | ៣២៨ | ១,០២០ |
| ៦ | សេចក្ដីចម្លងសំបុត្រអាពាហ៍ពិពាហ៍ | ៨ | ១៥ | ៣០ | ៤២ | ៥៧ | ១៥២ |
| ៧ | សំបុត្រមរណភាព | ៥៩ | ៤៧ | ៩៤ | ៨០ | ១៣៣ | ៤១៣ |
| ៨ | សេចក្ដីចម្លងសំបុត្រមរណភាព | ៤ | ៦ | ១៥ | ៣៨ | ៥១ | ១១៤ |

*ប្រភព៖ របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់ ២០១៤ - ២០១៨*

## ៣.១១. បញ្ហាប្រឈម

ការអនុវត្តតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឆ្នាំ២០១៤-២០១៨គឺជាមេរៀនបទពិសោធន៍ដ៏ល្អសម្រាប់រដ្ឋបាលស្រុកការរៀនបណ្ដើរធ្វើបណ្ដើរ។ ទន្ទឹមនឹងលទ្ធផលដែលទទួលបានខាងលើរដ្ឋបាលស្រុកក៏នៅមានបញ្ហាប្រឈមមួយចំនួនដូចជា៖ ការងារក្រុមប្រឹក្សា ពុំទាន់មានទីកន្លែងធ្វើការងារ ( មានតែប្រធាន ក្រុមប្រឹក្សា) ទើបរៀបចំកន្លែងថ្មី, សាលប្រជុំរបស់ក្រុមប្រឹក្សាតូចចង្អៀត, ពុំមានថវិកាសម្រាប់ចុះប្រឹក្សាយោបល់ជាមួយក្រុមប្រឹក្សាឃុំ, ពុំមានថវិការសម្រាប់ធ្វើវេទិកាផ្សព្វផ្សាយ និងថវិកាជាតិគាំទ្រការអភិវឌ្ឍន៍សមត្ថភាពដល់ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាឃុំនៅមានកម្រឹតនៅឡើយ។ ចំពោះសមត្ថភាពជំនាញ ចំណេះដឹងនៃក្រុមប្រឹក្សាគឺនៅមានកម្រិត ដោយសារពួកគាត់ត្រូវបានជ្រើសរើសធ្វើការបោះឆ្នោតអសកលចេញពីក្រុមប្រឹក្សាឃុំ ដែលមានទៅលើក្នុងមុខដំណែងគណៈបក្សនយោបាយតែប៉ុណ្ណោះ។

ដោយឡែកការងាររបស់គណៈអភិបាល មន្ត្រីបំពេញការងារ មិនបញ្ចេញឱ្យអស់លទ្ធភាពដោយសាខ្វះខាតផ្នែកជីវភាពនិងឆន្ទៈ។ ការងារថវិកាជាកិច្ចការថ្មីសម្រាប់ស្រុកតែចំណេះដឹងមន្ត្រីបំពេញបំពេញការងារនេះនៅមានកម្រិតមិនទាន់សមស្របទៅនឹងទំហំការងារបច្ចុប្បន្ន។ មន្ត្រីការិយាល័យជុំវិញស្រុកមានតិច (ភាគច្រើនមានតែ ១ ឬ២ នាក់) ,ខ្វះការិយាល័យបំពេញការងារ ហើយការផ្ដល់របាយការណ៍របស់ការិយាល័យឃុំមួយចំនួនមានការយឺតយ៉ាវ ។ ប្រព័ន្ធគ្រប់គ្រងទិន្នន័យ និងបញ្ចូលទិន្នន័យក្នុងប្រព័ន្ធអេឡិចត្រូនិច (ព័ត៌មានវិទ្យា) តាមបណ្ដាការិយាល័យ និងឃុំមិនទាន់ប្រើប្រាស់បានធ្វើឱ្យជួបបញ្ហាក្នុងការប្រមូលទិន្នន័យ។

# សេចក្ដីសន្និដ្ឋាន

សរុបសេចក្ដីមកតាមការស្រាវជ្រាវខាងលើ ការគ្រប់គ្រងរដ្ឋបាលស្រុក ខណ្ឌ ជាការគ្រប់គ្រងរដ្ឋបាលមួយក្នុងប្រព័ន្ធរដ្ឋបាលរបស់ជាតិយើងហើយក៏ជារដ្ឋបាលមួយដែលស្ថិតនៅជាប់ជាមួយមូលដ្ឋាន និងប្រជាពលរដ្ឋផ្ទាល់ផងដែរ ។

ក្នុងការគ្រប់គ្រប់រដ្ឋបាលនៅស្រុកមេមត់ដែលមាន ១៤ឃុំ ស្មើ១៨០ភូមិ នេះផងដែរ រយៈពេល៥ឆ្នាំកន្លងទៅអាជ្ញាធរគ្រប់លំដាប់ថ្នាក់ , អង្គភាពប្រដាប់អាវុធទាំងបី , ការិយាល័យជុំវិញស្រុក , បានខិតខំប្រឹងប្រែងបំពេញភារកិច្ចរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការធានារ៉ាប់រងរក្សាការពារសន្តិសុខស្ថេរភាព សុវត្ថិភាព សណ្ដាប់ធ្នាប់សង្គមនិងយកចិត្តទុកដាក់ខ្ពស់ដោយអនុវត្តតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល និងទិសដៅរបស់ខេត្តក្រសួងមហាផ្ទៃ និងក៏ដូចជាខ្សែបណ្ដោយនីមួយៗ សម្រេចបានគួរជាទីមោទន។ ជាពិសេសក្នុងការលើកកម្ពស់ការផ្ដល់សេវាសាធារណៈបានល្អប្រសើរ។ ជាក់ស្ដែងពាក់ព័ន្ធជាមួយនឹងព្រំដែន ការគ្រប់គ្រង ទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ អាជ្ញាធររដ្ឋបាលស្រុក តែងខិតខំបង្កើននូវកិច្ចសហប្រតិបត្តិការបានយ៉ាងល្អជាមួយអាជ្ញាធរស្រុក ឃុំ និងសមត្ថកិច្ចពាក់ព័ន្ធនៅជាប់ព្រំដែនភូមិផងរបងជាមួយ ជាពិសេសកិច្ចសហការជាមួយប៉ុស្តិ៍ អង្គភាពព្រំដែនតាមរយៈកិច្ចប្រជុំ ដកពិសោធន៍ធ្វើឲ្យសន្តិសុខ សណ្ដាប់ធ្នាប់តាមបន្ទាត់ព្រំដែន ក៏ដូចជាការសម្រួលការនាំចេញ នាំចូលនូវកសិផលទៅលក់ឆ្លងប្រទេសដំណើរការបានយ៉ាងប្រសើរ ។រួមជាមួយនឹងការចូលរួមរបស់ប្រជាពលរដ្ឋ មន្ត្រី និងក្រុមប្រឹក្សាស្រុក និងអង្គភាពពាក់ព័ន្ធនានាក៏បានខិតខំប្រឹងប្រែងបំពេញការងាររបស់ខ្លួនយ៉ាងយកចិត្តទុកដាក់ដែលធ្វើឲ្យកើនឡើងនូវសមិទ្ធផលនានាដូចជា៖ ផ្លូវថ្នល់ សាលារៀន មន្ទីរពេទ្យ...គួបផ្សំជាមួយការឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាលដើម្បីអភិវឌ្ឍអោយមានការរីកចម្រើនឡើង។ លើសពីនេះទៅទៀតវិធានការល្អបំផុតនៃការគ្រប់គ្រងរដ្ឋបាលក្នុងស្រុកមេមត់គឺឈានទៅរកការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ជំរុញឲ្យប្រជាពលរដ្ឋយល់ដឹងកាន់តែច្បាស់អំពីច្បាប់និងប្រែក្លាយពួកគាត់ឲ្យក្លាយជាប្រជាពលរដ្ឋដែលគោរពច្បាប់ ដើម្បីឲ្យមានចំណេះដឹងកាន់តែទូលំទូលាយ និងអភិវឌ្ឍន៍សេដ្ឋកិច្ចយើងអោយកាន់តែជឿនលឿន។

ដោយឡែកទោះបីជាការគ្រប់គ្រងរដ្ឋបាលស្រុក មានលក្ខណៈល្អប្រសើរ និងរលូនទៅមុខក៏ពិតមែន ក៏នៅតែមានចំណុចជាច្រើនដែលខ្វះចន្លោះផងដែរដូចជា៖ ចំណេះដឹងទៅលើប្រព័ន្ធបច្ចេកទេសនៅមានកម្រិត និងខ្វះប្រភពហិរញ្ញវត្ថុដែលជាកត្តាជះឥទ្ធិពលដល់ការអភិវឌ្ឍន៍ក្នុងស្រុក សមាសភាពមន្ត្រីរាជការមិនទាន់សមស្របទៅតាមទំហំស្រុកនិងចំនួនប្រជាពលរដ្ឋផងដែរ។

# អនុសាសន៍

ស្របតាមការស្រាវជ្រាវ និងការជួបផ្ទាល់នៃការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ ក្នុងនាមជាអ្នកស្រាវជ្រាវពិតជាមានសេចក្តីរីករាយ ព្រោះបានស្វែងយល់ពីដំណើរការគ្រប់គ្រងរដ្ឋបាលស្រុកមេមត់ និងយល់ដឹងពីបញ្ហាប្រឈមមួយចំនួនដែលរារាំងដល់ការអភិវឌ្ឍន៍ស្រុក ហើយឃើញថាចំណុចមួយចំនួនក៏មិនទាន់មានលក្ខណៈល្អប្រសើរនៅឡើយ ដោយសារវានៅមានភាពចន្លោះប្រហោងមួយចំនួនដែលរដ្ឋបាលស្រុក និងស្ថាប័នដែលពាក់ព័ន្ធគួរយកចិត្តទុកដាក់ និងកែលម្អទៅលើចំណុចខ្វះខាតទាំងនោះ។ ដើម្បីកែលម្អចំណុចខ្វះខាតទាំងនោះ ក្នុងនាមជាអ្នកស្រាវជ្រាវសូមចូលរួមចំណែកជាមតិយោបល់ និងគំនិតខ្លះៗដូចខាងក្រោម៖

- បើកវគ្គបណ្តុះបណ្តាលមន្ត្រីរាជការអោយបានច្រើនដងដើម្បីកសាងសមត្ថភាពរបស់មន្ត្រីអោយកាន់តែខ្លាំង ជាពិសេសផ្នែកបច្ចេកវិទ្យា
- បង្កើនសមាសភាពមន្ត្រីរាជការអោយសមស្របទៅតាមទំហំការងារនិងប្រជាជនដើម្បីងាយស្រួលបំពេញការងារ និងបានឆាប់រហ័ស
- រដ្ឋបាលស្រុកគួរតែធ្វើផែនការចំណាយរបស់ខ្លួនអោយបានច្បាស់លាស់
- បង្កើនថវិកាដល់ការអភិវឌ្ឍន៍ស្រុក អោយសមស្របទៅតាមតម្រូវការ
- ពង្រឹងឥរិយាបថមន្ត្រីរាជការក្នុងការបម្រើសេវាសាធារណៈជូនប្រជាពលរដ្ឋ
- ផ្តល់សិទ្ធិអំណាចអោយរដ្ឋបាលស្រុកកាន់តែច្រើនទៅលើកិច្ចការបម្រើប្រជាពលរដ្ឋ
- ត្រូវអនុវត្តអោយបានខ្ជាប់ខ្ជួននូវច្បាប់ទាំងឡាយដែលមានចែងទុក

យោងទៅតាមគំនិតដ៏ស្លូតស្តើងរបស់នាងខ្ញុំទាំងពីរនាក់ខាងលើ នឹងអាចជាចំណែកមួយនៃជ្រុងដំណោះស្រាយដល់ខាងរដ្ឋបាលស្រុកក្នុងការបំពេញការងារអោយបានឆាប់រហ័សជាងមុនដើម្បីឆ្លើយតបទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល។

# ឯកសារយោង

- **អនុក្រឹត្យ**

– អនុក្រឹត្យលេខ២៤០ អនក្រ ប.ក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការធ្វើប្រតិភូកម្មសិទ្ធិអំណាចទៅឲ្យ គណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ក្នុងការគ្រប់គ្រងបុគ្គលិកបំពេញការងារនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– អនុក្រឹត្យលេខ១៩ អនក្រ ប.ក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ ២០១៧ ស្តីពី ការបង្កើតការិយាល័យប្រជាពលរដ្ឋនៅរដ្ឋបាលថ្នាក់ក្រោមជាតិ

– អនុក្រឹត្យលេខ១៨៤ អនក្រ ប.កចុះថ្ងៃទី០២ ខែធ្នូ ឆ្នាំ ២០១៩ ស្តីពី មុខងារនិងរចនាសម្ព័ន្ធរដ្ឋបាលស្រុក

– អនុក្រឹត្យលេខ២១៦ អនក្រ ប.កចុះថ្ងៃទី១៤ ធ្នូ ឆ្នាំ២០០៩ ស្តីពី តួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក

- **ច្បាប់**

– ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ២០០៨

– ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានីខេត្ត ក្រុង ស្រុក ខណ្ឌ ២០១៩

– ច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ ឆ្នាំ២០០៨

- **សៀវភៅ**

– នីតិរដ្ឋបាលទូទៅ រៀបរៀងដោយបណ្ឌិត សាយ បូរី ២០០១

– នីតិរដ្ឋបាលសាធារណៈ រៀបរៀងដោយសាស្ត្រចារ្យបណ្ឌិត ស៊ន សុឃន ២០១៧

– សៀវភៅណែនាំស្តីពី របៀបរបបការងាររបស់រដ្ឋបាលស្រុកឆ្នាំ២០១០

– សៀវភៅណែនាំស្តីពី តួនាទី ភារកិច្ច និងរបៀបការងាររបស់រដ្ឋបាលស្រុក

– សៀវភៅស្តីពី វិស័យសំខាន់នីមួយៗនៅស្រុកមេមត់ ឆ្នាំ២០១៦

- របាយការណ៍ស្រុក

– របាយការណ៍បូកសរុបលទ្ធផលការងាររបស់ក្រុមប្រឹក្សាស្រុកមេមត់អាណត្តិទី២(២០១៤- ២០១៨)

– កម្មវិធីវិនិយោគបីឆ្នាំរំកិល សម្រាប់អាណត្តិទី២ របស់ក្រុមប្រឹក្សាស្រុកមេមត់ ខេត្តត្បូងឃ្មុំ

- **អ៊ីនធើណេត**

– http://kampongthom.gov.kh/wp-content/uploads/2017/09/2017

– http://kampongthom.gov.kh/

– https://m.wikisource.org/wiki/

– https://gda.interior.gov.kh/commune-sangkat-management/

– https://www.bakc.org.kh/index.php/km/ 2020-02-01-15-34-45/2020-02-02-03-24-55/2020-02-02-03-39-17